រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# ការសម្រុះសម្រួល
# ទំនាស់នៅថ្នាក់ឃុំ សង្កាត់

ខែកញ្ញា ឆ្នាំ២០០៨

## មាតិកាអត្ថបទ


**អារម្ភកថា** ១

**ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅនៃទំនាស់** ២

១.១. និយមន័យ ២

១.២. ផលនៃទំនាស់ ៣

១.៣. ប្រភពនៃទំនាស់ ៤

១.៤. ប្រភេទនៃទំនាស់ ៨

១.៥. លក្ខណៈនៃទំនាស់ ៩

១.៦. ចរិតបុគ្គលក្នុងទំនាស់ ១០

**ផ្នែកទី២ ៖ ឧបករណ៍វិភាគទំនាស់** ១២

២.១. ត្រីកោណ "ប.ទ.ច" ១២

២.២. ផែនទីទំនាស់ ១៥

២.៣. ចន្ទល់នៃបញ្ហា ១៧

២.៤. ខ្សែពេលវេលា ១៨

២.៥. ការវិភាគតាមដំណាក់កាលនៃទំនាស់ ២០

**ផ្នែកទី៣ ៖ វិធីសាស្ត្រដោះស្រាយទំនាស់** ២៣

៣.១. យុទ្ធសាស្ត្រ ២៣

៣.២. វិធីសាស្ត្រដោះស្រាយទំនាស់ ២៤

៣.២.១. ការចរចា ២៤

៣.២.២. ការសម្រុះសម្រួល ២៩

៣.២.៣. មជ្ឈត្តការ ឬអាជ្ញាកណ្តាល ៣៣

៣.២.៤. ការដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការ ៣៤

៣.៣. ការជ្រើសរើសវិធីសាស្ត្រ ៣៥

៣.៤. ជំហានជាមូលដ្ឋានក្នុងការសម្រុះសម្រួលទំនាស់ ៣៦

៣.៤.១. ការទទួលពាក្យបណ្តឹង ៣៦

៣.៤.២. ការស៊ើបអង្កេត និងប្រមូលព័ត៌មាន ៣៧

៣.៤.៣. ការសម្រុះសម្រួល និងការពិភាក្សា ៣៨

៣.៤.៤. ការរៀបចំកិច្ចសន្យា ៤០

៣.៤.៥. ការបញ្ជូនករណីទំនាស់ទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ ៤០

៣.៤.៦. ការតាមដាន និងការផ្សះផ្សា ៤១

៣.៥. ជំនាញផ្សេងៗ ៤២

៣.៥.១. ការស្តាប់ ៤២

៣.៥.២. ការបរប្រយោគ ៤៣

៣.៥.៣. ការរៀបប្រយោគឡើងវិញ ៤៤

**ផ្នែកទី៤ : យន្តការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់ ៤៧**

៤.១. ឃុំ សង្កាត់ ៤៧

៤.២. គណៈកម្មាធិការដោះស្រាយទំនាស់ ៤៨

៤.៣. ថ្នាក់ដឹកនាំភូមិ ៥២

៤.៤. អ្នកមានឥទ្ធិពលក្នុងភូមិ ៥៣

៤.៥. ទំនាស់ដែលមិនអាចសម្រុះសម្រួល និងដោះស្រាយនៅថ្នាក់ឃុំ សង្កាត់បាន ៥៣

**ផ្នែកទី៥ : បទពិសោធន៍នៃការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់ ៥៤**

៥.១. ទំនាស់ដីធ្លី ៥៤

៥.២. ទំនាស់រវាងអ្នកជិតខាង ៥៨

៥.៣. ទំនាស់នៅក្នុងគ្រួសារ ៦១

# អារម្ភកថា

ជាទូទៅមនុស្សរស់នៅក្នុងសង្គមតែងតែមានទំនាស់ ។ ទំនាស់អាចកើតមានចំពោះមនុស្សគ្រប់រូប និងមាននៅគ្រប់ទីកន្លែងទាំងអស់ ប៉ុន្តែបញ្ហាដែលសំខាន់នោះគឺ តើត្រូវទប់ស្កាត់ គ្រប់គ្រង និងដោះស្រាយទំនាស់ទាំងនោះយ៉ាងដូចម្តេច?

ឃុំ សង្កាត់ គឺជាថ្នាក់រដ្ឋបាលដែលស្ថិតនៅជិតប្រជាពលរដ្ឋជាងគេ។ ក្រុមប្រឹក្សាឃុំ សង្កាត់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវានានាដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន ក្នុងនោះការសម្រុះសម្រួលទំនាស់ដែលកើតឡើងនៅក្នុងឃុំ សង្កាត់គឺជាសេវាចម្បងមួយក្នុងចំណោមសេវាចម្បងនានាដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋ ។

ដោយមើលឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីចម្បងក្នុងការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់ ទើបគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានរៀបចំ និងចងក្រងសៀវភៅស្តីពី **ការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់** នេះឡើង ដើម្បីជួយឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់ឱ្យកាន់តែមានប្រសិទ្ធភាព និងស្របតាមសមត្ថកិច្ចរបស់ខ្លួន ។

សៀវភៅនេះរៀបចំឡើងមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយប្រើប្រាស់សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបរិយាយអំពី :

- ទិដ្ឋភាពទូទៅនៃទំនាស់
- ឧបករណ៍វិភាគទំនាស់
- វិធីសាស្ត្រដោះស្រាយទំនាស់
- យន្តការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់
- បទពិសោធន៍នៃការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងទទួលស្វាគមន៍ជានិច្ចនូវមតិរិះគន់ស្ថាបនា ដើម្បីកែលម្អសៀវភៅនេះ ។

# ផ្នែកទី១

# ទិដ្ឋភាពទូទៅនៃទំនាស់

# ផ្នែកទី១
# ទិដ្ឋភាពទូទៅនៃទំនាស់

## ១.១. និយមន័យ

### ១.១.១. ទំនាស់

ទំនាស់ គឺជាភាពមិនចុះសម្រុងគ្នារវាងមនុស្សពីរនាក់ ឬច្រើននាក់ ដែលមានគំនិត គោលដៅ ជំនឿសាសនា គុណតម្លៃ ការយល់ឃើញ ឬតម្រូវការខុសគ្នា ហើយអាចឈានដល់ការប្រកួតប្រជែង ការប៉ះទង្គិច ឬមានការគំរាមកំហែងដល់សេចក្តីត្រូវការ ធនធាន អំណាច ឬផលប្រយោជន៍របស់តួអង្គដែលពាក់ព័ន្ធ។ ភាពមិនចុះសម្រុងនេះអាចស្តែងឡើងជាសកម្មភាពពិត ឬគ្រាន់តែជាការយល់ឃើញខុសគ្នាប៉ុណ្ណោះ។ លើសពីនេះទៀត មនុស្សម្នាក់ៗក៏អាចមានទំនាស់ជាមួយនឹងខ្លួនឯងផងដែរ។

ទំនាស់បង្កប់នៅក្នុងការទំនាក់ទំនងទាំងអស់របស់មនុស្ស ហេតុនេះទើបតម្រូវឱ្យមនុស្សម្នាក់ៗត្រូវចេះសម្របសម្រួលខ្លួននៅក្នុងការទំនាក់ទំនងរបស់ខ្លួន។ លើសពីនេះទៀត លទ្ធផលទំនាស់អាស្រ័យលើមនុស្សដែលត្រូវដោះស្រាយប្រកបដោយការស្ថាបនា ឬដោយភាពមហន្តរាយ។



**ឧទាហរណ៍ "ទំនាស់រវាងក្រុមយុវជន" :** នៅក្នុងឃុំមួយមានយុវជនពីរក្រុមដែលមកពីភូមិផ្សេងគ្នា។ យុវជនទាំងពីរក្រុមនេះបានមកចូលរួមក្នុងពិធីរាំលេងសប្បាយក្នុងភូមិមួយ។ នៅក្នុងអំឡុងពេលនៃការរាំលេងនេះ ក្រុមមួយបានបង្ហាញនូវការពេញចិត្ត និងបានរាំជិតៗនឹងនារីម្នាក់ ដែលជាសាច់ញាតិរបស់សមាជិកម្នាក់នៃក្រុមមួយទៀត។ បន្ទាប់មកក្រុមទាំងពីរមានការប៉ះទង្គិចគ្នា ដែលការប៉ះទង្គិចនេះបានឈានទៅដល់ការវាយតប់គ្នាយ៉ាងខ្លាំង។



**ឧទាហរណ៍ "ទំនាស់ព្រំដី" :** នៅក្នុងភូមិមួយមានគ្រួសារពីររស់នៅជិតខាងគ្នា។ គ្រួសារមួយបានធ្វើរបងថ្មី ដោយបង្អិតព្រំដីចូលក្នុងដីរបស់គ្រួសារមួយទៀតប្រវែងប្រហែល១ម៉ែត្រ ដោយនិយាយថា ព្រំដីដែលមានស្រាប់មិនត្រឹមត្រូវ។ ការបង្អិតព្រំដីនេះបាននាំឱ្យមានទំនាស់យ៉ាងខ្លាំងរវាងគ្រួសារទាំងពីរនេះ។

### ១.១.២. ភាពតានតឹង

ភាពតានតឹង គឺជាភាពមិនពេញចិត្តរបស់នរណាម្នាក់ ឬរបស់សង្គមទៅនឹងអ្វីមួយ។ ភាពតានតឹងអាចកើតមាននៅគ្រប់ស្ថានភាពទាំងអស់ដូចជា នៅក្នុងគ្រួសារ សហគមន៍ ក្នុងចំណោមមិត្តភក្តិ ឬនៅក្នុងសង្គមជាដើម។

**ឧទាហរណ៍ ៖**

- សោភាមិនពេញចិត្តនឹងស្វាមីរបស់នាងដែលតែងតែចាយវាយខ្ជះខ្ជាយ
- គ្រួសារមួយមានការមិនពេញចិត្តជាមួយអ្នកជិតខាងរបស់គេដែលតែងតែចាក់បទចម្រៀងឮខ្លាំងៗ
- កម្មកររោងចក្រមិនសប្បាយចិត្តនឹងថៅកែដែលផ្តល់ប្រាក់កម្រៃតិចតួចឱ្យពួកគេ

ភាពតានតឹងជាផ្នែកមួយនៃទំនាស់ ដូច្នេះវាអាចកើតមានទាំងនៅមុនពេលទំនាស់ ក្នុងអំឡុងពេលទំនាស់ និងក្រោយទំនាស់ផងដែរ ។

## ១.២. ផលនៃទំនាស់

ទំនាស់អាចផ្តល់ផលវិជ្ជមាន ឬអវិជ្ជមាន ប៉ុន្តែទោះបីជាទំនាស់អាចផ្តល់ផលវិជ្ជមាន ឬផលអវិជ្ជមានក៏ដោយ ក៏មនុស្សម្នាក់ៗមិនអាចគេចផុតពីទំនាស់បានដែរ ពីព្រោះទំនាស់អាចកើតមាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដូចជាទំនាស់នៅក្នុងគ្រួសារ ទំនាស់ជាមួយអ្នកជិតខាង ឬទំនាស់ជាមួយមិត្តភក្តិជាដើម ។



**១.២.១. ទំនាស់ដែលផ្តល់ផលវិជ្ជមាន ៖** គឺជាទំនាស់ដែលអាចគ្រប់គ្រងបាន និងផ្តល់លទ្ធផលនូវការផ្លាស់ប្តូរជាវិជ្ជមាន ឬកែលម្អបុគ្គល គ្រួសារ សហគមន៍ សង្គម... ឬនយោបាយដែលធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ បង្កើនការទំនាក់ទំនង ឬសេវាក្នុងសង្គម ឬបង្កើនភាពយុត្តិធម៌ក្នុងសង្គមជាដើម ។ លើសពីនេះទៀត ទំនាស់គឺជាកត្តាសំខាន់ដែលនាំឱ្យមានការផ្លាស់ប្តូរធ្វើឱ្យមនុស្សចេះធ្វើការឆ្លុះបញ្ចាំង និងស្រាវជ្រាវនូវទិសដៅថ្មីៗព្រមទាំងជាផ្លូវនាំឱ្យមនុស្សអាចស្វែងយល់អំពីបញ្ហានានាផងដែរ ។

**ឧទាហរណ៍ ៖**

- ការតវ៉ារបស់ក្រុមកម្មកររោងចក្រកាត់ដេរជាមួយអ្នកគ្រប់គ្រង ឬថៅកែរោងចក្រដើម្បីទាមទារឱ្យអនុវត្តតាមច្បាប់ការងារ ។
- ម្តាយស្តីបន្ទោសកូនប្រុសដែលតែងតែត្រឡប់ពីសាលារៀនយឺតយ៉ាវ ហើយសេពគប់ជាមួយមិត្តភក្តិមិនល្អ
- ប្រជាពលរដ្ឋក្នុងឃុំសម្តែងការមិនពេញចិត្តចំពោះការអនុវត្តគម្រោងមូលនិធិឃុំ ដោយទាមទារឱ្យមេឃុំធ្វើការបកស្រាយអំពីមូលហេតុដែលគម្រោងស្នើសុំដោយពួកគាត់ភាគច្រើនមិនបានឆ្លើយតប ។



**១.២.២. ទំនាស់ដែលផ្តល់ផលអវិជ្ជមាន ៖** គឺជាទំនាស់ដែលមិនអាចគ្រប់គ្រងបាន ហើយផ្តល់នូវលទ្ធផលចេញជា អំពើហិង្សា ការកាប់សម្លាប់ ការរងរបួស ការបំផ្លាញទ្រព្យសម្បត្តិ ការបំផ្លាញបរិស្ថាន ការបាត់បង់ធនធាន ឬធ្វើឱ្យភាគីណាមួយមានអារម្មណ៍ឈឺចាប់ ។

ឧទាហរណ៍ :

- ការវាយតប់គ្នារវាងក្រុមក្មេងពាល
- ការលួចបង្ខិតព្រំដី ឬការរំលោភយកដីធ្លី
- ការគាបសង្កត់លើសិទ្ធិសេរីភាព ការមិនផ្តល់នូវភាពយុត្តិធម៌ ការបង្ខូចកេរ្តិ៍ឈ្មោះអ្នកដទៃជាសាធារណៈ ដោយគ្មានហេតុផល




## ១.៣. ប្រភពនៃទំនាស់

រាល់ទំនាស់ដែលកើតមានឡើងទាំងអស់សុទ្ធតែមានប្រភព ហើយប្រភពនៃទំនាស់ទាំងអស់នោះមិនដូចគ្នាទេ ព្រោះប្រភពនៃទំនាស់តែងតែមានការប្រែប្រួលទៅតាមលក្ខណៈនៃទំនាស់នីមួយៗ។ ប្រភព និងកត្តាដែលនាំឱ្យមានទំនាស់អាចមានដូចជា :

- ព័ត៌មាន
- ការទំនាក់ទំនង
- ការឱ្យតម្លៃ
- រចនាសម្ព័ន្ធ
- ផលប្រយោជន៍
- ការយល់ឃើញ
- បុរេវិនិច្ឆ័យ ឬការស្មានទុកជាមុន
- ផ្នត់គំនិត
- ការរើសអើង
- ...។ល។

### ១.៣.១. ព័ត៌មាន

ទំនាស់មួយចំនួនកើតឡើងដោយសារការខ្វះព័ត៌មាន ឬការទទួលព័ត៌មានមិនបានគ្រប់គ្រាន់ និងមិនត្រឹមត្រូវក្នុងចំណោមភាគីនៃទំនាស់ ឬពេលខ្លះភាគីនៃទំនាស់ទាំងនោះមានការបកស្រាយអត្ថន័យព័ត៌មានខុសៗគ្នា។

**ឧទាហរណ៍ :** **មករា** ជាប្រធានគ្រប់គ្រងរបស់ **មីនា**។ **មករា** មិនសប្បាយចិត្តនឹង **មីនា** ព្រោះ**មីនា**តែងតែមកដល់ការិយាល័យយឺតស្ទើររាល់ព្រឹក។ ជារៀងរាល់ព្រឹក **មីនា** ត្រូវជូនកូនរបស់នាងទៅសាលារៀន រួចទើបទៅធ្វើការ ចំណែក **មករា** តែងតែកំណត់ការប្រជុំនៅពេលព្រឹកព្រលឹម។ ទោះបីជានាងទទួលការស្តីបន្ទោសជាញឹកញាប់ក៏ដោយ ក៏ **មីនា** មិនបានផ្តល់ព័ត៌មានដល់ **មករា** អំពីមូលហេតុដែលនាងមកការិយាល័យយឺតពេលដែរ។

## ១.៣.២. ទំនាក់ទំនង

ទំនាស់មួយចំនួនកើតឡើងដោយខ្វះការទំនាក់ទំនង ឬមានទំនាក់ទំនងមិនល្អ ដែលនាំឱ្យមានការកើនឡើងនូវភាពតានតឹង ការសន្និដ្ឋានដែលមិនត្រឹមត្រូវ ការមិនយល់អំពីគ្នាទៅវិញទៅមក ឬការសម្តែងនូវឥរិយាបថខុសឆ្គងដដែលៗជាដើម។

**ឧទាហរណ៍ :** មានគ្រួសារពីរ គឺគ្រួសារ **សុក** និងគ្រួសារ **សៅ** បានរស់នៅក្បែរខាងគ្នាជាយូរឆ្នាំមកហើយ ប៉ុន្តែពួកគេមិនមានទំនាក់ទំនងល្អជាមួយគ្នាឡើយ។ ថ្ងៃមួយគ្រួសារ **សុក** ត្រូវរៀបអាពាហ៍ពិពាហ៍កូនស្រី ហើយត្រូវការទីធ្លាមុខផ្ទះគ្រួសារ **សៅ**។ **សុក** បានទៅសុំការអនុញ្ញាតពី **សៅ** ដើម្បីរៀបចំរោងពិធី ប៉ុន្តែ **សៅ** មិនអនុញ្ញាតឱ្យ **សុក** សាងសង់រោងការនៅមុខផ្ទះរបស់ខ្លួនឡើយ ដោយយល់ថា គ្រួសាររបស់គាត់មិនដែលមានទំនាក់ទំនងគ្នាជាមួយគ្រួសារ **សុក** ទេ។ ការបដិសេធរបស់ **សៅ** បានធ្វើឱ្យ **សុក** ខឹងយ៉ាងខ្លាំង។

## ១.៣.៣. ការឱ្យតម្លៃផ្សេងគ្នា

ទំនាស់មួយចំនួនកើតឡើងដោយសារភាពផ្សេងៗគ្នារបស់មនុស្សនៅក្នុងការឱ្យតម្លៃលើអ្វីមួយ។ ជាការពិត គ្រាន់តែជាការយល់ឃើញ ឬការឱ្យតម្លៃផ្សេងគ្នាមិនបង្កឱ្យមានទំនាស់ទេ ប៉ុន្តែទំនាស់អាចកើតមាន ប្រសិនបើមានគេបង្ខំឱ្យទទួលយកគំនិត ឬការឱ្យតម្លៃអ្វីមួយរបស់អ្នកដទៃដែលមានការយល់ឃើញ និងឱ្យតម្លៃខុសពីខ្លួន។

**ឧទាហរណ៍ :** ថ្ងៃមួយ **សីហា** បានទៅជួបជុំមិត្តភក្តិ ដែលបានបែកគ្នាអស់រយៈពេលប្រមាណ១០ឆ្នាំ។ ក្នុងពេលបរិភោគអាហារជុំគ្នា **សីហា** ជាអ្នកចេញលុយទាំងអស់ ព្រោះមិត្តភក្តិរបស់គាត់មានជីវភាពខ្វះខាត។ នៅពេលត្រឡប់មកផ្ទះវិញ **សីហា** បានរៀបរាប់ប្រាប់ **កញ្ញា** ដែលជាប្រពន្ធអំពីការជួបជុំមិត្តភក្តិ និងការចំណាយផងដែរ។ **កញ្ញា** ខឹងសម្បាយ៉ាងខ្លាំង ហើយនិយាយថា ការជួបជុំមិត្តភក្តិផឹកស៊ីនោះវាគ្មានប្រយោជន៍ទេ ថែមទាំងត្រូវចំណាយលុយច្រើនទៀត។ ភ្លាមនោះ **សីហា** តបវិញថា ការជួបជុំមិត្តភក្តិមានសារៈសំខាន់ណាស់សម្រាប់គាត់ ហើយបង្ខំ **កញ្ញា** ឱ្យទទួលយកឥរិយាបថបែបនេះ ដែលជាហេតុធ្វើឱ្យ **កញ្ញា** មិនសប្បាយចិត្ត។

## ១.៣.៤. រចនាសម្ព័ន្ធ

ទំនាស់រចនាសម្ព័ន្ធកើតឡើងដោយសារការចែករំលែកអំណាច តួនាទី ភារកិច្ច និងឱកាសក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តមិនបានស្មើគ្នា និងមិនមានភាពយុត្តិធម៌។

**ឧទាហរណ៍ :** សមាគមកសិករមួយបានបង្កើតឡើងដោយមានសមាជិកចូលរួមយ៉ាងច្រើន។ **ច័ន្ទ** ជាសមាជិកម្នាក់ ដែលបានចូលរួមតាំងពីដំបូង ហើយមានតួនាទីក្នុងគណៈគ្រប់គ្រងសមាគមផងដែរ។ ប៉ុន្តែដោយសារគ្រួសារ **ច័ន្ទ**

មានជីវភាពខ្វះខាត និងមិនបានរៀនសូត្រខ្ពង់ខ្ពស់ ហេតុនេះហើយបានជានៅពេលប្រជុំធ្វើសេចក្តីសម្រេចចិត្តនានា **ច័ន្ទ** មិនត្រូវបានអញ្ជើញឱ្យចូលរួមឡើយ ។ លើសពីនេះទៀត **ច័ន្ទ** ក៏មិនដែលបានទៅចូលរួមវគ្គបណ្តុះបណ្តាល ឬទស្សនកិច្ចនានាឡើយ ។ កត្តាទាំងនេះហើយបានជា **ច័ន្ទ** មិនសប្បាយចិត្ត ហើយសម្រេចចិត្តលាឈប់ពីគណៈគ្រប់គ្រងសមាគម ។

## ១.៣.៥. ផលប្រយោជន៍

ទំនាស់មួយចំនួនកើតឡើងដោយសារការប្រកួតប្រជែង ឬដណ្តើមផលប្រយោជន៍ ឬធនធាន និងការបែងចែកផលប្រយោជន៍ និងធនធានមិនបានត្រឹមត្រូវផងដែរ ។

**ឧទាហរណ៍ :** ក្នុងភូមិមួយមានស្រះទឹករួមមួយដែលអ្នកភូមិស្ទើរតែទាំងអស់បានប្រើប្រាស់ទឹកស្រះនេះពិសេសនៅរដូវប្រាំង ។ អ្នកភូមិមួយចំនួនតូចប្រើប្រាស់ទឹកស្រះយ៉ាងច្រើនដើម្បីស្រោចដំណាំ និងចិញ្ចឹមសត្វ ។ ពួកគេបានលាងគោ ក្របីក្នុងទឹកស្រះនោះទៀតផង ដែលជាហេតុធ្វើឱ្យស្រះនោះមានភាពកខ្វក់ និងអាចឆាប់រីងស្ងួតនាពេលខាងមុខ ។ ប្រជាពលរដ្ឋភាគច្រើនបានធ្វើការតវ៉ា និងប្តឹងទៅក្រុមប្រឹក្សាឃុំដើម្បីធ្វើយ៉ាងណារក្សាទឹកស្រះនេះសម្រាប់ប្រើប្រាស់បានពេញមួយរដូវប្រាំង ។

## ១.៣.៦. ការយល់ឃើញ

ការយល់ឃើញ គឺជាការទទួលអារម្មណ៍របស់មនុស្សម្នាក់ៗតាមវិញ្ញាណទាំងប្រាំ រួមមាន :

- ចក្ខុវិញ្ញាណ
- សោតវិញ្ញាណ
- ជីវ្ហាវិញ្ញាណ
- ឃានវិញ្ញាណ និង
- កាយវិញ្ញាណ

តាមរយៈការទទួលអារម្មណ៍តាមវិញ្ញាណទាំងនេះ បណ្តាលឱ្យមនុស្សយើងមានការយល់ឃើញទៅលើអ្វីមួយផ្សេងៗគ្នា ។ ដូច្នេះនៅក្នុងទំនាស់ ភាគីនីមួយៗតែងតែមានការយល់ឃើញអំពីទំនាស់ផ្សេងៗគ្នា ។ ចូរចងចាំថា **អ្វីដែលយើងមើលឃើញមិនមែនមនុស្សដទៃមើលឃើញដូចយើងនោះទេ** ។ លើសពីនេះទៀត ការយល់ឃើញផ្សេងគ្នាក៏ជាមូលហេតុដែលនាំឱ្យមានទំនាស់ផងដែរ ។

**ហេតុអ្វីបានជាមនុស្សម្នាក់ៗតែងតែមានការយល់ឃើញផ្សេងៗគ្នា?**

បន្ថែមលើការទទួលអារម្មណ៍តាមវិញ្ញាណទាំងប្រាំ មនុស្សម្នាក់ៗអាចមានការយល់ឃើញផ្សេងៗគ្នាអាស្រ័យលើកត្តាមួយចំនួនទៀត ដូចជា :

- កម្រិតជីវភាពរស់នៅ
- ទីតាំងភូមិសាស្ត្រ តំបន់ដែលពួកគេរស់នៅ ល័ក្ខខ័ណ្ឌធម្មជាតិ
- ទំនៀមទម្លាប់ ប្រពៃណី និងវប្បធម៌

- ចំណង់ចំណូលចិត្ត តម្រូវការ និងការនិយម
- ចំណេះដឹង បទពិសោធន៍ តួនាទី
- ភេទ អាយុ កាយសម្បទា
- នយោបាយ សេដ្ឋកិច្ច វចនាសម្ព័ន្ធ ...។ល។

**ឧទាហរណ៍ ១ :** ថ្ងៃមួយ **វិច្ឆិកា** បានទៅលេងផ្ទះរបស់ **កូឡាប** ដែលជាក្មួយស្រីគាត់នៅតាខ្មៅ។ នៅក្នុងបរិវេណផ្ទះរបស់ក្មួយស្រីគាត់មានដាំដំណាំជាច្រើន ដោយរួមទាំងស្រះទឹកមួយដែលពោរពេញទៅដោយដើមឈូក ព្រមទាំងមានផ្កាឈូកជាច្រើនផងដែរ។ ឃើញដូច្នោះ **វិច្ឆិកា** និយាយថា "ក្មួយដឹងទេ! ស្រះទឹកដែលមានដើមឈូកមិនអាចឱ្យត្រីលូតលាស់ធំធាត់បានទេ។ ដូច្នេះក្មួយត្រូវដកដើមឈូកទាំងនេះចេញឱ្យអស់ទៅ"។ នៅពេលឮយោបល់របស់ពូដូច្នេះ **កូឡាប** មានអារម្មណ៍មិនសប្បាយចិត្ត ហើយឆ្លើយតបទៅ **វិច្ឆិកា** វិញថា "ដកដើមឈូកចេញមិនបានទេពូ! ព្រោះផ្កាឈូកមានពណ៌ស្អាតណាស់ និងមានក្លិនក្រអូបទៀតផង"។



**មនុស្សម្នាក់ៗអាចមើលរូបខាងក្រោមនេះឃើញផ្សេងៗគ្នា។**



### ១.៣.៧. បុរេវិនិច្ឆ័យ ឬការវាយស្មានទុកជាមុន

បុរេវិនិច្ឆ័យ គឺជាគំនិត ឬទស្សនៈដែលមនុស្សបង្កើតឡើងជាមុនទៅលើស្ថានការណ៍មួយ ឬទៅលើមនុស្សម្នាក់ ឬក្រុមមនុស្សណាមួយដោយពុំមានហេតុផលត្រឹមត្រូវ ពុំមានព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវ មានជំនឿស៊ប ឬមានការជ្រុលនិយមលើអ្វីមួយជាដើម។ ជាទូទៅគំនិត ឬទស្សនៈទាំងនេះ អាចហៅម្យ៉ាងទៀតថា "ការវាយស្មានទុកជាមុន" ដែលភាគច្រើនមានទំនោរទៅរកការវាយតម្លៃបែបអវិជ្ជមាន។

**ឧទាហរណ៍ :**

- មានគ្រួសារមួយរស់នៅភូមិមួយដែលមានការរាប់អានពីអ្នកជិតខាង។ គ្រួសារនេះមានឪពុកមាម្នាក់រស់នៅបរទេស ហើយបានត្រឡប់មកប្រទេសកម្ពុជាវិញ ក្លាយជាសកម្មជនគណបក្សនយោបាយមួយ។ ឪពុកមាម្នាក់នោះតែងតែមកលេងក្រុមគ្រួសារនេះជាញឹកញាប់ ដែលការមកលេងជាញឹកញាប់នេះ ធ្វើឱ្យអ្នកជិតខាងគិតថា គ្រួសារនេះចូលរួមក្នុងគណបក្សដែលឪពុកមាគាត់គាំទ្រ។
- មានបុរសម្នាក់ចូលចិត្តពិសាស្រាស្ទើររាល់ថ្ងៃ ថ្ងៃមួយគាត់ជិះម៉ូតូដួលនៅតាមផ្លូវ ខ្ញុំមើលឃើញពីចម្ងាយ ខ្ញុំគិតថា គាត់ដួលម៉ូតូដោយសារស្រវឹងស្រា។

ការវិនិច្ឆ័យលើអ្វីមួយដោយគ្មានហេតុផល ឬជាការវាយស្មានទុកជាមុន ពិសេសការវាយស្មានដែលមានទំនោរទៅរកការវាយតម្លៃបែបអវិជ្ជមាន ក៏ជាមូលហេតុដែលនាំឱ្យកើតមានទំនាស់ផងដែរ។

### ១.៣.៨. ផ្នត់គំនិត

ផ្នត់គំនិត គឺជាគំនិត ឬទស្សនៈ ឬជំនឿដែលមានកន្លងមក ហើយក្លាយជាទម្លាប់ដែលពិបាកធ្វើការផ្លាស់ប្តូរ។ ផ្នត់គំនិតនេះ ក៏ជាកត្តាដែលនាំឱ្យមានទំនាស់ផងដែរ។

**ឧទាហរណ៍**

- បុរសជាមេគ្រួសារ និងជាអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ
- អ្នកក្រដោយសារខ្ជិល
- ស្ត្រីដើរលេងផ្ទះគេមិនល្អ

## ១.៤. ប្រភេទនៃទំនាស់

ជារួមទំនាស់មានបីប្រភេទដូចខាងក្រោម :

- ទំនាស់បង្កប់
- ទំនាស់ស្តែងចេញភ្លាមៗ
- ទំនាស់ចំហ

### ១.៤.១. ទំនាស់បង្កប់



ទំនាស់បង្កប់ គឺជាទំនាស់ ឬភាពតានតឹងដែលកើតឡើងនៅក្នុងខ្លួនបុគ្គល ឬសង្គមមួយ ប៉ុន្តែមិនស្តែងចេញជារូបរាង ឬសកម្មភាពនៃទំនាស់ឱ្យគេដឹងទេ។ ក្នុងករណីមិនធ្វើការទប់ស្កាត់ និងគ្រប់គ្រងទាន់ពេលវេលា នោះទំនាស់ប្រភេទនេះអាចបង្កឱ្យមានទំនាស់ដែលមានរូបរាង ឬសកម្មភាពបាន។

**ឧទាហរណ៍** : ក្នុងភូមិមួយមានស្រះទឹករួមមួយដែលអ្នកភូមិស្ទើរតែទាំងអស់បានប្រើប្រាស់ទឹកស្រះនេះពិសេសនៅរដូវប្រាំង។ អ្នកភូមិមួយចំនួនតូចបានដាំដំណាំបន្លែនៅជុំវិញស្រះនោះ ហើយតែងតែយកធុង និងសម្ភារៈបាញ់ថ្នាំពុលទៅលាងសម្អាតក្នុងស្រះនោះ។ ទោះបីជាមិនទាន់មានការឈ្លោះប្រកែកគ្នារវាងអ្នកបរិភោគទឹក និងអ្នកដាំបន្លែក៏ដោយ ក៏អ្នកបរិភោគទឹកភាគច្រើនមិនសប្បាយចិត្ត និងមានការព្រួយបារម្ភអំពីសុខភាពរបស់ពួកគេ។

### ១.៤.២. ទំនាស់ស្តែងចេញភ្លាមៗ



ទំនាស់ស្តែងចេញភ្លាមៗ គឺជាទំនាស់ដែលបង្ហាញជារូបរាង ឬសកម្មភាពនៃទំនាស់ភ្លាមៗ ប៉ុន្តែមិនចាក់ឫសជ្រៅ ឬមិនមានការគុំកួនទេ។ ក្នុងករណីមិនចាត់វិធានការផ្សះផ្សា និងគ្រប់គ្រងឱ្យទាន់ពេលវេលាទេ នោះទំនាស់ប្រភេទនេះនឹងចាក់ឫសយ៉ាងជ្រៅ ហើយអាចក្លាយជាទំនាស់ដែលមានទ្រង់ទ្រាយធំបាន។

**ឧទាហរណ៍** : នៅពេល **វិច្ឆិកា** ប្រាប់ **កុឡាប** ឱ្យដកដើមឈូកចេញពីស្រះ ប៉ុន្តែត្រូវ **កុឡាប** បដិសេធ ពេលនោះ **វិច្ឆិកា** បានស្តីបន្ទោស **កុឡាប** ភ្លាមៗតែម្តង។

### ១.៤.៣. ទំនាស់ចំហ



ទំនាស់ចំហ គឺជាទំនាស់ដែលបានចាក់ឫសយ៉ាងជ្រៅ ឬមានគំនុំគុំកួនជាយូរមកហើយ ហើយបានស្តែងចេញជារូបរាង ឬសកម្មភាពនៃទំនាស់ឡើង។ ក្នុងករណីមិនចាត់វិធានការផ្សះផ្សា និងដោះស្រាយឱ្យបានទាន់ពេលវេលាទេ នោះទំនាស់ប្រភេទនេះអាចបង្កឱ្យមានទំនាស់កាន់តែធំ ហើយអាចបង្កមហន្តរាយកាន់តែខ្លាំង។

**ឧទាហរណ៍** :

- ប្តីបានប្រើអំពើហិង្សាលើប្រពន្ធរបស់ខ្លួន ដោយសារតែការប្រច័ណ្ឌជាយូរមកហើយ
- កម្មករធ្វើបាតុកម្មតម្លើងប្រាក់បៀវត្ស ដោយសារការស្នើសុំតម្លើងប្រាក់បៀវត្សកន្លងមកមិនបានសម្រេច
- ក្រុមក្មេងពាលបានវាយតប់សងសឹកគ្នាទៅវិញទៅមក

## ១.៥. លក្ខណៈនៃទំនាស់

លក្ខណៈនៃទំនាស់អាចមានដូចជា :

- **ទំនាស់បុគ្គលខ្លួនឯង** : ខ្លួនយើងដែលជាបុគ្គលម្នាក់ ជារឿយៗតែងតែមានទំនាស់ជាមួយនឹងខ្លួនឯងអំពីការឱ្យតម្លៃ ជម្រើស ការប្តេជ្ញាចិត្ត អារម្មណ៍ និងការទំនាក់ទំនងជាដើម។

- **ទំនាស់អន្តរបុគ្គល** : ការខ្វែងគំនិត ឬការយល់ឃើញខុសគ្នារវាងបុគ្គលពីរនាក់ជាលក្ខណៈផ្ទាល់ខ្លួន ។
- **ទំនាស់អន្តរតួនាទី** : ជាទំនាស់ដែលកើតឡើងរវាងបុគ្គលពីរនាក់ ឬមនុស្សពីរក្រុមនៅលើមូលដ្ឋាននៃការងារ និងតួនាទីរបស់ពួកគេ ។
- **ទំនាស់អន្តរក្រុម** : ជាទំនាស់ដែលកើតចេញពីការខ្វែងគំនិតរវាងក្រុមផ្សេងៗទៅលើរបស់អ្វីមួយ ។
- **ទំនាស់អន្តរអង្គភាព** : ជាទំនាស់រវាងស្ថាប័ន ឬអង្គការពីរដែលមានអំណាចស្មើគ្នា ឬមិនស្មើគ្នា ។
- **ទំនាស់អន្តរសហគមន៍** : ជាទំនាស់រវាងក្រុមធំៗពីរដែលជាប់ទាក់ទងគ្នាដោយសារ ទឹកដី សាសនា ជនជាតិ ឬប្រវត្តិសាស្ត្រជាដើម ។
- **ទំនាស់អន្តរជាតិ** : ជាទំនាស់រវាងប្រទេស និងប្រទេស ។

## ១.៦. ចរិតបុគ្គលក្នុងទំនាស់

ជាទូទៅមនុស្សម្នាក់ៗមានចរិតខុសៗគ្នាក្នុងការរស់នៅក្នុងគ្រួសារ សហគមន៍ និងសង្គម ។ យ៉ាងណាមិញ បុគ្គលម្នាក់ៗក្នុងទំនាស់ក៏មានចរិតខុសៗគ្នាដែរ ។ ដូច្នេះក្នុងការសម្រុះសម្រួលទំនាស់ អ្នកសម្រុះសម្រួលត្រូវពិនិត្យមើលថាតើបុគ្គលនៃទំនាស់មានចរិតយ៉ាងដូចម្ដេច?

**ចរិតនៃបុគ្គលក្នុងទំនាស់អាចមានដូចជា :**

- **ចរិតត្រួតត្រា** ជាបុគ្គលដែល :
  - ចង់ឱ្យអ្នកដទៃធ្វើតាម ឬស្របតាមខ្លួន
  - ខ្វះអំណត់ក្នុងការសន្ទនា
  - មិនសូវស្ដាប់យោបល់អ្នកដទៃ
  - គិតពីទំនាក់ទំនងតិចតួច
  - គិតពីគោលបំណងរបស់ខ្លួនច្រើន
  - និយមប្រើកម្លាំង ធ្វើការគាបសង្កត់ ឬធ្វើការវាយប្រហារ
  - ចូលចិត្តបុគ្គលដែលមានចរិតគេចវេស និងចរិតទទួលយក



- **ចរិតដោះស្រាយ** ជាបុគ្គលដែល :
  - ចង់បញ្ចប់នូវទំនាស់រវាងភាគីទាំងសងខាង
  - គិតពីទំនាក់ទំនងច្រើន
  - ចូលចិត្តប្រមូលព័ត៌មាន និងពិភាក្សារកដំណោះស្រាយ
  - ចូលចិត្តបុគ្គលដែលមានចរិតដោះស្រាយ ឬចរិតយល់ព្រម

- **ចរិតសម្រុះសម្រួល** ជាបុគ្គលដែល :
  - ចង់ឃើញភាគីទាំងអស់នៃទំនាស់ចូលរួមដោះស្រាយបញ្ហា
  - មានការបើកចំហ
  - ចង់ឱ្យភាគីទាំងសងខាងឈ្នះដូចគ្នា
  - ចង់ឱ្យភាគីទាំងអស់នៃទំនាស់កាត់បន្ថយនូវការរំពឹងថានឹងឈ្នះពីទំនាស់
  - គិតពីគោលបំណងរបស់ខ្លួនផង និងគោលបំណងរបស់អ្នកដទៃផង
  - ចូលចិត្តបុគ្គលដែលមានចរិតសម្រុះសម្រួល និងយល់ព្រម
- **ចរិតគេចវេស** ជាបុគ្គលដែល :
  - មិនចាប់អារម្មណ៍ ឬខ្វល់ខ្វាយជាមួយនឹងទំនាស់
  - បដិសេធក្នុងការធ្វើការសន្ទនា ឬពិភាក្សាអំពីការសម្រុះសម្រួល
  - គៀសខ្លួនចេញ ឬគេចចេញពីការសម្រុះសម្រួល
  - ធ្វើមិនដឹងមិនឮ ឬដកថយ ឬពន្យារពេលនៃការសម្រុះសម្រួលទំនាស់
  - ចូលចិត្តបុគ្គលដែលមានចរិតគេចវេសដូចគ្នា



- **ចរិតយល់ព្រម** ជាបុគ្គលដែល :
  - ងាយយល់ស្របជាមួយគំនិតយោបល់របស់អ្នកដទៃ
  - ងាយនឹងទទួលយក ឬយល់ព្រមគំនិតអ្នកដទៃនៅពេលមានការខ្វែងគំនិតគ្នា
  - គិតពីគោលបំណងផ្ទាល់ខ្លួនតិចតួច
  - គិតពីទំនាក់ទំនងច្រើន
  - ចូលចិត្តបុគ្គលដែលមានចរិតដោះស្រាយ និងសម្រុះសម្រួល

# ផ្នែកទី២
# ឧបករណ៍វិភាគទំនាស់

# ផ្នែកទី២
# ឧបករណ៍វិភាគទំនាស់

ឧបករណ៍វិភាគទំនាស់ដែលគេនិយមប្រើអាចមានដូចជា :

- ត្រីកោណ "ប.ទ.ច"
- ផែនទីទំនាស់
- ចន្ទល់នៃបញ្ហា
- ខ្សែពេលវេលា
- វិភាគតាមដំណាក់កាលនៃទំនាស់... ។ល។

## ២.១. ត្រីកោណ "ប.ទ.ច"

### ២.១.១. និយមន័យ

ត្រីកោណ "ប.ទ.ច" គឺជាឧបករណ៍មួយសម្រាប់វិភាគកត្តាទាំងឡាយដែលពាក់ព័ន្ធនឹងចិត្តឬការគិត ការប្រព្រឹត្តឬទង្វើ និងបរិបទនៃភាគីនីមួយៗក្នុងចំណោមភាគីទំនាស់។

**ប** : មានន័យថា **បរិបទ**

**ទ** : មានន័យថា **ទង្វើ ឬការប្រព្រឹត្ត**

**ច** : មានន័យថា **ចិត្ត ឬការគិត**




តាមរូបខាងលើ បង្ហាញឱ្យឃើញថា បរិបទ ចិត្ត/ការគិត និងទង្វើតែងតែមានទំនាក់ទំនង ឬមានអំពើរវាងគ្នាទៅវិញទៅមក។

### ២.១.២. គោលបំណង

ការបង្កើតឧបករណ៍ត្រីកោណ "ប.ទ.ច" ក្នុងគោលបំណង :

- ដើម្បីកំណត់អំពី បរិបទ ចិត្ត និងការប្រព្រឹត្តរបស់ភាគីនីមួយៗក្នុងចំណោមភាគីទំនាស់
- ដើម្បីរិះរកនូវចំណុចចាប់ផ្តើមដើម្បីធ្វើអន្តរាគមន៍

## ២.១.៣. របៀបប្រើប្រាស់ឧបករណ៍

ក្នុងការប្រើប្រាស់ឧបករណ៍ត្រីកោណ ប.ទ.ច ដើម្បីវិភាគទំនាស់ អ្នកប្រើប្រាស់ត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- កំណត់នូវស្ថានការណ៍អវិជ្ជមាន ឬបញ្ហា ឬទំនាស់ណាមួយឱ្យច្បាស់ដើម្បីយកមកធ្វើការវិភាគ
- **បង្កើតត្រីកោណ ប.ទ.ច :** ត្រូវបង្កើតត្រីកោណ ប.ទ.ច សម្រាប់ភាគីនីមួយៗ ក្នុងចំណោមភាគីទាំងអស់នៃទំនាស់។
- បន្ទាប់ពីគូរត្រីកោណរួច អ្នកត្រូវកំណត់ ឬធ្វើបញ្ជីដែលទាក់ទងទៅនឹង បរិបទ ចិត្ត/ការគិត និងទង្វើ ឬការប្រព្រឹត្ត ដែលចេញពីទស្សនៈនៃភាគីនីមួយៗ។
  - **បរិបទ :** គឺជាបរិបទ ឬស្ថានភាពរបស់ភាគីទំនាស់ដែលយកមកវិភាគ
  - **ចិត្ត ឬគំនិត :** គឺជាការគិត ឬការយល់ឃើញរបស់ភាគីទំនាស់ដែលយកមកវិភាគទៅលើភាគីម្ខាងទៀត។
  - **ទង្វើ ឬការប្រព្រឹត្ត :** គឺជាសកម្មភាពរបស់ភាគីទំនាស់ដែលយកមកវិភាគបានធ្វើឡើង។
- បន្ទាប់ពីបង្កើតត្រីកោណ "ប.ទ.ច" សម្រាប់ភាគីនីមួយៗរួច ត្រូវពិនិត្យមើលអំពីបរិបទ ចិត្ត និងទង្វើរបស់ភាគីនីមួយៗ ហើយកំណត់អំពីចំណុចដែលត្រូវដោះស្រាយ។

**ឧទាហរណ៍ :** យុវជន **ច័ន្ទ** និងកញ្ញា **សុរិយា** បានស្រឡាញ់គ្នា ហើយឈានដល់ការរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ២០០២។ បន្ទាប់ពីរៀបការហើយ គូស្វាមីភរិយាថ្មីនេះបានសម្រេចចិត្តមករស់នៅជាមួយក្រុមគ្រួសារខាងប្រុស។ ដល់ដើមឆ្នាំ២០០៤ ដោយជីវភាពមានការខ្វះខាត **ច័ន្ទ** និង **សុរិយា** ចាប់ផ្តើមមានទំនាស់ជាមួយគ្នាបន្តិចបន្តួច។ លើសពីនេះទៀត ម្តាយច័ន្ទដែលតែងតែពិសាស្រាជាប្រចាំបានរអ៊ូរទាំ និយាយដៀមដាម **សុរិយា** ដែលជាកូនប្រសារ។ ដោយខឹងនឹងម្តាយក្មេក **សុរិយា** បានទៅពិភាក្សាជាមួយម្តាយបង្កើតរបស់ខ្លួន ជាមួយគ្នានោះម្តាយសុរិយាបានបង្ហាញនូវការសោកស្តាយដែលបានរៀបការកូនស្រីដ៏ស្រស់សោភារបស់ខ្លួនឱ្យទៅ **ច័ន្ទ** ដែលជាបុរសមិនសង្ហា និងមិនសូវពូកែរកស៊ីផង។ ម្តាយសុរិយាបានគាំទ្រឱ្យសុរិយាលែងលះជាមួយច័ន្ទ។ ពេលខ្លះ **សុរិយា** បាននិយាយរឿងរ៉ាវដែលម្តាយក្មេកតែងតែនិយាយរអ៊ូរទាំ និងដៀមដាមដាក់នាងប្រាប់ប្តីនៅពេលប្តីត្រឡប់មកពីធ្វើស្រែវិញ។ ដោយមានការហត់នឿយមកពីស្រែផង ពេលមកដល់ផ្ទះសុរិយានិយាយមិនល្អអំពីម្តាយខ្លួនផង **ច័ន្ទ** បានស្តីបន្ទោស **សុរិយា** យ៉ាងខ្លាំង ព្រមទាំងមានការវាយដំបន្តិចបន្តួចទៀតផង។ ពេលទទួលរងការស្តីបន្ទោស និងវាយដំ **សុរិយា** តែងតែទៅពឹងអ្នកជិតខាងឱ្យជួយ។ ទោះជាមានអន្តរាគមន៍ពីមេភូមិក៏ដោយ ក៏ទំនាស់រវាង **ច័ន្ទ** និង**សុរិយា** មិនអាចបញ្ឈប់បានដែរ។ ដល់ឆ្នាំ២០០៥ ដោយមានការគាំទ្រពីម្តាយ ទំនាស់រវាង **សុរិយា** និង **ច័ន្ទ** បានរីករាលដាលយ៉ាងខ្លាំងរហូតដល់មានការលក់ទ្រព្យសម្បត្តិចែកគ្នា ហើយបានសម្រេចចិត្តប្តឹងមកមេឃុំដើម្បីលែងលះគ្នា។ ដោយមានការសម្រុះសម្រួលពីក្រុមប្រឹក្សាឃុំជាច្រើនលើក ទើបក្នុងឆ្នាំ២០០៦ **ច័ន្ទ** និង **សុរិយា** សម្រេចចិត្តរួមរស់ជាមួយគ្នាវិញ ដោយសាងសង់ផ្ទះសម្រាប់រស់នៅដោយឡែកពីម្តាយទាំងសងខាង។

## ការវិភាគទំនាស់ក្នុងគ្រួសារ (ច័ន្ទ និងសុរិយា) ដោយប្រើឧបករណ៍ត្រីកោណ“ប.ទ.ច”

ការវិភាគ “ភាគីច័ន្ទ”

**បរិបទ**

- មានផ្ទះសម្រាប់ឱ្យប្រពន្ធរស់នៅ
- មានតួនាទីជាប្ដី
- មានការនឿយហត់ខ្លាំង
- មានម្ដាយបង្កើតគាំទ្រ




**ឥរិយាបថ/ការប្រព្រឹត្ត**

- ស្ដីបន្ទោសសុរិយា
- វាយដំបន្តិចបន្តួច
- បែងចែកទ្រព្យសម្បត្តិ
- សម្រេចចិត្តលែងលះ

**ចិត្ត/គំនិត**

- សុរិយាមិនបានជួយធ្វើការងារ
- សុរិយាជាអ្នកបង្ករឿង
- សុរិយាមិនដែលនិយាយល្អអំពីម្ដាយខ្លួន

ការវិភាគ “ភាគីសុរិយា”

**បរិបទ**

- មករស់នៅផ្ទះខាងប្ដី
- មានម្ដាយបង្កើតគាំទ្រ
- មានប្ដីជាអ្នកធ្វើស្រែ
- មានរូបសម្រស់ស្រស់ស្អាត




**ឥរិយាបថ/ការប្រព្រឹត្ត**

- និយាយរឿងរ៉ាវប្រាប់ប្ដីដើម្បីឱ្យប្ដីជួយ
- និយាយរឿងរ៉ាវប្រាប់ម្ដាយបង្កើតរបស់ខ្លួន
- ពឹងពាក់អ្នកជិតខាងឱ្យជួយ
- លក់ទ្រព្យសម្បត្តិចែកគ្នា
- ប្ដឹងទៅមេឃុំដើម្បីលែងលះ

**ចិត្ត/គំនិត**

- ម្ដាយក្មេកមើលងាយ
- ប្ដីមិនគាំទ្រខ្លួន និងជួយដោះស្រាយ
- ប្ដីមិនយកចិត្តទុកដាក់លើខ្លួន
- ប្ដីកាន់ជើងម្ដាយបង្កើតរបស់គេ

តាមរយៈការវិភាគដោយប្រើឧបករណ៍ត្រីកោណ ប.ទ.ច ឃើញថា ភាគីច័ន្ទ និងភាគីសុរិយា ស្ថិតក្នុងបរិបទផ្សេងគ្នា មានការយល់ឃើញខុសគ្នា ដែលនាំឱ្យមានទង្វើខុសគ្នា។ ដូច្នេះចំណុចសំខាន់ អ្នកសម្រុះសម្រួលត្រូវធ្វើការសម្រុះសម្រួលឱ្យភាគីទាំងពីរមានការយល់ឃើញរួមគ្នា។

## ២.២. ផែនទីទំនាស់

### ២.២.១. និយមន័យ

ផែនទីទំនាស់ជាឧបករណ៍វិភាគទំនាស់ ដែលបង្ហាញអំពីទំនាក់ទំនងរវាងភាគីទាំងអស់នៅក្នុងទំនាស់ជាក្រាហ្វិក ដូចជា ភាគីដែលមានទំនាស់នឹងគ្នា ភាគីដែលមានសម្ព័ន្ធមិត្តជាមួយគ្នា ភាគីដែលមានឥទ្ធិពលដោយប្រយោលលើទំនាស់ និងភាគីដែលមានទំនាក់ទំនងមិនផ្លូវការជាមួយភាគីណាមួយក្នុងទំនាស់ ឬការបែកបាក់ទំនាក់ទំនងជាដើម ។

### ២.២.២. គោលបំណង

អ្នកសម្រុះសម្រួលទំនាស់ ឬអ្នកដោះស្រាយទំនាស់ប្រើប្រាស់ឧបករណ៍ផែនទីទំនាស់ ក្នុងគោលបំណងដើម្បី ៖

- កំណត់អ្នកពាក់ព័ន្ធទាំងអស់ក្នុងទំនាស់
- កំណត់អំពីទំនាក់ទំនងរវាងភាគី និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងទំនាស់
- រកមើលច្រកចេញ ឬយុទ្ធសាស្ត្រថ្មីៗក្នុងការសម្រុះសម្រួល

### ២.២.៣. របៀបប្រើប្រាស់ឧបករណ៍

ក្នុងដំណាក់កាលដំបូងនៃការវិភាគទំនាស់ គេអាចប្រើប្រាស់ផែនទីជាឧបករណ៍វិភាគទំនាស់ ឬគេអាចប្រើប្រាស់ឧបករណ៍នេះសម្រាប់កំណត់លទ្ធភាពនៃដំណោះស្រាយ ឬជួយដំណើរការនៃការកសាងយុទ្ធសាស្ត្រនៃដំណោះស្រាយ ។

ប្រសិនបើភាគីទាំងអស់នៃទំនាស់ចូលរួមធ្វើផែនទីលើស្ថានភាពរបស់ពួកគេរួមគ្នា ពួកគេនឹងបានរៀនសូត្រពីបទពិសោធន៍ និងការយល់ដឹងច្រើនពីគ្នាទៅវិញទៅមក ពួកគេកាន់តែខិតចូលជិតគ្នាទៀត ហើយអាចនឹងមានគំនិតស្របគ្នាចំពោះស្ថានភាពតែមួយដែលពួកគេកំពុងស្ថិតនៅ ។

**ក). និម្មិតសញ្ញា**

នៅក្នុងផែនទី យើងអាចប្រើនិម្មិតសញ្ញាពិសេសផ្សេងៗ ។ ខាងក្រោមនេះជានិម្មិតសញ្ញាមួយចំនួន ដែលគេនិយមប្រើ ៖



- រង្វង់មូលតំណាងឱ្យអ្នកពាក់ព័ន្ធនឹងទំនាស់
- ទំហំរង្វង់បង្ហាញអំពីទំហំនៃអំណាចរបស់អ្នកពាក់ព័ន្ធក្នុងទំនាស់



- ខ្សែត្រង់បង្ហាញអំពីតំណ ដែលតភ្ជាប់នូវទំនាក់ទំនងជាអចិន្ត្រៃយ៍រវាងភាគីទំនាស់



- ខ្សែគូដែលតភ្ជាប់បង្ហាញអំពីមិត្តភាព ឬសម្ព័ន្ធមិត្ត



- ខ្សែចុចៗ បង្ហាញអំពីទំនាក់ទំនងមិនផ្លូវការ ឬមិនជានិច្ចកាល



- ខ្សែសញ្ញាព្រួញបង្ហាញអំពីទិសដៅសកម្មភាព និងឥទ្ធិពលរបស់ភាគីម្ខាងលើភាគីម្ខាងទៀត



- ខ្សែរាងអង្កាញ់ៗ បង្ហាញអំពីភាពមិនចុះសម្រុង ឬទំនាស់រវាងភាគីទំនាស់



- ខ្សែដែលមានគំនូសកាត់ទទឹងពីរ បង្ហាញអំពីទំនាក់ទំនងដែលបានបែកបាក់



- សញ្ញាប្រអប់បួនជ្រុងរាងទ្រវែង បង្ហាញអំពីបញ្ហា ឬប្រធានបទ ឬអ្វីមួយផ្សេងទៀតដែលមិនមែនជាមនុស្ស



- សញ្ញាខ្សែស្នាមចុចៗ បង្ហាញអំពីភាគីខាងក្រៅដែលមានឥទ្ធិពល ប៉ុន្តែមិនចូលរួមក្នុងទំនាស់ទេ។

## ខ). ការបង្កើតផែនទីទំនាស់

ដើម្បីរៀបចំផែនទីអំពីស្ថានភាពនៃទំនាស់មួយ អ្នកវិភាគ ឬអ្នកដោះស្រាយត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- កំណត់នូវស្ថានការណ៍អវិជ្ជមាន ឬបញ្ហា ឬទំនាស់ណាមួយឱ្យច្បាស់ដើម្បីយកមកធ្វើការវិភាគ
- កំណត់អំពីអ្នកពាក់ព័ន្ធ និងទំនាក់ទំនងរបស់ពួកគេ : ត្រូវកំណត់អំពីភាគីទំនាស់ និងអ្នកពាក់ព័ន្ធទាំងអស់។ បន្ទាប់ពីកំណត់អ្នកពាក់ព័ន្ធទាំងនោះហើយ ត្រូវកំណត់អំពីទំនាក់ទំនងរបស់ពួកគេ ដូចជា មានទំនាក់ទំនងល្អ សម្ព័ន្ធមិត្ត ទំនាក់ទំនងមិនផ្លូវការ ឬទំនាក់ទំនងរបស់ពួកគេត្រូវកាត់ផ្តាច់ជាដើម។
- គូរផែនទីទំនាស់ : ត្រូវគូរផែនទីទំនាស់ដោយបញ្ចូលនូវរាល់ភាគីពាក់ព័ន្ធ និងទំនាក់ទំនងរបស់ពួកគេជាមួយភាគីទំនាស់ដោយប្រើនិម្មិតសញ្ញា។
- ពិនិត្យរកជម្រើស និងចំណុចចាប់ផ្តើមនៃដំណោះស្រាយ : បន្ទាប់ពីគូរផែនទីទំនាស់រួច អ្នកត្រូវពិនិត្យមើលអំពីចំណុចដែលត្រូវចាប់ផ្តើមដោះស្រាយ និងជម្រើសនៃដំណោះស្រាយនានា។

**ឧទាហរណ៍ : ការវិភាគទំនាស់ក្នុងគ្រួសារ (ច័ន្ទ និងសុរិយា) ដោយប្រើឧបករណ៍ផែនទីទំនាស់**




តាមរយៈការវិភាគទំនាស់ដោយប្រើឧបករណ៍ផែនទីទំនាស់ឃើញថា ទាំងភាគីច័ន្ទ និងភាគីសុរិយា សុទ្ធតែមានម្តាយបង្កើតគាំទ្ររៀងៗខ្លួន។ ដូច្នេះ អ្នកសម្រុះសម្រួលអាចពិចារណា និងផ្តល់អន្តរាគមន៍ជាមួយម្តាយទាំងសងខាង ដោយធ្វើយ៉ាងណាឱ្យម្តាយបង្កើតទាំងសងខាងមានឆន្ទៈក្នុងការជំរុញឱ្យកូនរួមរស់ជាមួយគ្នាវិញ។

## ២.៣. ចន្ទល់នៃបញ្ហា

### ២.៣.១. និយមន័យ

ចន្ទល់នៃបញ្ហា គឺជាឧបករណ៍មួយដែលបង្ហាញអំពីសមាសធាតុ ឬកម្លាំងដែលជួយ "ទល់ទ្រ" ស្ថានការណ៍មួយដែលមិននឹងនឱ្យនៅនឹងមួយកន្លែងបាន។ ឧបករណ៍ចន្ទល់នៃបញ្ហាត្រូវបង្កើតឡើងដោយផ្អែកលើការសន្មតថាស្ថានការណ៍មួយមានលក្ខណៈមិននឹងន ប៉ុន្តែវាត្រូវបាន "ទល់ទ្រ" ដោយកត្តា ឬកម្លាំងជាច្រើនដែលជា "ចន្ទល់"។ ប្រសិនបើយើងអាចរកឃើញនូវចន្ទល់ទាំងនោះ យើងនឹងអាចរិះរកមធ្យោបាយដើម្បីកាត់បន្ថយឥទ្ធិពលរបស់វា ឬក៏ដកចន្ទល់ទាំងនោះចេញ។ ប្រសិនបើយើងអាចដកចន្ទល់ទាំងនោះចេញ នោះស្ថានការណ៍អវិជ្ជមាន ឬបញ្ហានៃទំនាស់នឹងត្រូវដួលរលំ ឬបញ្ចប់ ហើយត្រូវបានជំនួសមកវិញនូវស្ថានការណ៍មួយដែលវិជ្ជមាន និងល្អប្រសើរ។

### ២.៣.២. គោលបំណង

អ្នកដោះស្រាយទំនាស់ប្រើប្រាស់ឧបករណ៍ "ចន្ទល់នៃបញ្ហា" ក្នុងគោលបំណង :

- កំណត់នូវកត្តាទាំងឡាយដែលនាំឱ្យមានទំនាស់
- ពិចារណារកមធ្យោបាយផ្សេងៗសម្រាប់ធ្វើឱ្យចន្ទល់ចុះខ្សោយ ឬដកចន្ទល់ទាំងនោះចេញ

### ២.៣.៣. របៀបប្រើប្រាស់ឧបករណ៍

ក្នុងការប្រើប្រាស់ឧបករណ៍ចន្ទល់នៃបញ្ហា អ្នកវិភាគ ឬអ្នកដោះស្រាយត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- កំណត់នូវស្ថានការណ៍អវិជ្ជមាន ឬបញ្ហា ឬទំនាស់ណាមួយឱ្យច្បាស់ដើម្បីយកមកធ្វើការវិភាគ
- គូសត្រីកោណបញ្ច្រាស់មួយ ដោយដាក់កំពូលចុះក្រោម
- សរសេរបញ្ហា ឬស្ថានការណ៍អវិជ្ជមានដែលចង់ដោះស្រាយនៅចំកណ្ដាលត្រីកោណនោះ
- ពិនិត្យរកមើលកម្លាំង ឬកត្តាទាំងឡាយដែលនាំឱ្យកើតមានបញ្ហា ឬស្ថានការណ៍អវិជ្ជមាននោះ
- គូសបង្ហាញកម្លាំង ឬកត្តាទាំងនោះជាចន្ទល់ទ្រទ្រង់បញ្ហា ឬស្ថានការណ៍នោះនៅសងខាងត្រីកោណ ដែលទប់ត្រីកោណបញ្ច្រាស់នេះឱ្យនៅនឹងមួយកន្លែងបាន (មើលឧទាហរណ៍)
- ពិចារណារកមើលពីមធ្យោបាយនានាដើម្បីឱ្យចន្ទល់នីមួយៗចុះខ្សោយ ឬដកចន្ទល់នីមួយៗនោះចេញ

**ឧទាហរណ៍ : ការវិភាគទំនាស់ក្នុងគ្រួសារ (ច័ន្ទ និងសុរិយា) ដោយប្រើឧបករណ៍ចន្ទល់នៃបញ្ហា**




តាមរយៈការវិភាគទំនាស់ដោយប្រើឧបករណ៍ចន្ទល់នៃបញ្ហាឃើញថា មានកត្តាជាច្រើនដែលនាំឱ្យកើតមានទំនាស់រវាងច័ន្ទ និងសុរិយា។ ដូច្នេះអ្នកសម្រុះសម្រួលត្រូវពិចារណាកាត់ ឬដកចន្ទល់ទាំងនោះចេញ។

## ២.៤. ខ្សែពេលវេលា

### ២.៤.១. និយមន័យ

ខ្សែពេលវេលា គឺជាគំនូសតាងដែលរៀបរាប់ ឬបង្ហាញអំពីព្រឹត្តិការណ៍សំខាន់ៗកើតឡើងក្នុងពេលវេលាពិសេសណាមួយដែលយើងចង់ធ្វើការវិភាគ។ ការប្រើប្រាស់ឧបករណ៍ខ្សែពេលវេលា នឹងជួយដល់អ្នកវិភាគរកឃើញនូវទង្វើ ឬសកម្មភាពនានារបស់ភាគីនីមួយៗដែលបានធ្វើទៅតាមពេលវេលាកំណត់ជាក់លាក់នីមួយៗ។

### ២.៤.២. គោលបំណង

អ្នកដោះស្រាយទំនាស់ប្រើប្រាស់ឧបករណ៍ "ខ្សែពេលវេលា" ក្នុងគោលបំណង :

- បង្ហាញនូវទស្សនៈ ឬទង្វើផ្សេងៗរបស់ភាគីនីមួយៗក្នុងទំនាស់តាមពេលវេលាជាក់លាក់
- កំណត់ព្រឹត្តិការណ៍ដែលសំខាន់បំផុតសម្រាប់ភាគីនីមួយៗ

## ២.៤.៣. របៀបប្រើប្រាស់ឧបករណ៍

ខ្សែពេលវេលា គឺជាឧបករណ៍ដ៏សាមញ្ញបំផុត។ វាជាក្រាហ្វិកមួយបង្ហាញពីពេលវេលានៃព្រឹត្តិការណ៍សំខាន់ៗ កើតឡើងក្នុងស្ថានភាពមួយ។ ឧបករណ៍នេះបានកត់ត្រានូវពេលវេលា និងព្រឹត្តិការណ៍នានា ដែលកើតឡើងទៅតាមពេលវេលាកំណត់នីមួយៗនោះ។

ក្នុងការប្រើប្រាស់ឧបករណ៍ខ្សែពេលវេលា អ្នកវិភាគ ឬអ្នកដោះស្រាយត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- កំណត់នូវស្ថានការណ៍អវិជ្ជមាន ឬបញ្ហា ឬទំនាស់ជាមួយឱ្យច្បាស់ដើម្បីយកមកធ្វើការវិភាគ
- កំណត់ព្រឹត្តិការណ៍សំខាន់ៗដែលកើតមានរវាងភាគីទំនាស់
- កំណត់កាលបរិច្ឆេទ ឬពេលវេលានៃព្រឹត្តិការណ៍នីមួយៗនោះ
- កំណត់អំពីទស្សនៈ ឬទង្វើរបស់ភាគីនីមួយៗទៅតាមកាលបរិច្ឆេទ
- ពិចារណារកមើលពីមធ្យោបាយនានាដើម្បីដោះស្រាយ ឬសម្រុះសម្រួលទំនាស់ទាំងនោះ

**ឧទាហរណ៍ : ការវិភាគទំនាស់នៅក្នុងគ្រួសារ (ច័ន្ទ និងសុរិយា) ដោយប្រើឧបករណ៍ "ខ្សែពេលវេលា"**

| ភាគីច័ន្ទ | កាលបរិច្ឆេទ | ភាគីសុរិយា |
|---|---|---|
| - មានទំនាក់ទំនងស្នេហាជាមួយសុរិយា<br>- សម្រេចចិត្តរៀបការជាមួយសុរិយា | ២០០២ | - មានទំនាក់ទំនងស្នេហាជាមួយច័ន្ទ<br>- សម្រេចចិត្តរៀបការជាមួយច័ន្ទ |
| - មានទំនាស់បន្តិចបន្តួចជាមួយសុរិយា<br>- ម្ដាយច័ន្ទពិសាស្រា<br>- ម្ដាយច័ន្ទនិយាយរអ៊ូរទាំ និងជេរម្រដាម<br>- ស្ដីបន្ទោសប្រពន្ធ និងវាយដំបន្តិចបន្តួច | ២០០៤ | - និយាយរឿងរ៉ាវប្រាប់ម្ដាយ<br>- ម្ដាយបង្ហាញនូវការមិនពេញចិត្តចំពោះច័ន្ទ<br>- ម្ដាយគាំទ្រឱ្យលែងលះ<br>- និយាយប្រាប់ប្ដីអំពីម្ដាយក្មេកដែលតែងតែនិយាយរអ៊ូរទាំ និងជេរម្រដាម<br>- រត់ទៅពឹងអ្នកជិតខាង |
| - មិនទទួលយកការសម្រុះសម្រួលរបស់មេភូមិ<br>- លក់ទ្រព្យសម្បត្តិចែកគ្នា<br>- សម្រេចចិត្តប្ដឹងទៅមេឃុំដើម្បីសុំលែងលះ | ២០០៥ | - មិនទទួលយកការសម្រុះសម្រួលរបស់មេភូមិ<br>- លក់ទ្រព្យសម្បត្តិចែកគ្នា<br>- សម្រេចចិត្តប្ដឹងទៅមេឃុំដើម្បីសុំលែងលះ |
| - សម្រេចចិត្តរួមរស់ជាមួយគ្នាវិញ<br>- សង់ផ្ទះដើម្បីរស់នៅដោយឡែក | ២០០៦ | - សម្រេចចិត្តរួមរស់ជាមួយគ្នាវិញ<br>- សង់ផ្ទះដើម្បីរស់នៅដោយឡែក |

តាមរយៈការវិភាគទំនាស់ដោយប្រើឧបករណ៍ខ្សែពេលវេលាឃើញថា ភាគីភាគីទំនាស់ទាំងពីរមានបទពិសោធន៍ក្នុងជីវិតជាមួយគ្នា តាំងពីការមានទំនាក់ទំនងស្នេហាជាមួយគ្នា រហូតដល់មានការឈ្លោះប្រកែកគ្នា និងប្ដឹងសុំលែងលះ។

ជាចំណុចចាប់ផ្តើមនៃការសម្រុះសម្រួល អ្នកសម្រុះសម្រួលអាចទាញ ឬបង្ហាញអំពីអនុស្សាវរីយ៍ល្អៗនានា ដែលភាគីទាំងពីរបានសាងជាមួយគ្នា ដើម្បីឱ្យភាគីទំនាស់ឆ្លុះបញ្ចាំងអំពីអនុស្សាវរីយ៍ទាំងនោះ មុននឹងឈានទៅរកការសម្រុះសម្រួល និងការសម្រេចចិត្តចុងក្រោយ ។

## ២.៥. ការវិភាគតាមដំណាក់កាលនៃទំនាស់

ការវិភាគតាមដំណាក់កាលទំនាស់ គឺជាឧបករណ៍វិភាគទំនាស់មួយដែលជួយឱ្យអ្នកវិភាគ ឬអ្នកដោះស្រាយទំនាស់ដឹងអំពីស្ថានភាពកម្លាំងនៃទំនាស់ ឬដំណាក់កាលនៃទំនាស់ដែលកំពុងវិភាគ ។

ដំណាក់កាលនៃទំនាស់រួមមានដូចខាងក្រោម :

- មុនទំនាស់
- ការប្រឈម
- វិបត្តិ
- លទ្ធផល
- ក្រោយទំនាស់

### ២.៥.១. មុនទំនាស់

មុនទំនាស់អាចស្តែងចេញនូវសកម្មភាពមួយចំនួនដូចជា :



- ភាពផ្សេងគ្នា : មានការយល់ឃើញផ្សេងគ្នា អាចជាផលល្អប្រសិនបើការពិភាក្សានោះមានការអត់ធ្មត់គ្រប់គ្រាន់ ប៉ុន្តែប្រសិនបើមិនមានការអត់ធ្មត់ទេ នោះវានឹងឈានដល់ការប្រឈមមុខគ្នា ។
- ភាពតានតឹង : ភាគីនីមួយៗគិតអំពីជំហររបស់ខ្លួន ហើយគិតរិះគន់ភាគីម្ខាងទៀត ។ លើសពីនេះទៀតពួកគេចាប់ផ្តើមគិតថា ភាគីម្ខាងទៀតជាសត្រូវរបស់ខ្លួន ។

### ២.៥.២. ការប្រឈម

ការប្រឈមអាចស្តែងចេញនូវសកម្មភាពមួយចំនួនដូចជា :



- ភាគីនីមួយៗមិនទទួលស្គាល់ថា ខ្លួនមានកំហុស
- ការបង្ហាញ និងការពារជំហររបស់ខ្លួន
- មានការគំរាមកំហែង
- ក្រុមគាំទ្រភាគីនីមួយៗចាប់ផ្តើមបង្ហាញនូវឥរិយាបថគាំទ្រ
- មានការវាយតប់គ្នាម្តងម្កាល
- ប្រមូលធនធាន និងបង្កើតបក្សពួក

- មានការចំអក ដៀមដាម ប្រមាថមាក់ងាយដល់ភាគីទំនាស់ម្ខាងទៀត
- បញ្ចប់ការពិភាក្សា ឬចរចា

## ២.៥.៣. វិបត្តិ

ដំណាក់កាលវិបត្តិអាចស្តែងចេញនូវសកម្មភាពមួយចំនួនដូចជា :



- កើតមានអំពើហិង្សារវាងភាគីទាំងពីរតាមរូបភាពផ្សេងៗ
- ការប្រយុទ្ធ ឬប្រកួតប្រជែងគ្នារហូតដល់ភាគីណាមួយ "ឈ្នះ" ហើយភាគីផ្សេងទៀតចុះចាញ់
- ភាគីនីមួយៗនៃទំនាស់គិតថា ភាគីម្ខាងទៀតត្រូវតែចាញ់

## ២.៥.៤. លទ្ធផល

ដំណាក់កាលលទ្ធផលអាចស្តែងចេញនូវសកម្មភាពមួយចំនួនដូចជា :



- មានភាគីមួយឈ្នះ និងភាគីមួយទៀតចាញ់
- ភាគីទាំងពីរអស់ថាមពលរៀងៗខ្លួន
- អាចមានការចរចាគ្នា
- អ្នកខាងក្រៅអាចមានអន្តរាគមន៍នានា

## ២.៥.៥. ក្រោយទំនាស់

ដំណាក់កាលក្រោយទំនាស់អាចស្តែងចេញនូវសកម្មភាពមួយចំនួនដូចជា :



- បញ្ចប់អំពើហិង្សា
- បន្ថយនូវភាពតានតឹង
- ភាគីទំនាស់ឯកភាពក្នុងការស្វែងរកដំណោះស្រាយដូចជា ការចរចា ឬការសម្រុះសម្រួលជាដើម
- ភាគីទំនាស់ឯកភាពអំពីជម្រើសនៃដំណោះស្រាយ និងអនុវត្តដំណោះស្រាយ
- ភាគីទំនាស់ចាប់ផ្តើមយល់អំពីគ្នា និងគោរពគ្នាទៅវិញទៅមក
- ភាគីនីមួយៗរក្សានូវការយល់ឃើញផ្សេងគ្នា ប៉ុន្តែទទួលយកការយល់ឃើញរបស់អ្នកដទៃ
- អាចនាំឱ្យមានការប្រឈមមុខគ្នាឡើងវិញម្តងទៀត

ដូច្នេះ ក្នុងការវិភាគទំនាស់ដោយប្រើឧបករណ៍ "ដំណាក់កាលទំនាស់" អ្នកវិភាគត្រូវកំណត់នូវទង្វើ ឬសកម្មភាពនានាដែលកើតឡើងនៅក្នុងដំណាក់កាលនីមួយៗ។

**ឧទាហរណ៍ : ការវិភាគទំនាស់ក្នុងគ្រួសារ (ច័ន្ទ និងសុរិយា) ដោយប្រើឧបករណ៍ដំណាក់កាលទំនាស់**




| (១).មុនទំនាស់ | (២).ប្រឈមមុខ | (៣).វិបត្តិ | (៤).លទ្ធផល | (៥).ក្រោយទំនាស់ |
|---|---|---|---|---|
| - មានជីវភាពខ្វះខាត<br>- ប្រកបរបរធ្វើស្រែ<br>- ម្ដាយសុរិយាមិនសូវពេញចិត្តនឹងច័ន្ទ | - ច័ន្ទ និងសុរិយាមានទំនាស់បន្តិចបន្តួច<br>- ម្ដាយច័ន្ទពិសាស្រានិយាយរអ៊ូរទាំ និងដៀមដាម<br>- ម្ដាយសុរិយាគាំទ្រឱ្យលែងលះគ្នា | - ច័ន្ទស្តីបន្ទោសសុរិយា<br>- ច័ន្ទវាយដំសុរិយា | - សុរិយារត់ទៅពឹងអ្នកជិតខាងឱ្យជួយ<br>- លក់ទ្រព្យសម្បត្តិចែកគ្នា<br>- ប្តឹងទៅមេឃុំដើម្បីសុំលែងលះគ្នា | - ប្តីប្រពន្ធស្រុះស្រួលគ្នាវិញ<br>- សាងសង់ផ្ទះសម្រាប់រស់នៅតែពីរនាក់ប្តីប្រពន្ធ |

ក្រៅពីឧបករណ៍វិភាគទំនាស់ដែលបានបរិយាយខាងលើនេះ អាចមានឧបករណ៍វិភាគទំនាស់ផ្សេងៗទៀតជាច្រើនដូចជាការវិភាគតាមដើមឈើនៃបញ្ហាជាដើម ។

# ផ្នែកទី៣
# វិធីសាស្ត្រដោះស្រាយទំនាស់

# ផ្នែកទី៣
# វិធីសាស្ត្រដោះស្រាយទំនាស់

ជាការពិតទំនាស់អាចផ្ដល់ផលវិជ្ជមាន ដោយធ្វើឱ្យមានការបំផុសគំនិតថ្មីៗ ឬវិធីសាស្ត្រថ្មីៗជាដើម ប៉ុន្តែទំនាស់ក៏អាចផ្ដល់ផលអវិជ្ជមានផងដែរដូចជា អំពើហិង្សា ឬជាការរំលោភបំពាននានា ដែលបញ្ហានេះតម្រូវឱ្យមានដំណោះស្រាយប្រកបដោយយុត្តិធម៌ ។ ប្រសិនបើមិនដោះស្រាយទំនាស់ឱ្យបានឆាប់ និងមានប្រសិទ្ធភាពទេ នោះវានឹងអាចឈានទៅដល់ការប្រើអំពើហិង្សា និងមានទម្រង់ផ្សេងៗទៀតនៃភាពអន្តរាយ ។

ការដោះស្រាយទំនាស់បានល្អអាចជួយ :

- ជៀសវាង និងទប់ស្កាត់នូវអំពើហិង្សា និងការរំលោភបំពាននានា
- ឱ្យមានការផ្លាស់ប្ដូរ និងផ្ដល់នូវភាពយុត្តិធម៌ដល់ភាគីទំនាស់ និងអ្នកពាក់ព័ន្ធ
- កាត់បន្ថយនូវភាពតានតឹង និងទប់ស្កាត់ការកើនឡើងនូវភាពតានតឹង
- រក្សាការទំនាក់ទំនងចុះសម្រុងគ្នាដែលធ្លាប់មានជាយូរមកហើយរបស់ភាគីទំនាស់

## ៣.១. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រដោះស្រាយទំនាស់រួមមាន :

- **ការទប់ស្កាត់ :** គឺជាការការពារមិនឱ្យកើតមានសកម្មភាពទំនាស់ ឬសកម្មភាពហិង្សានានា ។
- **ការផ្សះផ្សា :** គឺជាការបញ្ចប់ទំនាស់ ឬបញ្ចប់ហិង្សា ហើយឈានដល់ការព្រមព្រៀងដោយសន្តិវិធី ។
- **ការគ្រប់គ្រង :** ជាការជំរុញឱ្យមានការផ្លាស់ប្ដូរជាវិជ្ជមាននូវអាកប្បកិរិយារបស់ភាគីនានាក្នុងទំនាស់ ដើម្បីចៀសវាងទំនាស់ ឬហិង្សានាពេលអនាគត ។
- **ការដោះស្រាយ :** ជាការឆ្លើយតបទៅនឹងមូលហេតុនៃទំនាស់ ដើម្បីបញ្ចប់ទំនាស់រវាងភាគីទំនាស់ ហើយស្វែងរកការកសាងទំនាក់ទំនងថ្មីមួយដែលមានភាពយូរអង្វែងរវាងភាគីទំនាស់ ។

ប្រភេទនៃទំនាស់រួមមាន ទំនាស់បង្កប់ ទំនាស់ស្ដែងចេញភ្លាមៗ និងទំនាស់ចំហ ដូច្នេះក្នុងការទប់ស្កាត់ ផ្សះផ្សា គ្រប់គ្រង និងដោះស្រាយទំនាស់ត្រូវឆ្លើយតបទៅតាមប្រភេទនៃទំនាស់ទាំងអស់នោះ ។

តារាងខាងក្រោមបង្ហាញអំពីយុទ្ធសាស្ត្រក្នុងការឆ្លើយតបទៅនឹងទំនាស់តាមប្រភេទនីមួយៗ :

| យុទ្ធសាស្ត្រ | ទំនាស់បង្កប់ | ទំនាស់ស្ដែងចេញភ្លាមៗ | ទំនាស់ចំហ |
|---|---|---|---|
| ការទប់ស្កាត់ | ✓ | | |
| ការផ្សះផ្សា | | ✓ | ✓ |
| ការគ្រប់គ្រង | ✓ | ✓ | |
| ការដោះស្រាយ | | | ✓ |

## ៣.២. វិធីសាស្ត្រដោះស្រាយទំនាស់

ជាទូទៅ ការដោះស្រាយទំនាស់មានច្រើនរបៀប ក្នុងនោះមានបួនរបៀបដែលគេនិយមប្រើជាងគេ។ របៀបទាំងបួននោះរួមមានដូចខាងក្រោម :

- ការចរចា
- ការសម្រុះសម្រួល
- អាជ្ញាកណ្តាល ឬមជ្ឈត្តការ
- ការកាត់សេចក្តីតាមប្រព័ន្ធតុលាការ

### ៣.២.១. ការចរចា

#### ក). និយមន័យ



ការចរចា គឺជាដំណើរការពិភាក្សារវាងភាគីទំនាស់ទាំងសងខាង ដែលភាគីទាំងពីរត្រូវធ្វើការរួមគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នា ដោយមិនមានជំនួយពីភាគីទី៣។ ការចរចាអាចប្រព្រឹត្តទៅបានក្នុងករណីដែលទំនាក់ទំនងរវាងភាគីទំនាស់មិនទាន់ប្រេះឆាខ្លាំងនៅឡើយ ឬក្នុងដំណាក់កាលដែលគូភាគីមានបំណងចង់ដោះស្រាយបញ្ហាទំនាស់របស់ពួកគេ។

#### ខ). គុណសម្បត្តិ និងគុណវិបត្តិនៃការចរចា

- **គុណសម្បត្តិ**
  - មិនចំណាយច្រើន : ថ្លៃចំណាយសម្រាប់ការចរចាស្ទើរតែមិនមាន ព្រោះការចរចាមិនចាំបាច់ត្រូវការភាគីទី៣។
  - សាមញ្ញ : ការចរចាមានលក្ខណៈសាមញ្ញ ហើយអាចមិនមានលក្ខណៈផ្លូវការទេ ពីព្រោះគ្រាន់តែធ្វើឡើងរវាងភាគីទំនាស់ ឬតំណាងរបស់ភាគីទំនាស់ប៉ុណ្ណោះ។
  - រកដំណោះស្រាយដោយភាគីទំនាស់ : តាមរយៈការចរចា ភាគីទំនាស់ទាំងអស់ព្យាយាមស្វែងរកដំណោះស្រាយដ៏សមស្របមួយដោយខ្លួនឯង។ ដូច្នេះពួកគេងាយទទួលយក និងអនុវត្តនូវដំណោះស្រាយដែលបានកំណត់ ព្រមទាំងទទួលយកលទ្ធផលនៃដំណោះស្រាយនោះដោយពេញចិត្ត។
  - ភាពបត់បែន : ការចរចាផ្តល់ឱកាសឱ្យភាគីទំនាស់អាចធ្វើការបត់បែនបានច្រើនជាងការដោះស្រាយតាមវិធីសាស្ត្រផ្សេងៗទៀត។
  - បន្តទំនាក់ទំនង : តាមរយៈការចរចាបានផ្តល់ឱកាសឱ្យភាគីទំនាស់បន្តការទំនាក់ទំនងជាមួយគ្នាដោយរួមបញ្ចូលទាំងក្នុងដំណើរការដោះស្រាយ និងក្រោយការដោះស្រាយផងដែរ។

- ឯកជនភាព : ការចរចាជាវិធីសាស្ត្រដែលត្រូវធ្វើឡើងជាលក្ខណៈឯកជន ហើយព័ត៌មានអំពីទំនាស់អាចនឹងមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

- **គុណវិបត្តិ**
  - ការពន្យារពេល : ភាគីមួយអាចប្រើប្រាស់ការចរចាជាមធ្យោបាយពន្យារពេល ដើម្បីបង្អាក់ភាគីមួយទៀតពីការដាក់ពាក្យបណ្តឹង ។
  - ការប្រតិបត្តិដំណោះស្រាយ : ទោះបីជាភាគីទំនាស់បានព្រមព្រៀងគ្នាលើដំណោះស្រាយក៏ដោយក៏មិនអាចធានាថាគ្រប់ភាគីទាំងអស់បានអនុវត្តតាមកិច្ចព្រមព្រៀងនោះដែរ ។ ដូច្នេះប្រសិនបើភាគីណាមួយមិនអនុវត្តតាមកិច្ចសន្យានោះ ភាគីម្ខាងទៀតនៅតែត្រូវស្វែងរកភាគីអព្យាក្រឹតទីបី ឬប្តឹងទៅស្ថាប័នមានសមត្ថកិច្ចដើម្បីដោះស្រាយ ។
  - អាចមានការលំបាកក្នុងការយល់ព្រមជួបចរចាគ្នារវាងភាគីទាំងសងខាង ប្រសិនបើករណីទំនាស់នោះស្ថិតក្នុងស្ថានការណ៍ប្រឈមមុខតឹងតែង និងកើតមានអំពើហិង្សា ។

## គ). ដំណើរការនៃការចរចា

- **ដំណាក់កាលទី១ : ការរៀបចំការចរចា**
  - ស្រាវជ្រាវ ឬប្រមូលព័ត៌មានដែលចាំបាច់
  - កំណត់តម្រូវការ និងផលប្រយោជន៍របស់ខ្លួនផ្ទាល់ និងរបស់ភាគីម្ខាងទៀត
  - គិតពិចារណានូវជម្រើសនានារបស់ខ្លួន ដែលចង់បានពីការចរចា ក៏ដូចជាជម្រើសដ៏ល្អបំផុតសម្រាប់កិច្ចព្រមព្រៀងនៃការចរចា
  - ទំនាក់ទំនងជាមួយភាគីម្ខាងទៀត ដើម្បីព្រមព្រៀងលើទីកន្លែង ពេលវេលា បញ្ហា អ្នកចូលរួម... ។
- **ដំណាក់កាលទី២ : សកម្មភាពក្នុងការចរចា**
  - នៅពេលចូលដល់កន្លែងចរចា គួរជម្រាបសួរគ្នាទៅវិញទៅមកដើម្បីកសាងភាពជឿជាក់គ្នា
  - ចែករំលែកគ្នាទៅវិញទៅមកនូវគំនិតផ្សេងៗរបស់អ្នកអំពីស្ថានភាព ឬទំនាស់
  - ព្រមព្រៀងគ្នាលើការកំណត់បញ្ហា
  - ស្វែងយល់អំពីតម្រូវការ ផលប្រយោជន៍របស់ខ្លួនឯង និងរបស់ភាគីម្ខាងទៀត
  - លើកឡើងនូវជម្រើសនៃដំណោះស្រាយនានា
  - ជ្រើសរើសដំណោះស្រាយដ៏ល្អមួយដោយធ្វើការវាយតម្លៃ និងចាត់អាទិភាពជម្រើសនានាដោយផ្អែកតាមតម្រូវការ និងផលប្រយោជន៍របស់ភាគីទាំងសងខាង ។
  - បង្កើតកិច្ចព្រមព្រៀង (តាមជម្រើសដែលបានជ្រើសរើស)

- **ដំណាក់កាលទី៣ : ការបញ្ចប់ការចរចា**
  - បង្កើតផែនការសកម្មភាពដែលត្រូវអនុវត្តបន្ត
  - អនុវត្តកិច្ចព្រមព្រៀង
  - តាមដានលើការអនុវត្តកិច្ចព្រមព្រៀង ។

| **ការចរចាតាមរបៀប**<br>**ឈ្នះ-ចាញ់** (ផ្អែកលើជំហរ) **និង** **ឈ្នះ-ឈ្នះ** (ផ្អែកលើផលប្រយោជន៍) | |
|---|---|
| • ប្រើពាក្យ "ខ្ញុំ និងអ្នក" ឬ "ពួកយើង-ពួកគេ" | • យើងទាំងអស់គ្នាមានបញ្ហា ឬវាជាបញ្ហារបស់យើងទាំងអស់គ្នា |
| • បរិយាកាស : មានការប្រកួតប្រជែង និងគ្មានទំនុកចិត្ត | • បរិយាកាស : មានកិច្ចសហប្រតិបត្តិការ និងមានភាពបើកចំហ |
| • ការសម្រេចធ្វើឡើងដោយ :<br>– ការប្រឈមមុខដោយឥតអៀនខ្មាស<br>– ការគាបសង្កត់<br>– ការបង្ខិតបង្ខំ | • ការសម្រេចធ្វើឡើងដោយ :<br>– ការស្វះស្វែងរកព័ត៌មានជាក់ស្តែង<br>– មានឆន្ទៈឆ្ពោះទៅរកគោលដៅយុត្តិធម៌<br>– គិតពីផលប្រយោជន៍ទាំងសងខាង<br>– រក្សានូវសេចក្តីត្រូវការរបស់គូភាគី |
| • អាចនឹងមានការរើបម្រះ ឬការតវ៉ា | • អាចនឹងទទួលបាននូវការគាំទ្រកាន់តែច្រើន |
| • កាត់ផ្តាច់ការទំនាក់ទំនងរវាងភាគីទាំងពីរ | • រក្សាទំនាក់ទំនងរវាងភាគីទាំងពីរ |

## ឃ). គោលការណ៍នៃការចរចា

គោលការណ៍នៃការចរចារួមមាន :

- ស្តាប់មតិយោបល់របស់ភាគីម្ខាងទៀតយ៉ាងយកចិត្តទុកដាក់ : ទោះបីជាអ្នកមិនយល់ស្របនឹងអ្វីដែលគេកំពុងនិយាយក៏ដោយ ក៏អ្នកត្រូវយកចិត្តទុកដាក់ស្តាប់គំនិតយោបល់របស់គេដោយយកចិត្តទុកដាក់បំផុត ដើម្បីឱ្យអ្នកអាចដឹងច្បាស់អំពីស្ថានភាព និងផលប្រយោជន៍របស់ភាគីម្ខាងទៀត ហើយអាចស្ថិតនៅក្នុងស្ថានភាពប្រសើរមួយដើម្បីអាចរកដំណោះស្រាយទំនាស់បាន ។
- ជៀសវាងការទិតៀនលើបុគ្គល : ក្នុងការចរចាត្រូវផ្តោតលើបញ្ហា ហើយមិនត្រូវផ្តោតលើបុគ្គលឡើយ ។ ជារឿយៗ មនុស្សមានអារម្មណ៍ខឹង និងស្មុគស្មាញនៅពេលមានទំនាស់កើតឡើង ។ ដូច្នេះចូរព្យាយាមជជែក និងពិភាក្សាអំពីករណីទំនាស់ទើបអាចឈានទៅដល់ការព្រមព្រៀងគ្នាបាន ។
- រកដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក : ព្យាយាមរកឱ្យឃើញផលប្រយោជន៍ និង

គោលបំណងទាំងឡាយរបស់ភាគីម្ខាងទៀត និងបង្កើតដំណោះស្រាយទាំងឡាយដែលឱ្យភាគីទាំងអស់ទទួលបាននូវអ្វីដែលគេត្រូវការ ។

- ដំណោះស្រាយត្រូវមានភាពច្បាស់លាស់ និងងាយយល់ : ភាគីទាំងអស់ត្រូវយល់ឱ្យច្បាស់អំពីដំណោះស្រាយ របៀបអនុវត្តដំណោះស្រាយ ដោយរួមទាំងការប្រើពាក្យពេចន៍នៅក្នុងកិច្ចព្រមព្រៀងផងដែរ ដែលអាចជួយឱ្យភាគីនីមួយៗអនុវត្តដំណោះស្រាយនោះស្របតាមការព្រមព្រៀងឯកភាពគ្នា ។

## ខ). សិល្បៈនៃការចរចា

- **ការប្រាស្រ័យទាក់ទង**
  - អ្នកចរចាដ៏ប៉ិនប្រសព្វ គឺស្តាប់ច្រើនជាងនិយាយ
  - ប្រសិនបើអ្នកចង់ឱ្យភាគីម្ខាងទៀតស្តាប់ អ្នកត្រូវទទួលស្តាប់ភាគីនោះជាមុនសិន
  - ប្រសិនបើអ្នកចង់ឱ្យភាគីម្ខាងទៀតទទួលស្គាល់គំនិតរបស់អ្នក អ្នកត្រូវទទួលស្គាល់គំនិតភាគីនោះជាមុនសិន
  - ដើម្បីឱ្យភាគីម្ខាងទៀតយល់ព្រមជាមួយអ្នក អ្នកត្រូវចាប់ផ្តើមព្រមព្រៀងជាមួយភាគីនោះតាមលទ្ធភាពដែលអាចធ្វើទៅបាន
  - ត្រូវចាប់ផ្តើមដោយទទួលស្គាល់អំពីចំណុចរួមជានិច្ច
  - ផ្តល់យោបល់ត្រឡប់ជាវិជ្ជមានទៅភាគីម្ខាងទៀត
  - កុំនិយាយ "ប៉ុន្តែ" គួរនិយាយ "បាទ ឬ ចាស៎"
  - បង្ហាញទស្សនៈរបស់អ្នកដោយនិយាយថា "ជាការបន្ថែម" មិនមែនជាការប្រឆាំងតបតទៅនឹងអ្វីដែលភាគីម្ខាងទៀតនិយាយនោះទេ ។
- **ការកសាងទំនាក់ទំនង**
  - ខិតខំកសាងទំនាក់ទំនងល្អឱ្យបានមុន មុននឹងលើកឡើងនូវបញ្ហា
  - ត្រូវញែកឱ្យដាច់រវាងបុគ្គល និងឥរិយាបថរបស់គេ
  - កសាងទំនុកចិត្តដោយសន្សឹមៗ
  - ធានាទំនុកចិត្តនៃកិច្ចព្រមព្រៀងយូរអង្វែង
  - គោលដៅរបស់អ្នកមិនមែនយកឈ្នះ ឬចាញ់លើភាគីណាមួយទេ ប៉ុន្តែដើម្បីទាក់ទាញ ឬបញ្ចុះបញ្ចូលពួកគេ
  - បំបាត់សត្រូវរបស់អ្នកដោយចងមិត្តជាមួយពួកគេ
- **ការដោះស្រាយបញ្ហា**
  - គោលដៅនៃការចរចា គឺដើម្បីផ្លាស់ប្តូរពីការប្រឈមមុខឱ្យទៅជាការដោះស្រាយបញ្ហាជាមួយគ្នា
  - តម្លៃនៃការចរចាដ៏ល្អ គឺជាការទទួលផលប្រយោជន៍ដោយការពេញចិត្ត

- ប្រសិនបើអ្នកចង់ប្រឆាំងនឹងគំនិតរបស់ភាគីម្ខាងទៀត អ្នកត្រូវរៀបចំគម្រោងនិយាយ សួរសំណួរភ្ជាប់ទៅនឹងជម្រើសនៃការដោះស្រាយ ដែលអាចជួយយើងឱ្យដឹងអំពីកង្វល់របស់គេ
- ជួយភាគីម្ខាងទៀតក្នុងការរក្សាកិត្តិយស
- ប្រសិនបើភាគីម្ខាងទៀតធ្វើការវាយប្រហារ សូមកុំវាយបកវិញ ប៉ុន្តែត្រូវខិតខំធ្វើយ៉ាងណាឱ្យពួកគេបន្តការពិភាក្សា
- ផ្លាស់ប្តូរពីភាពជាសត្រូវទៅជាដៃគូ

### ច). ការចរចាដែលជោគជ័យ

ការចរចាដែលទទួលជោគជ័យ គឺជាការចរចាដែល :

- សម្រេចបាននូវកិច្ចព្រមព្រៀង ឬបានដោះស្រាយបញ្ហា
- ភាគីទាំងអស់បានដោះស្រាយបញ្ហារបស់ពួកគេដោយយុត្តិធម៌
- គ្មានការបែកបាក់ទំនាក់ទំនងរវាងភាគីទាំងអស់ ទាំងក្នុងអំឡុងពេលចរចា និងក្រោយពេលចរចា
- ទទួលយកដោយភាគីទាំងអស់ ពោលគឺមិនមានភាគីណាមួយត្រូវបានគេបង្ខំឱ្យទទួលយកអ្វីមួយដែលខ្លួនមិនពេញចិត្តឡើយ
- ភាគីទាំងអស់ទទួលស្គាល់ភាពខុសគ្នានៃមូលដ្ឋានទំនាក់ទំនង ឬការយល់ឃើញ
- ភាគីទាំងអស់មានជំនឿថា ការចរចា គឺជាជម្រើសមួយដែលល្អបំផុតសម្រាប់ដោះស្រាយបញ្ហា

## ឧទាហរណ៍ "រឿងស្ពាយសាច់ខ្វៃ"

**វិច្ឆិកា** ជាកម្មករសំណង់ មានភរិយាម្នាក់ឈ្មោះ **កុម្ភៈ** ជាគ្រូបង្រៀនសាលាបឋមសិក្សាក្នុងភូមិ។ ល្ងាចថ្ងៃមួយ **វិច្ឆិកា** បានបើកប្រាក់រង្វាន់ ហើយបាននាំមិត្តភក្តិដែលជាកម្មករសំណង់ដូចគ្នាមកស៊ីផឹកនៅផ្ទះគាត់។ **កុម្ភៈ** បានរៀបចំចម្អិនម្ហូបអាហារផង មើលថែទាំកូនផង និងផ្គត់ផ្គង់ម្ហូបអាហារឱ្យភ្ញៀវរបស់ប្តីផង។ ក្រោយពីភ្ញៀវត្រលប់ទៅវិញអស់ **វិច្ឆិកា** ស្រវឹងស្រា ហើយក៏ដេកលក់ទៅ។ ចំណែក **កុម្ភៈ** នៅបន្តរៀបចំទុកដាក់ចានឆ្នាំង។ **កុម្ភៈ** ឃើញសាច់ខ្វៃសល់ច្រើនពេក ក៏យកសាច់ខ្វៃនោះទៅកម្តៅទុកសម្រាប់បរិភោគថ្ងៃស្អែកទៀត។ ដោយអស់កម្លាំងផង និងងងុយគេងផង **កុម្ភៈ** បានគេងលក់នៅក្បែរចង្ក្រាន។ **កុម្ភៈ** ភ្ញាក់ឡើងនៅពេលឮអ្នកជិតខាងស្រែកថា ភ្លើងឆេះផ្ទះៗ។ នាងបានរត់ទៅដាស់ប្តីដែលកំពុងគេងលក់ដោយភាពស្រវឹងឱ្យភ្ញាក់ឡើង និងនាំកូនរត់ចេញពីអគ្គិភ័យ។ ភ្លើងឆេះផ្ទះ **វិច្ឆិកា** ហើយរាលដល់ផ្ទះ **សីហា** ដែលនៅក្បែរនោះ។ ផ្ទះ និងទ្រព្យសម្បត្តិរបស់ **វិច្ឆិកា** និង **សីហា** ក្លាយជាចំណីភ្លើងទាំងអស់។ ករណីនេះ **សីហា** បានទាមទារឱ្យ **វិច្ឆិកា** សងការខូចខាតទាំងស្រុង។

- **ដំណោះស្រាយទី១ : វិច្ឆិកា** បានទៅជួប **សីហា** ដើម្បីសុំកុំឱ្យ **សីហា** ទាមទារសំណង ព្រោះផ្ទះ និងទ្រព្យសម្បត្តិរបស់គាត់ក៏ភ្លើងឆេះអស់ដែរ ប៉ុន្តែ **សីហា** មិនព្រម ព្រោះគាត់មិនអាចខាតបង់ផ្ទះ និងទ្រព្យសម្បត្តិទទេៗឡើយ។ ដំណោះស្រាយនេះ គឺជាការដោះស្រាយទំនាស់តាមរយៈ "**ការចរចា**"។

## ៣.២.២. ការសម្រុះសម្រួល

### ក). និយមន័យ



ការសម្រុះសម្រួល ជាដំណើរការនៃការដោះស្រាយទំនាស់មួយ ដែលភាគីទំនាស់ទាំងអស់បានព្រមព្រៀងគ្នាក្នុងការជ្រើសរើសភាគីទីបី ដែលជាភាគីអព្យាក្រឹតដើម្បីជួយធ្វើអន្តរាគមន៍ និងសម្រុះសម្រួល។ ការសម្រុះសម្រួលភាគច្រើនធ្វើឡើង នៅពេលណាដែលការចរចាមិនបានជោគជ័យ។

### ខ). គុណសម្បត្តិ និងគុណវិបត្តិ

- **គុណសម្បត្តិ**
  - មិនចំណាយច្រើន : អ្នកសម្រុះសម្រួលអាចធ្វើឡើងដោយស្ម័គ្រចិត្ត ឬត្រូវចំណាយបន្តិចបន្តួចប៉ុណ្ណោះ។
  - សាមញ្ញ : ការសម្រុះសម្រួលជាវិធីសាស្ត្រសាមញ្ញ ហើយមិនមានវិធានការផ្លូវការ ឬសវនការទេ ទោះបីជាអ្នកសម្រុះសម្រួលមាននីតិវិធីដែលភាគីទំនាស់ត្រូវអនុវត្តតាមក៏ដោយ។
  - បង្កើតដំណោះស្រាយដោយភាគីទំនាស់ : អ្នកសម្រុះសម្រួលគ្រាន់តែជួយឱ្យភាគីទាំងអស់ក្នុងទំនាស់ធ្វើការរួមគ្នាដើម្បីស្វែងរកដំណោះស្រាយដោយខ្លួនឯងប៉ុណ្ណោះ ដូច្នេះមិនមានភាគីណាមួយត្រូវបានបង្ខំឱ្យទទួលយកកិច្ចព្រមព្រៀង ដែលទទួលបានពីការសម្រុះសម្រួលឡើយ។
  - មិនសូវមានការប្រឈមមុខខ្លាំង : ការសម្រុះសម្រួលអាចជួយរក្សាទំនាក់ទំនងរវាងភាគីទំនាស់បន្តទៀត។
  - រក្សាការសម្ងាត់ : មានតែអ្នកចូលរួមក្នុងដំណើរការនៃការសម្រុះសម្រួលប៉ុណ្ណោះដែលដឹងអំពីព័ត៌មានទំនាស់។
- **គុណវិបត្តិ**
  - ពន្យារពេល : ភាគីមួយអាចយកការសុំសម្រុះសម្រួលដើម្បីបង្អាក់ភាគីមួយទៀតពីការដាក់ពាក្យបណ្តឹង
  - ការអនុវត្តកិច្ចព្រមព្រៀង : ទោះបីជាភាគីទាំងពីរបានព្រមព្រៀងលើដំណោះស្រាយក៏ដោយ ក៏មិនអាចធានាថា គ្រប់ភាគីទាំងអស់នោះអនុវត្តតាមកិច្ចព្រមព្រៀងដែរ។ ដូច្នេះប្រសិនបើភាគីណាមួយមិនអនុវត្តតាមកិច្ចព្រមព្រៀង នោះទំនាស់នៅតែមិនបានដោះស្រាយ ហើយភាគីម្ខាងទៀតនៅតែប្តឹងទៅស្ថាប័នមានសមត្ថកិច្ចដដែល។

## គ). ដំណើរការនៃការសម្រុះសម្រួល

ដើម្បីឱ្យការសម្រុះសម្រួលទំនាស់មានប្រសិទ្ធភាព គូទំនាស់ និងអ្នកសម្រុះសម្រួលត្រូវពិចារណា និងអនុវត្តសកម្មភាពតាមដំណាក់កាលមួយចំនួនដូចខាងក្រោម :

- **គូភាគីព្រមព្រៀងដោះស្រាយទំនាស់តាមការសម្រុះសម្រួល :** ភាគីទំនាស់ទាំងអស់ត្រូវព្រមព្រៀងគ្នាក្នុងការដោះស្រាយទំនាស់តាមរយៈការសម្រុះសម្រួល។ ការសម្រុះសម្រួលធ្វើឡើងដោយស្ម័គ្រចិត្ត ដូច្នេះមិនមានភាគីណាមួយបង្ខំឱ្យភាគីមួយទៀតទទួលយកការដោះស្រាយតាមការសម្រុះសម្រួលឡើយ។
- **ជ្រើសរើសអ្នកសម្រុះសម្រួល :** បន្ទាប់ពីគូភាគីព្រមព្រៀងដោះស្រាយទំនាស់របស់ពួកគេ តាមរយៈការសម្រុះសម្រួល ភាគីទាំងអស់ត្រូវតែជ្រើសរើសអ្នកសម្រុះសម្រួល ឬស្ថាប័នដែលផ្តល់សេវាសម្រុះសម្រួលទំនាស់។ លក្ខណសម្បត្តិចម្បងនៃអ្នកសម្រុះសម្រួល គឺជាភាគីអព្យាក្រឹតដែលអាចឱ្យភាគីទំនាស់នីមួយៗជឿ និងទុកចិត្តបាន។ នៅក្នុងសហគមន៍ ឬនៅថ្នាក់ឃុំ សង្កាត់ អ្នកដែលអាចធ្វើជាអ្នកសម្រុះសម្រួលទំនាស់បានអាចជា មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ព្រះសង្ឃ អាចារ្យវត្ត អ្នកដឹកនាំសាសនា គ្រូបង្រៀន ចាស់ព្រឹទ្ធាចារ្យ និងអ្នកដែលត្រូវបានគេគោរពផ្សេងទៀតនៅក្នុងសហគមន៍។
- **អ្នកសម្រុះសម្រួលជួបជាមួយភាគីទំនាស់ :** ជាដំបូង អ្នកសម្រុះសម្រួលត្រូវជួបជាមួយភាគីទំនាស់នីមួយៗដោយឡែកៗពីគ្នា។ អ្នកសម្រុះសម្រួលពន្យល់ ដល់ភាគីទំនាស់អំពីដំណើរការនៃការសម្រុះសម្រួល ដោយធ្វើយ៉ាងណាឱ្យភាគីទំនាស់យល់អំពីដំណើរការ និងមានឆន្ទៈក្នុងការដោះស្រាយតាមការសម្រុះសម្រួល។ អ្នកសម្រុះសម្រួលអាចសួរសំណួរមួយចំនួនដើម្បីសិក្សាអំពីបញ្ហានៃទំនាស់ មូលហេតុពិតប្រាកដ និងគោលបំណងរបស់ភាគីនីមួយៗ។ ការជួបជាមួយភាគីទំនាស់ដោយឡែកៗនេះអាចធ្វើឡើងមុនកាលបរិច្ឆេទប្រជុំសម្រុះសម្រួល ឬអាចធ្វើឡើងនៅក្នុងថ្ងៃប្រជុំសម្រុះសម្រួល។
- **ការត្រៀមរៀបចំ :** មុននឹងឈានដល់ការជួបជុំគ្នាដើម្បីសម្រុះសម្រួល អ្នកសម្រុះសម្រួលត្រូវទំនាក់ទំនងជាមួយភាគីទំនាស់ទាំងអស់ ដើម្បីកំណត់អំពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងអ្នកដែលត្រូវចូលរួម។ ចំពោះពេលវេលា កាលបរិច្ឆេទ និងទីកន្លែងត្រូវកំណត់ឱ្យបានសមស្របបំផុត ដែលអាចឱ្យភាគីទំនាស់ទាំងអស់ចូលរួមបានពេញលេញ និងគ្មានការភ័យខ្លាច។ សម្រាប់ការរៀបចំកន្លែងអង្គុយត្រូវធ្វើយ៉ាងណាឱ្យភាគីទាំងពីរអង្គុយឆ្ងាយពីគ្នាបន្តិច ដើម្បីជៀសវាងការប៉ះទង្គិចរាងកាយ។
- **ការបើកអង្គប្រជុំ :** អ្នកសម្រុះសម្រួលចាប់ផ្តើមដោយកិច្ចស្វាគមន៍ និងថ្លែងអំណរគុណចំពោះវត្តមាននៃភាគីទាំងពីរ និងអរគុណចំពោះការតាំងចិត្តរបស់ពួកគេផងដែរ។
  - អ្នកសម្រុះសម្រួលត្រូវពិពណ៌នាបន្តិចអំពីមូលហេតុដែលពួកគេត្រូវមានវត្តមាននៅទីនេះ និងតួនាទីរបស់ខ្លួនជាអ្នកសម្រុះសម្រួលដែលត្រូវជួយឱ្យភាគីទំនាស់ទាំងអស់ស្វែងរកដំណោះស្រាយរួម។
  - បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវចាប់ផ្តើមបង្កើតគោលការណ៍នៃការពិភាក្សា ដូចជា :

+ ត្រូវនិយាយម្តងម្នាក់ៗ
+ ការនិយាយស្តីត្រូវមានសេចក្តីថ្លៃថ្នូរ
+ មិនត្រូវនិយាយកាត់គ្នា
+ មិនត្រូវមានការបំពានលើរូបរាងកាយ
+ ...។ល។

– អ្នកសម្របសម្រួលបញ្ជាក់បន្ថែមថា អ្វីៗដែលបាននិយាយក្នុងពេលនេះត្រូវរក្សាជាការសម្ងាត់ គ្មាននរណាម្នាក់ដឹងក្រៅពីអ្នកដែលមានវត្តមាននៅទីនេះឡើយ។
– អ្នកសម្រុះសម្រួលសុំការឯកភាពពីភាគីទំនាស់ទាំងអស់មុនពេលចូលដល់ការពិភាក្សា។

- **ការបរិយាយអំពីទំនាស់**

– អ្នកសម្រុះសម្រួលចាប់ផ្តើមដោយស្នើសុំឱ្យភាគីទំនាស់និយាយរឿងរ៉ាវរបស់ខ្លួនម្នាក់ម្តងៗ ដោយមិនអនុញ្ញាតឱ្យនរណាម្នាក់និយាយកាត់
– ភាគីនីមួយៗនិយាយរឿងរ៉ាវ បង្ហាញអំពីទស្សនៈ ឬយោបល់របស់ខ្លួនទៅតាមអ្វីដែលគេយល់ឃើញ
– កំណត់ពេលឱ្យបានត្រឹមត្រូវសម្រាប់ការនិយាយរបស់ភាគីនីមួយៗ
– អ្នកសម្រុះសម្រួលត្រូវមានជំនាញក្នុងការស្តាប់ ហើយត្រូវដឹងថា តើចំណុចអ្វីខ្លះដែលភាគីក្នុងទំនាស់មិនបានបញ្ចេញ?

- **ដំណាក់កាលពិភាក្សា (ដោះដូរ)**

– អ្នកសម្រុះសម្រួលអាចផ្តល់ឱកាសឱ្យភាគីមួយសួរទៅភាគីមួយទៀតដើម្បីសុំការបំភ្លឺ ដូច្នេះអ្នកសម្រុះសម្រួលត្រូវមានជំនាញក្នុងការស្តាប់ ជំនាញក្នុងការបរប្រយោគ ជំនាញក្នុងការរៀបចំប្រយោគនិយាយឡើងវិញ និងជំនាញក្នុងការសង្ខេបខ្លឹមសារជាដើម
– អ្នកសម្រុះសម្រួលអាចជួយក្នុងការស្រាយបំភ្លឺនូវការយល់ច្រឡំនានារបស់ភាគីនីមួយៗ
– បើសិនជាស្ថានភាពមិនល្អ ដែលមិនអាចត្រួតត្រាបាន ត្រូវឱ្យសម្រាកបន្តិចសិន ឬនាំភាគីណាមួយចេញក្រៅ ហើយនិយាយជាមួយគេដោយឡែកៗ ឬអ្នកសម្រុះសម្រួលអាចស្នើឱ្យភាគីទំនាស់សម្រាកនិងពន្យារពេល ដើម្បីឱ្យភាគីនីមួយៗមានពេលគ្រប់គ្រាន់ក្នុងការគិត និងពិចារណាលើករណីទំនាស់និងគំនិតយោបល់របស់អ្នកសម្រុះសម្រួល។

- **ដំណាក់កាលកសាងកិច្ចព្រមព្រៀង**

– អ្នកសម្រុះសម្រួលស្នើឱ្យភាគីនីមួយៗលើកឡើងអំពីជម្រើសនៃដំណោះស្រាយ
– ពិភាក្សាជ្រើសរើសយកជម្រើសណាមួយដែលផ្តល់ប្រយោជន៍ដល់ភាគីទាំងសងខាង
– រៀបចំកិច្ចព្រមព្រៀងទៅតាមអ្វីដែលភាគីទំនាស់បានឯកភាព
– អ្នកសម្រុះសម្រួលណែនាំដល់ភាគីទំនាស់ក្នុងការអនុវត្តកិច្ចព្រមព្រៀង (ក្នុងករណីនេះ ជាការប្រសើរ

គួររៀបចំកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ និងត្រូវឱ្យភាគីទាំងអស់ចុះហត្ថលេខា ឬផ្តិតមេដៃ)

– អ្នកសម្រុះសម្រួលបិទការប្រជុំដោយថ្លែងអំណរគុណដល់ភាគីទំនាស់ ចំពោះកិច្ចសហការរបស់គេ។

## ឃ). គោលការណ៍របស់អ្នកសម្រុះសម្រួល

ក្នុងការសម្រុះសម្រួលទំនាស់ អ្នកសម្រុះសម្រួលគួរពិចារណាលើចំណុចគន្លឹះមួយចំនួនដូចខាងក្រោម :

- **គួរមានគំនិតទទួលយក :** ទទួលយកគំនិតរបស់ភាគីទាំងសងខាង (ត្រូវទាំងសងខាង) ទោះជាអ្នកពេញចិត្តនឹងគំនិតរបស់ភាគីណាមួយជាងក៏ដោយ ឬសូម្បីតែអ្នកជួបតែភាគីម្ខាងក៏ដោយ។
- **គួរមានចិត្តជួយជ្រោមជ្រែង :** ប្រើប្រាស់ភាសាដែលសម្តែងការយកចិត្តទុកដាក់ បង្កើតបរិយាកាសមានសន្តិសុខដែលធ្វើឱ្យគេបើកចំហចិត្តបានច្រើន។
- **មិនគួរវិនិច្ឆ័យ ឬវាយតម្លៃ :** អ្នកសម្រុះសម្រួលមិនត្រូវវិនិច្ឆ័យលើចម្លើយ ឬគំនិតយោបល់របស់ភាគីទំនាស់ដែលបានលើកឡើងឡើយ។
- **គួរប្រើសំណួរឈ្លាសវៃ :** សួរសំណួរដើម្បីជំរុញឱ្យមានការផ្តល់គំនិតផ្សេងៗពីអ្នកចូលរួម មិនគួរទូន្មាន ឬបង្គាប់ ប៉ុន្តែបើចាំបាច់ត្រូវផ្តល់ត្រឹមតែជម្រើសប៉ុណ្ណោះ។
- **គួរប្រើវិធីឈ្នះ-ឈ្នះ :** ធ្វើឱ្យភាគីនៃទំនាស់ឈ្នះទាំងសងខាង ដោយប្តូរពីគូប្រឆាំងទៅជាដៃគូដោះស្រាយ។

## ង). តួនាទីរបស់អ្នកសម្រុះសម្រួល

តួនាទីរបស់អ្នកសម្រុះសម្រួលក្នុងការដោះស្រាយទំនាស់អាចមានដូចខាងក្រោម :

- ជួយជម្រះនូវការយល់ច្រឡំទាំងឡាយរបស់ភាគីទំនាស់
- ជួយឱ្យភាគីទំនាស់នីមួយៗឯកភាពគ្នា និងមានទំនុកចិត្តលើចំណុចដែលត្រូវធ្វើការសម្រុះសម្រួល
- ជួយឱ្យភាគីទំនាស់មានការយោគយល់គ្នា
- នាំពាក្យ ឬនាំសារពីភាគីមួយទៅភាគីមួយទៀត ដោយបង្កប់នូវការសម្រុះសម្រួល
- ជំរុញឱ្យភាគីទំនាស់យកចិត្តទុកដាក់ចំពោះការពិតដែលមើលរំលង

### ដំណោះស្រាយនៃឧទាហរណ៍

### ករណីរឿង "ស្វាយសាច់ខ្មៅ" នៅទំព័រទី២៨

- **ដំណោះស្រាយទី២ : *វិច្ឆិកា*** ទៅពឹងពូ ***សុក*** ឱ្យជួយអង្វរ ***សីហា*** កុំឱ្យប្តឹងគាត់។ ពូ ***សុក*** ទៅជួប ***សីហា*** ដោយបង្ហាញការគាំទ្រចំពោះការទាមទាររបស់ ***សីហា*** ប៉ុន្តែ ***ពូសុក*** បានពន្យល់អំពីច្បាប់នានាដល់ ***សីហា*** ហើយស្នើឱ្យ ***សីហា*** បន្ថយចំនួនទឹកប្រាក់ដែលទាមទារ។ ***សីហា*** យល់ព្រមបន្ថយការទាមទារមួយកម្រិត។ ដោយឡែក ***វិច្ឆិកា*** មិនអាចរកប្រាក់មកសង ***សីហា*** បានភ្លាមៗទេ ហើយគាត់ស្នើសុំពន្យារពេល ប៉ុន្តែ ***សីហា*** មិនព្រម។ ដំណោះស្រាយទី២ គឺជាការដោះស្រាយទំនាស់តាមរយៈ "*ការសម្រុះសម្រួល*"។

## ៣.២.៣. មជ្ឈត្តការ ឬអាជ្ញាកណ្តាល

មជ្ឈត្តការ គឺជាវិធីមួយនៃការដោះស្រាយទំនាស់ទ្វេភាគី ដែលមានភាគីអព្យាក្រឹតទី៣ ឬហៅថាអាជ្ញាកណ្តាល ឬមជ្ឈត្តករ ឬសាលាក្តីអាជ្ញាកណ្តាល (ប្រសិនបើមានអាជ្ញាកណ្តាលច្រើនជាងម្នាក់) ទទួលបណ្តឹងពីភាគីនៃទំនាស់ពិនិត្យភស្តុតាង និងចេញសេចក្តីសម្រេចដែលគេចាត់ទុកថា សេចក្តីសម្រេចដើម្បីដោះស្រាយទំនាស់ ។

### ក. គុណសម្បត្តិ និងគុណវិបត្តិនៃមជ្ឈត្តការ

- **គុណសម្បត្តិ**
  - សេរីភាព និងភាពបត់បែន : ភាគីទាំងឡាយមានសេរីភាពក្នុងការកំណត់ភារកិច្ច និងលក្ខខណ្ឌនៃមជ្ឈត្តការ
  - ការទុកចិត្តនៅលើភាពមិនលម្អៀងរបស់អ្នកធ្វើសេចក្តីសម្រេចចិត្ត : រាល់ការសម្រេចធ្វើឡើងដោយភាគីអព្យាក្រឹត មិនពុករលួយ ឬលម្អៀង ឬប្រឆាំងទៅភាគីណាមួយ ។
  - ចំណាយតិច : ជាទូទៅការដោះស្រាយតាមមជ្ឈត្តករ ឬអាជ្ញាកណ្តាល ត្រូវចំណាយតិចជាងការដោះស្រាយតាមប្រព័ន្ធតុលាការ
  - សាមញ្ញ : វិធីសាស្ត្រនេះមានលក្ខណៈសាមញ្ញ និងមានលក្ខណៈផ្លូវការតិចជាងការបណ្តឹងវិវាទ
  - រហ័ស : មជ្ឈត្តការអាចសម្រេចលទ្ធផលបានរហ័សជាងបណ្តឹងវិវាទ
  - ការសម្រេច : ការសម្រេចរបស់មជ្ឈត្តករ គឺជាសេចក្តីសម្រេចចុងក្រោយ ហើយមិនត្រូវបានពិនិត្យដោយតុលាការទេ លើកលែងតែមានមូលហេតុចាំបាច់ ។
  - ការប្រតិបត្តិដំណោះស្រាយ : ការសម្រេចរបស់អាជ្ញាកណ្តាលអាចមានប្រសិទ្ធភាពជាងដំណោះស្រាយតាមការចរចា ឬដំណោះស្រាយតាមការសម្រុះសម្រួល ។
  - បន្ថយភាពបដិបក្ខ : មជ្ឈត្តការជួយរក្សាទំនាក់ទំនងរវាងភាគីទាំងអស់ក្នុងទំនាស់ ។
  - ឯកជន : ព័ត៌មានដែលបានដឹងពីទំនាស់ គឺជាការសម្ងាត់ ដែលភាគីទាំងឡាយតែងតែមិនចង់ឱ្យមានការផ្សព្វផ្សាយពីរឿងក្តីជាសាធារណៈឡើយ ។
- **គុណវិបត្តិ**
  - មជ្ឈត្តការអាចពិបាក ប្រសិនបើមានភាគីនៃទំនាស់ច្រើនជាងពីរ
  - ភាគីនៃទំនាស់ត្រូវចំណាយដោយផ្ទាល់សម្រាប់មជ្ឈត្តករម្នាក់ ឬមជ្ឈត្តករច្រើននាក់
  - អាចមានភាគីណាមួយព្យាយាមពន្យាពេល ឬរារាំងការធ្វើមជ្ឈត្តការ

### ខ. ចំណុចសំខាន់ៗនៃមជ្ឈត្តការ

- អាជ្ញាកណ្តាល ឬមជ្ឈត្តិករជាមនុស្សដែលមានបទពិសោធន៍ និងចំណេះដឹងទាក់ទងនឹងប្រធានបទទំនាស់
- អាជ្ញាកណ្តាល ឬមជ្ឈត្តករ ជាមនុស្សអព្យាក្រឹត ឯករាជ្យ ហើយអាចធ្វើសេចក្តីសម្រេចដោយផ្អែកលើបញ្ហាជាក់លាក់

- អាជ្ញាកណ្តាល ឬមជ្ឈត្តករ អាចជាមនុស្សម្នាក់ ឬក្រុមមនុស្ស ដែលត្រូវចុះហត្ថលេខាជាមុនលើកិច្ចព្រមព្រៀងថា យល់ព្រមធ្វើជាអាជ្ញាកណ្តាល
- ភាគីទាំងសងខាងត្រូវបង្ហាញនូវភស្តុតាងទៅអាជ្ញាកណ្តាល បន្ទាប់មកទើបអាជ្ញាកណ្តាលជាអ្នកសម្រេចថា ភាគីណាត្រូវ ហើយភាគីណាខុស
- សេចក្តីសម្រេចរបស់អាជ្ញាកណ្តាល ត្រូវមានភ្ជាប់ជាមួយកាតព្វកិច្ចរបស់ភាគីនីមួយៗ ហើយភាគីនីមួយៗនោះត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ
- ការកាត់សេចក្តីរបស់អាជ្ញាកណ្តាលត្រូវផ្អែកលើច្បាប់ និងការព្រមព្រៀងរបស់គូភាគី
- ប្រសិនបើមិនមានច្បាប់សម្រាប់គិតពិចារណាទេ អាជ្ញាកណ្តាលត្រូវគិតថ្លឹងថ្លែងតាមគតិយុត្តិធម៌
- ប្រយោជន៍នៃការដោះស្រាយតាមបែបអាជ្ញាកណ្តាល គឺការដោះស្រាយដែលអាចរក្សាការសម្ងាត់

**បញ្ជាក់ :** មជ្ឈត្តការ ឬការដោះស្រាយទំនាស់តាមបែបអាជ្ញាកណ្តាល គឺជាវិធីសាស្ត្រទូទៅសម្រាប់ដោះស្រាយទំនាស់មួយ ប៉ុន្តែឃុំ សង្កាត់មិនអាចដើរតួនាទីជាអាជ្ញាកណ្តាល ឬមជ្ឈត្តករក្នុងការដោះស្រាយទំនាស់នៅក្នុងឃុំ សង្កាត់ឡើយ។

## ៣.២.៤. ការដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការ



ការកាត់សេចក្តី គឺជាទម្រង់ ឬរបៀបនៃការដោះស្រាយទំនាស់មួយ ដែលត្រូវធ្វើឡើងដោយប្រព័ន្ធតុលាការ និងពឹងផ្អែកលើច្បាប់។ ការកាត់សេចក្តីដោយតុលាការ អាចមានសារៈសំខាន់សម្រាប់ដោះស្រាយទំនាស់ដែលមានទ្រង់ទ្រាយធំ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានា ឬសម្រាប់ទំនាស់ដែលមិនអាចធ្វើការចរចា ឬសម្រុះសម្រួលបាន។

### ក). គុណសម្បត្តិ

គុណសម្បត្តិចម្បងនៃការដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការរួមមាន :

- ការសម្រេចរបស់តុលាការ ដែលហៅថា ការកាត់សេចក្តី គឺជាការអនុវត្តនូវអំណាចរបស់រដ្ឋ
- តុលាការអាចជួយរឹបអូសទ្រព្យសម្បត្តិរបស់ភាគីម្ខាងដែលចាញ់ឱ្យទៅភាគីដែលឈ្នះ
- ភាគីទំនាស់នីមួយៗត្រូវតែគោរព និងអនុវត្តតាមសាលក្រមរបស់តុលាការ
- មានលក្ខណៈផ្លូវច្បាប់ជាងវិធីសាស្ត្រដោះស្រាយទំនាស់នានា

### ខ). គុណវិបត្តិ

គុណវិបត្តិនៃការដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការរួមមាន ដូចជា :

- មាននីតិវិធីច្រើន ដែលប្រជាពលរដ្ឋពិបាកយល់

- អាចមានភាពយឺតយ៉ាវ ហើយអាចត្រូវការចំណាយពេលវេលា និងធនធានច្រើន
- បន្ទាប់ពីកាត់សេចក្តី គូភាគីទាំងសងខាងនៅតែជាគូសត្រូវនឹងគ្នា

ទោះបីជាការដោះស្រាយទំនាស់តាមប្រព័ន្ធតុលាការមានសារៈសំខាន់ក៏ដោយ ក៏មេរៀននេះមិនផ្តោតជាចម្បងលើរបៀបនៃការដោះស្រាយតាមប្រព័ន្ធតុលាការឡើយ ។

## ៣.៣. ការជ្រើសរើសវិធីសាស្ត្រ




រាល់វិធីសាស្ត្រដោះស្រាយទំនាស់ទាំងអស់ សុទ្ធតែមានគោលបំណងក្នុងការបង្កើតឱកាសឱ្យមានការព្រមព្រៀងគ្នា ដើម្បីបញ្ចប់ទំនាស់រវាងគូភាគីទាំងអស់ក្នុងទំនាស់ ។ រាល់វិធីសាស្ត្រដោះស្រាយទំនាស់ទាំងនោះ អាចមានចំណុចរួមគ្នាមួយចំនួនដូចជា :

- លើកទឹកចិត្តឱ្យភាគីទំនាស់ផ្តោតការយកចិត្តទុកដាក់ លើករណីទំនាស់ និងរៀបចំដើម្បីដោះស្រាយ
- ភាគីទំនាស់នីមួយៗមានឱកាសក្នុងការ "និយាយ" និង "ស្តាប់" ដែលអាចឱ្យពួកគេបង្ហាញនូវទស្សនៈ ឬការយល់ឃើញផ្ទាល់ខ្លួនអំពីស្ថានភាពទំនាស់
- ភាគីទំនាស់នីមួយៗមានឱកាសក្នុងការកំណត់នូវប្រយោជន៍រួម និងចំណុចរួមគ្នាផ្សេងៗទៀត ព្រមទាំងមានឱកាសក្នុងការបង្កើតជម្រើសនៃដំណោះស្រាយនានា ដែលភាគីទាំងអស់អាចទទួលយកបាន ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ត្រូវជ្រើសរើសយកវិធីសាស្ត្រណាមួយដែលសមស្របបំផុតទៅនឹងស្ថានភាពនៃទំនាស់ និងស្ថានភាពនៃគូភាគីទំនាស់ផងដែរ ។ ដូច្នេះដើម្បីជ្រើសរើសវិធីសាស្ត្រដែលសមស្របបំផុត អ្នកត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- ស្ថានភាព ឬលក្ខណៈនៃទំនាស់
- ស្ថានភាព ឬលក្ខណៈនៃទំនាក់ទំនងរបស់គូភាគីទំនាស់
- គោលបំណង និងគោលដៅនៃភាគីនីមួយៗ
- ផលប្រយោជន៍របស់ភាគីនីមួយៗ
- តុល្យភាពអំណាចនៃភាគីក្នុងទំនាស់
- ឯកជនភាពនៃភាគីទំនាស់ ឬភាពសម្ងាត់
- ភាគីពាក់ព័ន្ធក្នុងទំនាស់
- ធនធានរបស់ភាគីក្នុងទំនាស់

លើសពីនេះទៀត ការដោះស្រាយទំនាស់ដោយប្រើវិធីសាស្ត្រផ្សេងៗនៅថ្នាក់ឃុំ សង្កាត់ ផ្តល់សារៈប្រយោជន៍មួយចំនួនដូចខាងក្រោម :

- សន្សំពេលវេលា និងថវិកា
- អាចរក្សាទំនាក់ទំនងរវាងភាគីទំនាស់ មានភាពបត់បែន និងឆ្លើយតបទៅនឹងតម្រូវការរបស់ភាគី
- ភាគីទំនាស់អាចទទួលយកលទ្ធផលនៃការដោះស្រាយដោយពេញចិត្ត
- ពង្រឹងការចូលរួមរបស់សហគមន៍ក្នុងការដោះស្រាយទំនាស់ដោយសន្តិវិធី
- កាត់បន្ថយគូបដិបក្ខរវាងភាគីទំនាស់ ... ។ល។

## ៣.៤. ជំហានជាមូលដ្ឋានក្នុងការសម្រុះសម្រួលទំនាស់

ជំហានជាមូលដ្ឋានក្នុងការសម្រុះសម្រួលករណីទំនាស់ដែលកើតមានឡើងនៅក្នុងសហគមន៍ រួមមានជំហានដូចខាងក្រោម :

- ការទទួលពាក្យបណ្តឹង
- ស៊ើបអង្កេត និងប្រមូលព័ត៌មាន
- ការសម្រុះសម្រួល និងការពិភាក្សា
- រៀបចំកិច្ចព្រមព្រៀង
- ការបញ្ជូនករណីទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ
- ការតាមដាន និងការផ្សះផ្សា

### ៣.៤.១. ការទទួលពាក្យបណ្តឹង



នៅពេលមានករណីទំនាស់កើតឡើង ប្រសិនបើភាគីណាមួយចង់ធ្វើការប្តឹងមកអាជ្ញាធរមានសមត្ថកិច្ចដូចជា មេឃុំ ចៅសង្កាត់ គណៈកម្មាធិការដោះស្រាយទំនាស់ ឬមេភូមិ ភាគីនោះត្រូវរៀបចំពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ។ ទម្រង់នៃពាក្យបណ្តឹងអាចបត់បែន អាស្រ័យលើស្ថានភាពជាក់ស្តែង។ អាជ្ញាធរមានសមត្ថកិច្ចអាចស្នើឱ្យភាគីដើមបណ្តឹងរៀបចំពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរដោយបំពេញទម្រង់ដែលមានស្រាប់ ឬសរសេរដោយដៃ (សូមមើលទម្រង់គំរូពាក្យបណ្តឹង)។

## ៣.៤.២. ការស៊ើបអង្កេត និងប្រមូលព័ត៌មាន



ដើម្បីកុំឱ្យគូភាគី ដែលពាក់ព័ន្ធមានពេលក្នុងការបង្កើតសាច់រឿង ការចុះស៊ើបអង្កេតមិនគួរជម្រាបឱ្យភាគីទំនាស់ដឹងជាមុនឡើយ។ ការស៊ើបអង្កេតអាចធ្វើឡើងនៅកន្លែងកើតហេតុ ឬអាចសាកសួរអ្នកដែលរស់នៅជិតខាង និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីស្វែងរកសាក្សី និងភស្តុតាងនានា។ ជាការប្រសើរក្នុងការស៊ើបអង្កេត គួរមានអ្នកកត់ត្រា ប៉ុន្តែពួកគេមិនអាចបង្ខំឱ្យសាក្សីផ្តល់នូវរបាយការណ៍ជាលក្ខណៈផ្លូវការ ឬផ្តិតមេដៃលើកំណត់ត្រាបានទេ។ លើសពីនេះទៀត គួរមានស្ត្រីយ៉ាងហោចណាស់ម្នាក់ចូលរួមនៅក្នុងការចុះទៅអង្កេតនោះ ព្រោះថាស្ត្រីអាចមានអារម្មណ៍កក់ក្តៅជាងបុរសក្នុងការពិភាក្សាទៅលើបញ្ហាមួយចំនួនរបស់ស្ត្រី ពិសេសបញ្ហាដែលមានការអៀនខ្មាស។

ការចុះទៅដល់ទីតាំងកើតហេតុអាចជួយឱ្យអ្នកអង្កេតឃើញស្ថានភាពនៃកន្លែងកើតហេតុ និងមានលទ្ធភាពចូលទៅជិតបុគ្គលដែលពាក់ព័ន្ធក្នុងទំនាស់ ដែលជាមូលដ្ឋានក្នុងការស្វែងរកដើមហេតុរបស់បញ្ហាផងដែរ។

ក្នុងដំណើរការនៃការស៊ើបអង្កេត និងប្រមូលព័ត៌មាន ក្រុមអង្កេតត្រូវពិចារណា និងអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម :

- ស្វែងរកក្រុម និងបុគ្គលដែលមានការពាក់ព័ន្ធ
- ស្វែងរកសាក្សីផ្សេងៗដែលដឹងអំពីទំនាស់
- ស្វែងរកសាវតា និងសាច់រឿងរបស់ទំនាស់
- ស្វែងរកបុគ្គលមានចំណេះដឹងពាក់ព័ន្ធដែលអាចចូលរួមនៅក្នុងដំណើរការសម្រុះសម្រួលទំនាស់
- ស្រាវជ្រាវអំពីច្បាប់ បទបញ្ជា ទំនៀមទម្លាប់ និងប្រពៃណីផ្សេងៗដែលពាក់ព័ន្ធនឹងទំនាស់

ជាគោលការណ៍ ការស៊ើបអង្កេត និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនានាក្នុងទំនាស់ ពិសេសជាមួយអ្នករងគ្រោះ និងជាមួយអ្នកប្រព្រឹត្តបទល្មើស ត្រូវធ្វើឡើងក្នុងពេលផ្សេងៗគ្នា ព្រោះធ្វើដូច្នេះអាចជួយឱ្យពួកគេ :

- មានភាពកក់ក្តៅក្នុងការនិយាយដោយឥតលាក់លៀម
- មិនចាំបាច់យល់ព្រមជាមួយនឹងអ្នកដទៃទៀតដែលមានវត្តមាន
- អ្នកប្រមូលព័ត៌មានអាចសង្កេត និងវិភាគទៅលើផ្នែកផ្សេងៗរបស់សាច់រឿង

នៅពេលត្រឡប់មកវិញ ក្រុមប្រមូលព័ត៌មានត្រូវធ្វើការពិភាក្សាជាមួយនឹងសមាជិកក្រុម ឬក្រុមប្រឹក្សាឃុំ សង្កាត់ ទៅលើព័ត៌មាន និងភស្តុតាងនានាដែលប្រមូលបាន ហើយចាត់ចែងរកវិធី ឬជម្រើសនានាដើម្បីដោះស្រាយករណីទំនាស់នោះ។

**ឧទាហរណ៍ :** ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ម្នាក់និយាយថា ខ្ញុំបានចុះទៅស៊ើបអង្កេតដោយសម្ងាត់ ព្រោះខ្ញុំមិនចង់ឱ្យពួកគេដឹងអំពីការចុះស៊ើបអង្កេតនេះទេ។ ប្រសិនបើពួកគេដឹងមុន នោះខ្ញុំប្រហែលជាមិនអាចទទួលបាននូវព័ត៌មានពិតប្រាកដឡើយ។ ក្នុងការចុះប្រមូលព័ត៌មាន ខ្ញុំបានទៅនិយាយជាមួយអ្នករស់នៅជិតខាង និងអ្នកដែលបានដឹងឮអំពីករណីទំនាស់នោះ។ ខ្ញុំបានជួបសាក្សី និងប្រមូលភស្តុតាងនានា ហើយកត់ត្រាក្នុងសៀវភៅដែលជាជាងសរសេរក្នុងកំណត់ហេតុ ព្រោះក្នុងតំបន់នេះ នៅពេលមានរឿងអ្វីមួយកើតឡើង អ្នករស់នៅទីនេះមិនចង់មានការ ពាក់ព័ន្ធឡើយ។

## ៣.៤.៣. ការសម្រុះសម្រួល និងការពិភាក្សា

### ក). ការជ្រើសរើសទីកន្លែងសម្រាប់ប្រជុំ

ទីកន្លែងប្រជុំគួរតែជាទីកន្លែងអាព្យាក្រឹត មានន័យថា មិនមែនជាផ្ទះរបស់ភាគីណាមួយ ឬមួយនៅផ្ទះមិត្តភក្តិរបស់ភាគីណាមួយដែលមានឥទ្ធិពលនោះទេ។ ជាទូទៅនៅផ្ទះមេភូមិ សាលាឃុំ សង្កាត់ ឬនៅតាមទីវត្តអារាម (ប្រសិនបើភាគីទាំងអស់ជាអ្នកកាន់សាសនាព្រះពុទ្ធ) ជាដើម គឺជាទីតាំងដ៏សមគួរសម្រាប់ប្រជុំ។ អ្នកសម្រុះសម្រួលគួរតែធានាថា ភាគីទាំងអស់មានការកក់ក្តៅជាមួយនឹងទីតាំងដែលបានជ្រើសរើស។

### ខ). ការណែនាំ និងការសម្រុះសម្រួល

មុនពេលចាប់ផ្តើមធ្វើការសម្រុះសម្រួល អ្នកសម្រុះសម្រួលត្រូវពន្យល់ដល់ភាគីទំនាស់ទាំងអស់អំពីចំណុចដូចខាងក្រោម :

- ពន្យល់អំពីសារៈសំខាន់នៃទំនាក់ទំនងនៅក្នុងសង្គមរវាងភាគីទាំងសងខាង
- ពន្យល់អំពីការលំបាក ការចំណាយពេលវេលា និងធនធានសម្រាប់ដំណោះស្រាយនៅតុលាការ
- បង្ហាញអំពីគំរូ ឬដំណោះស្រាយករណីទំនាស់នានាដែលមានកន្លងមក
- ...។ល។

នេះគឺជាហេតុផលដែលជំរុញឱ្យភាគីទំនាស់ទាំងអស់នៅជុំគ្នា ហើយព្យាយាមបន្តការសម្រុះសម្រួល ឬក៏ងាកមករកកិច្ចពិភាក្សាគ្នាឡើងវិញម្តងទៀត ហើយហេតុផលនេះក៏អាចជួយបង្ហាញដល់ភាគីទាំងសងខាងឱ្យគិតអំពីអ្វីដែលជាតម្រូវការរួមរបស់ពួកគាត់ ដូចជា ការចំណាយតិច ការរាប់អានគ្នានៅក្នុងសហគមន៍ ការជួយគ្នាពេលមានគ្រោះអាសន្នជាដើម។ បន្ទាប់មក អ្នកសម្រុះសម្រួលត្រូវពិនិត្យពិចារណាលើដំណោះស្រាយមួយដែលជាដំណោះស្រាយ **ឈ្នះ-ឈ្នះ**។ លទ្ធផលនៃដំណោះស្រាយ ឈ្នះ-ឈ្នះ គឺគ្មានភាគីទំនាស់ណាមួយចាញ់ ឬអាប់ឱនកិត្តិយស បន្ទាប់ពីការសម្រុះសម្រួលទំនាស់នេះឡើយ។ អ្នកដោះស្រាយអាចជួយប្រជាពលរដ្ឋ ឬភាគីនៃទំនាស់ឱ្យលះបង់ចោលនូវគំនិតចង់ឈ្នះ-ចាញ់ ដែលមានតែភាគីខ្លួនប៉ុណ្ណោះជាអ្នកឈ្នះ ហើយភាគីម្ខាងទៀតជាអ្នកចាញ់ទាំងស្រុង។

នៅក្នុងការសម្រុះសម្រួលករណីទំនាស់ អ្នកសម្រុះសម្រួលត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម :

- ពន្យល់អំពីល័ក្ខខ័ណ្ឌនៅពេលចាប់ផ្តើមធ្វើកិច្ចពិភាក្សា

- ត្រូវមានការអត់ឱន អធ្យាស្រ័យ និងផ្តល់ឱកាសជាថ្មីដល់ភាគីទំនាស់
- មានភាពអំណត់អត់ធ្មត់
- តាំងចិត្តស្តាប់ដោយប្រុងប្រយ័ត្ន
- កុំបង្ហាញនូវភាពលម្អៀងទៅភាគីណាមួយនៅពេលប្រជុំ ព្រោះវាធ្វើឱ្យមានការកាត់បន្ថយនូវភាពជឿជាក់របស់ភាគីម្ខាងទៀតក្នុងការសម្រុះសម្រួល
- មិនត្រូវនិយាយកាត់នៅពេលអ្នកណាម្នាក់កំពុងនិយាយ
- ត្រូវព្យាយាមបន្តទៀត បើសិនជាដំណើរការមានភាពរីកចម្រើន

## គ). ពន្យល់ដល់គូភាគីទំនាស់ដោយផ្អែកលើច្បាប់

ប្រជាពលរដ្ឋភាគច្រើនមិនសូវយល់ដឹងអំពីច្បាប់ផ្សេងៗ ដែលពាក់ព័ន្ធនឹងអ្វីទៅជាទង្វើស្របច្បាប់ ឬមិនស្របច្បាប់នោះទេ។ អ្នកសម្រុះសម្រួលអាចប្រាប់ទៅភាគីទំនាស់អំពីអ្វីៗដែលមានចែងនៅក្នុងច្បាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពដែលភាគីទាំងនោះបានធ្វើ។ ការបង្ហាញអំពីខ្លឹមសារច្បាប់ដល់ភាគីពាក់ព័ន្ធក្នុងទំនាស់ ជាផ្នែកមួយក្នុងការដោះស្រាយទំនាស់យ៉ាងមានប្រសិទ្ធភាព។

**ឧទាហរណ៍ :** សមាជិកក្រុមប្រឹក្សាឃុំម្នាក់នៅខេត្តកំពង់ធំបានបញ្ជាក់ថា មានទំនាស់មួយចំនួន ដូចជា មានអ្នកខ្លះយកជើងផ្កាដាក់នៅលើផ្លូវ ឬតទុយោទឹកកាត់ពីលើផ្លូវដែលគេដើរ ដែលសកម្មភាពនេះធ្វើឱ្យមានទំនាស់ជាមួយអ្នកជិតខាង។ ក្នុងការសម្រុះសម្រួលទំនាស់នេះ ក្រុមប្រឹក្សាឃុំបានអញ្ជើញភាគីទាំងអស់នៃទំនាស់មកប្រជុំនៅសាលាឃុំ ហើយមេឃុំបានបង្ហាញ និងពន្យល់ដល់ពួកគាត់អំពីអ្វីដែលពួកគាត់បានធ្វើ និងអ្វីដែលច្បាប់បានចែងទាក់ទងនឹងការរំលោភសិទ្ធិអ្នកជិតខាងជាដើម។ បន្ទាប់ពីពន្យល់ និងសម្រុះសម្រួលមកឃើញថា ពួកគាត់បានយកជើងផ្កា ឬទុយោទឹកនោះចេញពីផ្លូវ"។

## ឃ). កិច្ចពិភាក្សា និងការពន្យារពេល



អ្នកដោះស្រាយគួរទុកពេលឱ្យភាគីទំនាស់បន្តកិច្ចពិភាក្សានូវបញ្ហារបស់ពួកគេរហូតដល់មានការព្រមព្រៀងគ្នា។ ប្រសិនបើនៅតែមិនមានការព្រមព្រៀងទៀតគួរធ្វើការពន្យារពេលពិភាក្សាមួយរយៈខ្លី ដើម្បីឱ្យភាគីទាំងសងខាងមានការពិចារណាឡើងវិញ នូវអ្វីដែលពួកគេបានធ្វើ ឬដើម្បីឱ្យរំសាយកំហឹង។ ប្រសិនបើភាគីទាំងសងខាងនៅតែមិនមានការរីកចម្រើនទៀត ឱកាសនៃការពន្យារពេលគួរមានត្រឹមបីដងជាការគ្រប់គ្រាន់សម្រាប់កិច្ចពិភាក្សានេះ។

## ៣.៤.៤. ការរៀបចំកិច្ចសន្យា

ដំណើរការនៃការបង្កើតកិច្ចសន្យាគួរតែមានគោលដៅដើម្បីសម្រេចបាននូវការអធ្យាស្រ័យ និងផ្តល់ឱកាសដល់ភាគីទំនាស់ដើម្បីបញ្ចប់ទំនាស់របស់ពួកគេ ឬជៀសវាងការប្តឹងទៅស្ថាប័នមានសមត្ថកិច្ចដទៃទៀត (សូមមើលទម្រង់គំរូនៃកិច្ចព្រមព្រៀង) ។

ល័ក្ខខ័ណ្ឌ និងការពិន័យគួរតែបញ្ចូលទៅក្នុងកិច្ចព្រមព្រៀង។ ការពិន័យត្រូវតែមានលក្ខណៈប្រាកដប្រជាដើម្បីកុំឱ្យភាគីទំនាស់មានការរំលោភទៅលើកិច្ចសន្យា ប៉ុន្តែមិនត្រូវមានល័ក្ខខ័ណ្ឌធ្ងន់ធ្ងរខ្លាំងពេកនោះទេ ពីព្រោះប្រសិនបើល័ក្ខខ័ណ្ឌខ្លាំងពេក នោះនឹងមិនមាននរណាម្នាក់គោរព និងធ្វើតាមឡើយ ។

ការសរសេរកិច្ចសន្យាអាចធ្វើឱ្យភាគីដែលពាក់ព័ន្ធនឹងទំនាស់មានការស្ងប់ស្ងៀម។ ដូច្នេះក្នុងកិច្ចព្រមព្រៀង ឬកិច្ចសន្យាមួយគួរមានព័ត៌មានមួយចំនួនដូចខាងក្រោម :

- កាលបរិច្ឆេទ ទីកន្លែងកើតហេតុ
- ពេលវេលានៃកិច្ចព្រមព្រៀង
- ល័ក្ខខ័ណ្ឌនៃការសន្យាដែលភាគីទាំងអស់បានព្រមព្រៀង
- ចុះហត្ថលេខា ឬផ្តិតមេដៃដោយភាគីទាំងសងខាង និងតំណាងអ្នកសម្រុះសម្រួលដែលមានដូចជា សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ឬប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ជាដើម ។

## ៣.៤.៥. ការបញ្ជូនករណីទំនាស់ទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ

ក្នុងករណីដែលមិនអាចដោះស្រាយបាន ករណីទំនាស់នឹងត្រូវបញ្ជូនទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃដើម្បីធ្វើការដោះស្រាយបន្ត។

- **បញ្ជូនករណីទំនាស់ទៅកាន់មេឃុំ ចៅសង្កាត់ :** ប្រសិនបើករណីទំនាស់មិនអាចឈានដល់កិច្ចព្រមព្រៀងនៅភូមិ ឬគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់បាន ករណីទំនាស់នឹងត្រូវបញ្ជូនទៅមេឃុំ ចៅសង្កាត់។ មេឃុំ ចៅសង្កាត់ជាតំណាងរបស់ប្រជាពលរដ្ឋ ដែលកើតចេញពីការបោះឆ្នោតត្រូវធ្វើការដោះស្រាយ និងសម្រុះសម្រួលករណីទំនាស់ប្រកបដោយយុត្តិធម៌ មិនលម្អៀង និងស្របតាមច្បាប់ដែលអាចឱ្យគូភាគីនៃទំនាស់ឈានដល់កិច្ចព្រមព្រៀង។ មេឃុំ ចៅសង្កាត់មានតួនាទីចម្បងក្នុងការសម្រុះសម្រួលទំនាស់ដល់ភាគីទាំងអស់ ប៉ុន្តែមេឃុំ ចៅសង្កាត់មិនមានសិទ្ធិក្នុងការកំណត់នូវចំនួនតម្លៃនៃសំណងទូទាត់ណាមួយឡើយ។ តម្លៃនៃសំណងទូទាត់ពីភាគីមួយឱ្យទៅភាគីមួយទៀតអាស្រ័យលើការព្រមព្រៀងរវាងភាគីទំនាស់ក្រោមការសម្រុះសម្រួលរបស់មេឃុំ ចៅសង្កាត់។
- **បញ្ជូនករណីទំនាស់ទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ :** ប្រសិនបើមេឃុំ ចៅសង្កាត់មិនអាចសម្រុះសម្រួល និងដោះស្រាយករណីទំនាស់នេះបាន ករណីទំនាស់នឹងត្រូវបញ្ជូនទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត។ ចំពោះករណីទំនាស់ដែលបង្កឱ្យមានបទល្មើសព្រហ្មទណ្ឌដូចជា ការបង្ក

ឱ្យមានរបួសស្នាម លួច ប្លន់ ឆបោក រំលោភផ្លូវភេទ រំលោភលើសេចក្តីទុកចិត្តជាដើម ត្រូវតែបញ្ជូនទៅកាន់អាជ្ញាធរមានសមត្ថកិច្ចឱ្យបានឆាប់ជាការប្រសើរ ព្រោះករណីបទល្មើសព្រហ្មទណ្ឌជាករណីទំនាស់ដែលមិនអាចធ្វើការសម្រុះសម្រួល ឬដោះស្រាយនៅក្រៅប្រព័ន្ធតុលាការបានឡើយ ។

**ឧទាហរណ៍ :** ករណីទំនាស់កើតឡើងក្នុងក្រុមគ្រួសារមួយ ដែលមានយាយម្នាក់បានយកក្មេងប្រុសម្នាក់ (មិនមែនចៅបង្កើត) មកចិញ្ចឹមធ្វើជាចៅរបស់ខ្លួនដោយរំពឹងថា ថ្ងៃក្រោយចៅប្រុសនេះអាចនឹងជួយថែរក្សាបីបាច់ខ្លួននៅពេលខ្លួនមានវ័យចាស់ជរា។ ដោយមានក្តីស្រឡាញ់ និងអាណិតចៅប្រុស យាយបានសន្យាចែកដីលំនៅស្ថានរបស់ខ្លួន និងផ្ទះដែលកំពុងរស់នៅឱ្យចៅប្រុសនោះ ។ លុះដល់យាយឈានដល់វ័យចាស់ជរា ចៅប្រុសដែលគាត់បានចិញ្ចឹមនោះមិនបានយកចិត្តទុកដាក់ទំនុកបម្រុងថែទាំយាយដូចអ្វីដែលយាយរំពឹងទុកទេ ។ ដោយមានជីវភាពខ្វះខាត យាយបានសម្រេចចិត្តលក់ដីលំនៅស្ថានរបស់ខ្លួនមួយចំណែក ដើម្បីទិញចំណីអាហារ និងឱសថព្យាបាលជំងឺ តែផ្ទុយទៅវិញ ចៅប្រុសនេះ បែរជានិយាយថា ដីនេះលក់មិនបានទេ ព្រោះវាជាកម្មសិទ្ធិរបស់ខ្លួន ។ ទោះបីជា **អ្នកស្ម័គ្រចិត្តដោះស្រាយទំនាស់ភូមិ** និង**មេភូមិ**បានចូលរួមជួយសម្រុះសម្រួលយ៉ាងណាក៏ដោយ ក៏ចៅប្រុសចិញ្ចឹមនោះមិនទទួលយកការសម្រុះសម្រួលឡើយ ។ អ្នកស្ម័គ្រចិត្តភូមិបានបញ្ជូនករណីទំនាស់នេះទៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ ។ គណៈកម្មាធិការបានស៊ើបអង្កេត និងប្រមូលព័ត៌មាន ព្រមទាំងបានចុះទៅធ្វើការសម្រុះសម្រួលនៅនឹងផ្ទះរបស់យាយ ជាច្រើនលើកច្រើនសា ប៉ុន្តែមិនទទួលបានលទ្ធផលល្អឡើយ ។ ដោយអស់លទ្ធភាពក្នុងការសម្រុះសម្រួល គណៈកម្មាធិការបានសម្រេចបញ្ជូនករណីទំនាស់នេះទៅតុលាការតាមការស្នើសុំរបស់យាយ ។

## ៣.៤.៦. ការតាមដាន និងការផ្សះផ្សា



ការតាមដាន និងផ្សះផ្សា គឺជាជំហានមួយដែលមានសារៈសំខាន់បំផុតនៅក្នុងការកាត់បន្ថយទំនាស់ និងទប់ស្កាត់នូវរាល់ករណីទំនាស់កុំឱ្យរីករាលដាលកាន់តែធំ ។ ការចុះតាមដាន និងផ្សះផ្សានឹងជួយកាត់បន្ថយនូវភាពតានតឹង ដែលកើតមាននៅក្នុងសហគមន៍ ព្រមទាំងចូលរួមចែកចាយព័ត៌មានមកដល់សហគមន៍វិញផងដែរ ។ ការចែកចាយព័ត៌មានទៅប្រជាពលរដ្ឋ និងការតាមដានទៅលើភាគីទំនាស់នឹងអាចទប់ស្កាត់បាននូវពាក្យចចាមអារាម និងបង្កើនការគោរពចំពោះអ្នកសម្រុះសម្រួល ឬអ្នកដោះស្រាយទំនាស់ ឬគណៈកម្មាធិការដោះស្រាយទំនាស់ផងដែរ ។

ដូច្នេះ ដើម្បីទប់ស្កាត់នូវហេតុការណ៍កុំឱ្យឆាបឆេះឡើងសាជាថ្មី បន្ទាប់ពីការចុះហត្ថលេខានៅក្នុងកិច្ចព្រមព្រៀង អ្នកសម្រុះសម្រួល ឬដោះស្រាយគួរតែតាមដានទៅលើភាគីទំនាស់ ដោយត្រូវប្រាកដថា ភាគីទំនាស់មានការពេញចិត្តនឹងកិច្ចសន្យា ព្រមទាំងអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យានោះ ហើយភាពតានតឹងរបស់ពួកគេត្រូវបានកាត់បន្ថយ ឬលុបបំបាត់ ។

**ឧទាហរណ៍ :** ប្រធានគណៈកម្មាធិការម្នាក់បាននិយាយថា បន្ទាប់ពីសម្រុះសម្រួល និងធ្វើកិច្ចសន្យាហើយ ចាំបាច់ត្រូវធ្វើការតាមដាន ព្រោះភាពតានតឹង ឬករណីទំនាស់អាចកើតឡើងវិញម្តងទៀត។ យើងអាចធ្វើការតាមដានភាគីទំនាស់ តាមរយៈសមាជិកគណៈកម្មាធិការដែលមានអាសយដ្ឋាននៅក្នុងភូមិនោះ ឬមេភូមិ ឬអ្នកស្ម័គ្រចិត្តភូមិ ឬអាចសាកសួរព័ត៌មានពីអ្នកជិតខាង។

ប្រសិនបើ ប្រជាពលរដ្ឋមានការជឿជាក់ថា អ្នកសម្រុះសម្រួល ឬគណៈកម្មាធិការដោះស្រាយទំនាស់អាចដោះស្រាយទំនាស់បានជោគជ័យ និងប្រកបដោយភាពយុត្តិធម៌ នោះពួកគេនឹងមានទំនុកចិត្ត ហើយនឹងស្នើសុំឱ្យគណៈកម្មាធិការជួយដោះស្រាយទំនាស់ឱ្យពួកគេទៀតនៅពេលដែលពួកគេជួបបញ្ហា។

## ៣.៥. ជំនាញផ្សេងៗ

ក្នុងដំណើរការនៃការដោះស្រាយទំនាស់ អ្នកដោះស្រាយទំនាស់ចាំបាច់ត្រូវមានជំនាញផ្សេងៗទៀតដូចជា ជំនាញក្នុងការស្តាប់ ការបរប្រយោគ និងការរៀបប្រយោគឡើងវិញជាដើម។

### ៣.៥.១. ការស្តាប់

ការស្តាប់ត្រូវពឹងផ្អែកទាំងស្រុងទៅលើការឮ និងការសង្កេតនូវអ្វីដែលអ្នកនិយាយបាននិយាយមកកាន់ ដូច្នេះនៅពេលស្តាប់សូមអ្នកទុកការងារផ្ទាល់ខ្លួនមួយឡែកសិន ហើយផ្ចង់ស្មារតី និងយកចិត្តទុកដាក់ស្តាប់អ្នកនិយាយដោយការគោរព និងសុភាពរាបសារ។ ការស្តាប់ដែលល្អនឹងជួយដល់អ្នកស្តាប់ឱ្យទទួលបាននូវព័ត៌មានច្បាស់លាស់ត្រឹមត្រូវ និងស្វែងរកមូលហេតុនៃបញ្ហា ឬអាចដោះស្រាយបញ្ហានានាបានផងដែរ។

ដើម្បីឱ្យក្លាយជាអ្នកស្តាប់ដែលល្អ អ្នកស្តាប់ត្រូវពិចារណាលើចំណុចដែលត្រូវអនុវត្ត និងចំណុចដែលមិនត្រូវអនុវត្តនៅពេលស្តាប់ដូចខាងក្រោម :

#### ក). ចំណុចដែលត្រូវអនុវត្តនៅពេលស្តាប់

ដើម្បីឱ្យក្លាយជាអ្នកស្តាប់ដែលល្អ អ្នកស្តាប់ត្រូវ :

- បង្ហាញនូវចំណូលចិត្តក្នុងការស្តាប់ ដោយផ្តោតការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន
- មើលមុខអ្នកនិយាយ និងរក្សាទំនាក់ទំនងក្រសែភ្នែក
- ខិតខំស្វែងយល់ ធ្វើចិត្តឱ្យត្រជាក់ និងស្តាប់ដោយគោរព
- បង្ហាញនូវការយកចិត្តទុកដាក់ និងធ្វើសញ្ញាផ្សេងៗដូចជា ងក់ក្បាលពេលអ្នកយល់ព្រមជាដើម
- សួរសំណួរដើម្បីបំភ្លឺ
- និយាយបញ្ជាក់ឡើងវិញនូវអ្វីដែលអ្នកនិយាយបាននិយាយ

#### ខ). ចំណុចដែលត្រូវចៀសវាងនៅពេលស្តាប់

- និយាយកាត់ ឬប្រកែកគ្នា
- វិនិច្ឆ័យរហ័សពេក មុនពេលទទួលបានព័ត៌មានពេញលេញ

- មើលស្រាលចំពោះអ្នកនិយាយ ឬគិតថាខ្លួនមានចំណេះដឹងច្រើនជាង ឬមានអំណាចធំជាង
- ស្តាប់ដោយទោសៈ ដែលតែងតែឆ្លើយតបទៅអ្នកនិយាយវិញបែបអវិជ្ជមាន
- ផ្តល់ការណែនាំ ឬដំបូន្មានទៅអ្នកនិយាយដោយគ្មានសំណូមពរពីអ្នកនិយាយ
- បញ្ចេញអាកប្បកិរិយាមិនសមរម្យ
- ផ្តោតអារម្មណ៍លើបញ្ហាផ្សេង
- ភ្នែកសម្លឹងទៅកន្លែងផ្សេង
- សួរសំណួរក្រៅប្រធានបទ

## ៣.៥.២. ការបរប្រយោគ

ការបរប្រយោគ គឺការរៀបចំនិយាយឡើងវិញដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួន បន្ទាប់ពីស្តាប់គំនិតយោបល់របស់អ្នកនិយាយបាននិយាយ ដោយប្រើពាក្យពេចន៍ផ្សេងៗ ប៉ុន្តែត្រូវរក្សាខ្លឹមសារដដែលដើម្បីឱ្យងាយយល់។ ការបរប្រយោគជួយយើងឱ្យចៀសផុតពីការយល់ខុស និងកាត់បន្ថយនូវស្ថានភាពដែលអាចធ្វើឱ្យការទំនាក់ទំនងកាន់តែតានតឹងឡើង។ ចំនួនព័ត៌មានដែលអ្នកស្តាប់ធ្វើការបរប្រយោគអាចមានចំនួនតិចជាងព័ត៌មានដែលអ្នកនិយាយបាននិយាយ ព្រោះអ្នកស្តាប់មានគោលបំណងសង្ខេបនូវគំនិតសំខាន់ៗដែលអ្នកនិយាយបាននិយាយ។ ការបរប្រយោគជាមធ្យោបាយដ៏មានប្រយោជន៍មួយដើម្បីពិនិត្យ និងធ្វើឱ្យប្រាកដថា អ្នកស្តាប់ពិតជាបានយល់នូវអ្វីដែលអ្នកនិយាយចង់ប្រាប់។

ដើម្បីធ្វើការបរប្រយោគ អ្នកត្រូវកំណត់ឱ្យច្បាស់នូវគំនិត ឬចំណុចដែលសំខាន់ៗ ដែលអ្នកនិយាយបាននិយាយ ហើយនិយាយឡើងវិញនូវគំនិត ឬខ្លឹមសារទាំងនោះដោយប្រើពាក្យពេចន៍ផ្ទាល់ខ្លួន។ ជាចំណុចសំខាន់មួយ គឺអ្នកត្រូវធ្វើឱ្យការបរប្រយោគឱ្យមានលក្ខណៈប្រាកដប្រជា ដូច្នេះដើម្បីធានាឱ្យខ្លឹមសារនៃគំនិត ឬទស្សនៈដែលអ្នកបានបរប្រយោគដូចគ្នាទៅនឹងខ្លឹមសារដែលអ្នកនិយាយបាននិយាយ នោះអ្នកមិនត្រូវបញ្ចូលនូវការយល់ឃើញរបស់ខ្លួន ឬបំភ្លេចចោលនូវគំនិតយោបល់មួយចំនួនដែលមានសារៈសំខាន់ឡើយ។

**ឧទាហរណ៍១ :**

អ្នកនិយាយ : ពីពេលមុនភរិយារបស់ខ្ញុំបានប្រើពាក្យសម្តីមិនសមរម្យទៅលើភរិយាអ្នកជិតខាងខ្ញុំ ហើយក្រោយមក ខ្ញុំបានចាក់ដីបន្ថែមលើដីលំនៅស្ថានខ្ញុំដើម្បីកុំឱ្យវាដក់ទឹកពេលរដូវភ្លៀង។ ការចាក់ដីនេះធ្វើឱ្យដីរបស់ខ្ញុំ ខ្ពស់ជាងដីអ្នកជិតខាងខ្ញុំប្រហែលកន្លះម៉ែត្រ។ ដោយសារតែបញ្ហានេះហើយបានជាអ្នកជិតខាងខ្ញុំធ្វើដំណើរទៅផ្ទះប្រធានភូមិ ហើយប្តឹងខ្ញុំតែម្តង។

អ្នកបរប្រយោគ : ដោយសារតែធ្លាប់មានបញ្ហាជាមួយគ្នាពីមុនមក បានជាអ្នកជិតខាងអ្នកទៅប្តឹងប្រធានភូមិនៅពេលអ្នកចាក់ដីបន្ថែមនៅលើដីភូមិរបស់អ្នកដែលមានកម្ពស់ខ្ពស់ជាដីរបស់គេ។

**ឧទាហរណ៍២ :**

អ្នកនិយាយ : ខ្ញុំមិនសុខចិត្តទេ ព្រោះកាលមេភូមិចែកដីឱ្យខ្ញុំ គឺដីរបស់ខ្ញុំប្រវែង៥០ម៉ែត្រក្បាល និងបណ្តោយ១០០ម៉ែត្រ ប៉ុន្តែវាបានបង្ខិតភ្លឺស្រែចូលក្នុងដីរបស់ខ្ញុំអស់ជាង១០ម៉ែត្រ។

អ្នកបរប្រយោគ : អ្នកមីងមិនសុខចិត្ត ព្រោះគេបានបង្ហិតភ្លឺស្រែចូលដីអ្នកមីងជាង១០ម៉ែត្រ ។

## ៣.៥.៣. ការរៀបប្រយោគឡើងវិញ

ការរៀបប្រយោគឡើងវិញ គឺជាដំណើរការនៃការផ្លាស់ប្តូររបៀបគិត និងនិយាយ ដោយរក្សានូវខ្លឹមសារសំខាន់ៗ ប៉ុន្តែមានទំនោរទៅរកការកាត់បន្ថយនូវការវាយប្រហារ និងបង្កើនភាពវិជ្ជមានដើម្បីដោះស្រាយទំនាស់ ។ ការរៀបប្រយោគឡើងវិញអាចធ្វើឡើងដោយភាគីទំនាស់នីមួយៗ ឬជាការប្រសើរគួរមានភាគីអព្យាក្រឹតទី៣ដែលជាអ្នកសម្រុះសម្រួល ។

គោលបំណងនៃការរៀបប្រយោគឡើងវិញ គឺដើម្បីរំកិលអំពីទំនាក់ទំនងអវិជ្ជមាន ដែលចេញពីការស្តីបន្ទោសចោទប្រកាន់ គំរោះគំរើយ ទៅរកស្ថានភាពមួយមានលក្ខណៈវិជ្ជមាន ដែលធ្វើឱ្យភាគីម្ខាងទៀតអាចទទួលយកបាន ។

ដំណើរការនៃការរៀបប្រយោគឡើងវិញ អាចអនុវត្តភ្លាមៗប្រសិនបើភាគីទំនាស់អាចទទួលយកនូវការរៀបប្រយោគឡើងវិញ ប៉ុន្តែវាអាចចំណាយពេលច្រើន ប្រសិនបើភាគីទំនាស់មិនទាន់ទទួលយក ។ នៅក្នុងករណីជាច្រើនភាគីទំនាស់មិនបានយល់អំពីលក្ខណៈពិតប្រាកដនៃទំនាស់ ដោយពួកគេគ្រាន់តែដឹងថា ពួកគេកំពុងខឹង ពួកគេទទួលរងនូវការរំលោភបំពាន ពួកគេត្រូវការឱ្យមានការដាក់ទោសទៅលើភាគីម្ខាងទៀតជាដើម ។ ដោយមានជំនួយពីអ្នកសម្រុះសម្រួល ភាគីទំនាស់អាចមានឱកាសក្នុងការកំណត់បាននូវមូលហេតុនៃទំនាស់ ហើយភាគីនីមួយៗអាចស្វែងយល់អំពីគ្នាទៅវិញទៅមក ។ ចំណុចទាំងនេះជួយឱ្យភាគីទំនាស់ទាំងអស់ចាប់ផ្តើមគិតអំពីដំណោះស្រាយនៃទំនាស់ ។

នៅពេលអនុវត្តការរៀបប្រយោគឡើងវិញ អ្នកសម្រុះសម្រួលត្រូវគិតពិចារណាលើសមាសភាគមួយចំនួនដូចខាងក្រោម :

- ទទួលយក និងប្រើគំនិតខ្លះៗរបស់អ្នកនិយាយ
- ដកចេញនូវអត្ថន័យដែលមានលក្ខណៈអវិជ្ជមាន ការរំលោភបំពាន ឬការវាយប្រហារជាដើម
- និយាយគំនិត ឬយោបល់នោះឡើងវិញដោយប្រើពាក្យវិជ្ជមាន
- ផ្ទៀងផ្ទាត់ជាមួយម្ចាស់សារ អំពីប្រយោគរបស់អ្នក

**ឧទាហរណ៍១**

អ្នកនិយាយ : "គេនិយាយផ្សេង តែធ្វើផ្សេង"

អ្នករៀបប្រយោគ : "លោកនិយាយនេះចង់មានន័យថា គាត់គួរតែមានភាពទៀងទាត់ជាងនេះ មែនទេ?"

**ឧទាហរណ៍២**

អ្នកនិយាយ : "គេចេះតែចង់ឱ្យខ្ញុំធ្វើនេះ ធ្វើនោះ ប៉ុន្តែគេមិនដែលបង្រៀនខ្ញុំឡើយ"

អ្នករៀបប្រយោគ : "អ្នកចង់ស្នើឡើងថា ប្រសិនបើគេបង្រៀនអ្នក អ្នកនឹងធ្វើកិច្ចការនោះមែនទេ?"

**ឧទាហរណ៍៣**

អ្នកនិយាយ : "រោងចក្ររបស់គេបង្កឱ្យមានការប៉ះពាល់ដល់សុខភាពកូនចៅ និងប្រជាពលរដ្ឋក្នុងភូមិយើង"

អ្នករៀបប្រយោគ : "ដូច្នេះ អ្នកមានការបារម្ភអំពីសុខភាពរបស់កូនចៅ និងអ្នកភូមិដោយសាររោងចក្រ"។

**ទម្រង់គំរូពាក្យបណ្ដឹង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................... អាយុ.........ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ក្រុមទី........ ភូមិ................... ឃុំ/សង្កាត់............................... ស្រុក/ខណ្ឌ........................ ខេត្ត/ក្រុង........................។

**សូមគោរពចូលមក**

..................................................................

**តាមរយៈ :**.......................................................................................................................................

**កម្មវត្ថុ :** សុំប្ដឹងឈ្មោះ................................ ភេទ............ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ក្រុមទី.......... ភូមិ.................. ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ................. ខេត្ត/ក្រុង.................ពីបទ.................។

តាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបលោក/លោកស្រីជា................................................ មេត្តាជ្រាបថា កាលពីថ្ងៃទី........ ខែ........ ឆ្នាំ.............. វេលាម៉ោង............. ឈ្មោះ.................បាន................

..............................................................................................................................................

........................................(បរិយាយអំពីករណីទំនាស់).......................................................................

..............................................................................................................................................

........................................................................................................។

អាស្រ័យហេតុនេះ សូមលោក/លោកស្រី មេត្តាជួយដោះស្រាយ និងរកយុត្តិធម៌ឱ្យខ្ញុំបាទ/នាងខ្ញុំដោយក្ដីអនុគ្រោះ។

សូមលោក/លោកស្រីទទួលនូវការគោរពអំពីខ្ញុំបាទ/នាងខ្ញុំ។

ធ្វើនៅ....................... ថ្ងៃទី......... ខែ........... ឆ្នាំ.............

ហត្ថលេខា/ស្នាមមេដៃដើមចោទ

ឈ្មោះ..............................

ទម្រង់គំរូកិច្ចសន្យា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា

យោងតាមការដោះស្រាយទំនាស់របស់.................................. លើករណីទំនាស់អំពី........................ យើងខ្ញុំឈ្មោះ................................. អាយុ...........ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ............... ក្រុមទី........ ភូមិ................ ឃុំ/សង្កាត់...................... ស្រុក/ខណ្ឌ.................... ខេត្ត/ក្រុង.................... ហៅថាភាគី "ក" និង ឈ្មោះ...................... អាយុ...........ឆ្នាំ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ............ ក្រុមទី........... ភូមិ.................... ឃុំ/សង្កាត់................................ ស្រុក/ខណ្ឌ........................ ខេត្ត/ក្រុង........................... ហៅថាភាគី "ខ"

**យល់ព្រមធ្វើកិច្ចសន្យាតាមលក្ខខណ្ឌដូចខាងក្រោម :**

លក្ខខណ្ឌសម្រាប់ភាគី "ក"

១. ........................................................................................................................

២. ........................................................................................................................

៣. ........................................................................................................................

...

លក្ខខណ្ឌសម្រាប់ភាគី "ខ"

១. ........................................................................................................................

២. ........................................................................................................................

៣. ........................................................................................................................

...

ប្រសិនបើភាគីណាមួយមិនគោរព និងអនុវត្តតាមលក្ខខណ្ឌដូចមានចែងខាងលើ ភាគីនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

យើងខ្ញុំសូមផ្ដិតមេដៃទុកជាភស្តុតាងនៃការព្រមព្រៀងនេះ។

ធ្វើនៅ....................... ថ្ងៃទី......... ខែ.......... ឆ្នាំ..............

| សាក្សី | ស្នាមមេដៃភាគី "ក" | ស្នាមមេដៃភាគី "ខ" |
|---|---|---|
| ឈ្មោះ.................... | ឈ្មោះ.................... | ឈ្មោះ.................... |

# ផ្នែកទី៤
# យន្តការសម្រុះសម្រួលទំនាស់
# នៅថ្នាក់ឃុំ សង្កាត់

# ផ្នែកទី៤
# យន្តការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់

ក្នុងផ្នែកនេះនឹងបរិយាយអំពីយន្តការដោះស្រាយទំនាស់នៅថ្នាក់ឃុំ សង្កាត់ ព្រមទាំងករណីទំនាស់នានាដែលអាចធ្វើការសម្រុះសម្រួលបាន និងទំនាស់ដែលមិនអាចធ្វើការសម្រុះសម្រួលបាននៅថ្នាក់ឃុំ សង្កាត់ ។

យន្តការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់អាចមានដូចជា :

- ឃុំ សង្កាត់
- គណៈកម្មាធិការដោះស្រាយទំនាស់
- ថ្នាក់ដឹកនាំភូមិ
- អ្នកមានឥទ្ធិពលក្នុងភូមិ

## ៤.១. ឃុំ សង្កាត់



ឃុំ សង្កាត់ត្រូវបានផ្តល់ជូននូវសមត្ថកិច្ច ក្នុងការជួយសម្រុះសម្រួលនូវរាល់ករណីទំនាស់ដែលមានលក្ខណៈជាឯកជន រវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋដែលកើតមាននៅក្នុងឃុំ សង្កាត់របស់ខ្លួន។ នៅក្នុងឃុំ សង្កាត់អាចមានករណីទំនាស់ជាច្រើនរូបភាព ដូចជា ទំនាស់ដីធ្លី អំពើហិង្សាក្នុងគ្រួសារ អំពើចោរកម្ម ទំនាស់រវាងប្តីប្រពន្ធ ការរំលោភ ការវាយដំ ការកាប់សម្លាប់ ព្រមទាំងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ និងបទល្មើសរដ្ឋប្បវេណីផ្សេងៗទៀត។ នៅក្នុងចំណោមទំនាស់ទាំងនេះ មានទំនាស់មួយចំនួនឃុំ សង្កាត់អាចធ្វើការសម្រុះសម្រួលបាន ប៉ុន្តែមានទំនាស់មួយចំនួនឃុំ សង្កាត់មិនមានសមត្ថកិច្ចក្នុងការដោះស្រាយឡើយ ។

### ក). ករណីបទល្មើសរដ្ឋប្បវេណី

ឃុំ សង្កាត់មានសមត្ថកិច្ចសម្រុះសម្រួលនូវរឿងរ៉ាវដែលទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី។ ករណីរដ្ឋប្បវេណីជាទូទៅជាករណីដែលទាក់ទងទៅនឹងសិទ្ធិ ការទូទាត់សំណង ទំនាស់រវាងប្តីប្រពន្ធដែលមិនបង្កបួសស្នាម ទំនាស់ដីធ្លីដែលគ្មានអំពើហិង្សា ឬទំនាស់នានាដែលមិនឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាដើម។

**ឧទាហរណ៍ :**

- **ករណីទំនាស់ដីធ្លី :** ឃុំ សង្កាត់អាចសម្រុះសម្រួល និងដោះស្រាយលើករណីទំនាស់ដីធ្លីដែលគ្មានអំពើហិង្សា ប៉ុន្តែពួកគេមិនអាចធ្វើការកាត់សេចក្តីបានទេ។ ទោះជាយ៉ាងណាក៏ដោយ រាល់កិច្ចព្រមព្រៀងត្រូវមានចុះហត្ថលេខា ឬផ្តិតមេដៃដោយស្ម័គ្រចិត្តពីគ្រប់ភាគីទំនាស់ទាំងអស់ ។

- **ករណីទំនាស់ក្នុងគ្រួសារ :** ក្នុងករណីមានទំនាស់ក្នុងគ្រួសារកើតឡើង ហើយមិនបានឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឃុំ សង្កាត់អាចធ្វើការសម្រុះសម្រួលរាល់ករណីទំនាស់ទាំងនោះបាន។ ប៉ុន្តែប្រសិនបើទំនាស់រវាងប្តីប្រពន្ធនោះឈានដល់ការប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ នោះឃុំ សង្កាត់អាចធ្វើអន្តរាគមន៍ជាបន្ទាន់ដើម្បីទប់ស្កាត់និងការពារជនរងគ្រោះ ធ្វើកំណត់ហេតុអំពីករណីអំពើហិង្សា បញ្ជូនជនរងគ្រោះទៅកាន់កន្លែងមានសុវត្ថិភាព និងចេញសេចក្តីសម្រេចរដ្ឋបាលដើម្បីការពារសន្តិសុខជនរងគ្រោះជាដើម។

### ខ). ករណីបទល្មើសព្រហ្មទណ្ឌ :

បទល្មើសព្រហ្មទណ្ឌជាទូទៅ គឺជាករណីដែលមានការទាក់ទងទៅនឹងអំពើហិង្សា ប្លន់ លួច ការបង្ក របួសស្នាម ការរំលោភលើទំនុកចិត្ត ការរំលោភលើរូបរាងកាយ ការកាប់សម្លាប់ ការជួញដូរមនុស្ស ការធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ឬប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈជាដើម ដែលករណីទាំងនេះ គឺជាសមត្ថកិច្ចរបស់នគរបាល និងតុលាការ។ ប៉ុន្តែ ឃុំ សង្កាត់អាចធ្វើការតាមដាននូវរាល់ករណីបទល្មើសព្រហ្មទណ្ឌទាំងនេះបាន។ យោងមាត្រា៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មេឃុំ ចៅសង្កាត់ បំពេញតួនាទីជាផ្លូវការដូចនគរបាលយុត្តិធម៌។ ដូចនេះ មេឃុំ ចៅសង្កាត់អាចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការស៊ើបអង្កេតទៅលើករណីទំនាស់ ស្នើឱ្យនគរបាលធ្វើការឃាត់ខ្លួន និងចូលធ្វើអន្តរាគមន៍នៅពេលមានបទល្មើសព្រហ្មទណ្ឌ។ ទោះជាយ៉ាងណាក៏ដោយ ក៏ឃុំ សង្កាត់មិនមានសមត្ថកិច្ចក្នុងការសម្រុះសម្រួលទំនាស់ដែលពាក់ព័ន្ធទៅនឹងករណីព្រហ្មទណ្ឌឡើយ។ ឃុំ សង្កាត់អាចជួយដល់នគរបាល និងតុលាការក្នុងការស៊ើបអង្កេត តាមដាននូវករណីដែលកើតមាននៅក្នុងឃុំសង្កាត់របស់ខ្លួន ដើម្បីកាត់បន្ថយនូវភាពតានតឹង ឬជួយនាំភាគីទំនាស់ទៅកាន់តុលាការ ឬធ្វើការទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នដទៃទៀតដើម្បីជួយដល់ពលរដ្ឋ។ ការជួយដល់ប្រជាពលរដ្ឋ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងតួនាទីរបស់ឃុំ សង្កាត់ និងជាសេវាកម្មមួយដែលពួកគាត់ត្រូវផ្តល់ជូនប្រជាពលរដ្ឋ។

## ៤.២. គណៈកម្មាធិការដោះស្រាយទំនាស់

### ៤.២.១. អំពីគណៈកម្មាធិការដោះស្រាយទំនាស់

យោងមាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា :

- មេឃុំចៅសង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់។
- គណៈកម្មាធិការខាងលើនេះអាចយកសមាជិកណាម្នាក់ក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យធ្វើជាប្រធានក៏បាន ឬអាចយកប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតណាម្នាក់ក្នុងឃុំ សង្កាត់របស់ខ្លួនក្រៅពីសមាជិកក្រុមប្រឹក្សាឱ្យធ្វើជាប្រធានក៏បាន។

ផ្អែកលើខ្លឹមសារច្បាប់ខាងលើ ឃុំ សង្កាត់មានសិទ្ធិគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមានគណៈកម្មាធិការដោះស្រាយទំនាស់ ដើម្បីជួយសម្រុះសម្រួលទំនាស់នានាដែលកើតមានក្នុងឃុំ សង្កាត់របស់ខ្លួន ។

## ក). និយមន័យ

គណៈកម្មាធិការដោះស្រាយទំនាស់ គឺជាគណៈកម្មាធិការមួយ ដែលឃុំសង្កាត់បង្កើតឡើង ដើម្បីជួយឃុំ សង្កាត់ក្នុងការសម្រុះសម្រួលនូវករណីទំនាស់មួយចំនួន ដែលកើតមាននៅក្នុងឃុំ សង្កាត់ប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ហើយស្វះស្វែងតាមដានទៅលើករណីទំនាស់នានា និងជួយជំរុញឱ្យភាគីទំនាស់អនុវត្តកិច្ចព្រមព្រៀងដែលបានកំណត់ ព្រមទាំងជួយបញ្ជូននូវរាល់ករណីទំនាស់ណា ដែលមិនអាចសម្រុះសម្រួលបានទៅស្ថាប័នពាក់ព័ន្ធដទៃទៀត ។




## ខ). សារៈប្រយោជន៍នៃការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់

ការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់នៅក្នុងឃុំ សង្កាត់អាចផ្តល់សារៈប្រយោជន៍មួយចំនួនដូចខាងក្រោម :

- អាចជួយសម្រុះសម្រួលទំនាស់បានទាន់ពេលវេលា ព្រោះសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ ជាអ្នករស់នៅក្នុងឃុំ សង្កាត់ ដែលចាត់ទុកថា ជាអ្នកដែលរស់នៅជិតប្រជាពលរដ្ឋបំផុត
- ប្រជាពលរដ្ឋអាចកាត់បន្ថយការចំណាយពេលវេលា និងធនធានក្នុងការស្វែងរកជំនួយពីខាងក្រៅដើម្បីដោះស្រាយករណីទំនាស់របស់ពួកគេ
- ស្របពេលជាមួយគ្នានេះដែរ ការគ្រប់គ្រងឃុំ សង្កាត់ គឺជាការងារដែលត្រូវប្រើប្រាស់ពេលវេលាច្រើន ហើយពេលខ្លះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាចមានពេលវេលា និងធនធានមិនគ្រប់គ្រាន់ដើម្បីសម្រុះសម្រួលទំនាស់ដោយពួកគេផ្ទាល់ទេ។ ដូច្នេះការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ ជាការផ្តល់ឱកាសដល់អ្នករស់នៅក្នុងមូលដ្ឋានចូលរួមក្នុងការសម្រុះសម្រួលទំនាស់ ដែលកើតមាននៅក្នុងមូលដ្ឋានរបស់ពួកគេ និងជួយសម្រាលបន្ទុកការងាររបស់ឃុំ សង្កាត់ផងដែរ ។

## គ). លក្ខណសម្បត្តិនៃសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់

ក្នុងការជ្រើសរើសសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវពិចារណាលើលក្ខណសម្បត្តិមួយចំនួនដូចខាងក្រោម :

- ជាអ្នកដែលមានការយល់ដឹងអំពីបញ្ហា ឬទំនាស់នានា
- ជាអ្នកដែលប្រជាពលរដ្ឋជឿទុកចិត្ត និងហ៊ានប្រាប់អំពីបញ្ហារបស់ពួកគេដោយចំហ
- ជាអ្នកដែលមានសិទ្ធិអំណាចក្នុងការសម្រុះសម្រួលទំនាស់ដូចជា មេឃុំ ចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង

សមាជិកក្រុមប្រឹក្សាឃុំ មេភូមិ ឬប្រជាពលរដ្ឋដែលមានឥទ្ធិពលក្នុងឃុំ សង្កាត់ជាដើម

- ជាអ្នកដែលមានជំនាញ ចំណេះដឹង និងបទពិសោធន៍មូលដ្ឋានក្នុងការសម្រុះសម្រួលទំនាស់
- ជាអ្នកដែលរស់នៅជាអចិន្ត្រៃយ៍ក្នុងឃុំ សង្កាត់
- ជាអ្នកមានចំណេះដឹងទាក់ទងនឹងច្បាប់នានា (បើអាចរកបាន)

## ឃ). សមាសភាពគណៈកម្មាធិការដោះស្រាយទំនាស់

សមាសភាពគណៈកម្មាធិការដោះស្រាយទំនាស់អាចមានដូចជា មេឃុំ ចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ មេភូមិ ចាស់ព្រឹទ្ធាចារ្យ តំណាងស្ត្រី អ្នកដឹកនាំសាសនានានា អ្នកដឹកនាំឬតំណាងជនជាតិដើមភាគតិច នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំសង្កាត់ គ្រូបង្រៀន និងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ផងដែរ។ ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់អាចជាមេឃុំ ចៅសង្កាត់ ឬមិនមែនជាមេឃុំ ចៅសង្កាត់។ ក្នុងការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវរៀបចំប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីកំណត់អំពីចំនួនសមាជិក និងសមាសភាពគណៈកម្មាធិការ ហើយចេញសេចក្តីសម្រេចតែងតាំង (ដោយអនុវត្តតាមសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ខែវិច្ឆិកា ឆ្នាំ២០០៥)។

**ឧទាហរណ៍ :**

នៅក្នុងឃុំមួយ មានភូមិចំនួន៤គឺ ភូមិ"ក" ភូមិ"ខ" ភូមិ"គ" និងភូមិ"ឃ"។ ក្រុមប្រឹក្សាឃុំនេះបានបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ដែលមានសមាសភាពដូចខាងក្រោម :

- មេឃុំ ជាប្រធាន
- ជំទប់ទី២ ជាអនុប្រធាន
- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ លេខាធិការ
- មេភូមិ ឬអនុប្រធានភូមិគ្រប់ភូមិ ជាសមាជិក
- ព្រះសង្ឃ ជាសមាជិក
- អាចារ្យវត្ត ជាសមាជិក
- តំណាងប្រជាពលរដ្ឋ ជាសមាជិក

តាមសមាសភាពខាងលើនេះមានន័យថា នៅពេលមានករណីទំនាស់កើតឡើងនៅក្នុងភូមិ"ក" សមាសភាពគណៈកម្មាធិការដែលត្រូវចូលរួមដោះស្រាយរួមមាន ប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មាធិការ ព្រមទាំងសមាជិកដែលមកពីភូមិ"ក"ដូចជា មេភូមិ ឬអនុប្រធានភូមិ"ក" ព្រះសង្ឃ ឬអាចារ្យវត្ត ឬតំណាងប្រជាពលរដ្ឋនៅក្នុងភូមិ "ក"។ ដូចគ្នាដែរ ប្រសិនករណីទំនាស់កើតឡើងនៅក្នុងភូមិ"ខ" នោះសមាសភាពគណៈកម្មាធិការរួមមាន ប្រធាន អនុប្រធាន និងលេខាធិការនៃគណៈកម្មាធិការ ព្រមទាំងសមាជិកដែលមកពីភូមិ "ខ" ដូចជា មេភូមិ ឬអនុប្រធានភូមិ"ខ" ព្រះសង្ឃ ឬអាចារ្យវត្ត ឬតំណាងប្រជាពលរដ្ឋនៅក្នុងភូមិ "ខ"។

ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់អាចអញ្ជើញមេភូមិ ឬអនុប្រធានភូមិ ឬព្រះសង្ឃ ឬអាចារ្យវត្ត ឬអ្នកមានឥទ្ធិពលមកពីភូមិដទៃក្នុងឃុំ សង្កាត់របស់ខ្លួនដែលមានសមត្ថភាព និងដែលជាសមាជិកគណៈកម្មាធិការមកជួយដោះស្រាយទំនាស់ដែលកើតឡើងក៏បាន។

រចនាសម្ព័ន្ធនៃគណៈកម្មាធិការដោះស្រាយទំនាស់ រួមមាន :

- ប្រធាន ០១រូប
- អនុប្រធាន ០១រូប
- លេខាធិការ ០១រូប
- អ្នកដែលនៅសល់ គឺជាសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់

## ៤.២.២. គោលការណ៍ និងតួនាទីរបស់គណៈកម្មាធិការដោះស្រាយទំនាស់

### ក). គោលការណ៍របស់គណៈកម្មាធិការដោះស្រាយទំនាស់

ក្នុងការបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិចារណាលើគោលការណ៍មួយចំនួនដូចខាងក្រោម :

- ត្រូវមានតំណាងពីក្រុមផ្សេងៗគ្នាក្នុងសង្គម ដើម្បីបង្កើតនូវភាពជាម្ចាស់ក្នុងដំណើរការសម្រុះសម្រួលទំនាស់ និងការធ្វើសេចក្តីសម្រេចចិត្តដូចជា តំណាងស្ត្រី តំណាងជនជាតិដើមភាគតិច អ្នកដឹកនាំសាសនាជាដើម។
- ត្រូវមានការទុកចិត្តពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវធ្វើការសម្រុះសម្រួល និងដោះស្រាយទំនាស់ ប្រកបដោយយុត្តិធម៌ អព្យាក្រឹត និងមានតម្លាភាព
- ត្រូវមានការពេញចិត្តពីសហគមន៍
- ត្រូវមានចំណេះដឹងដែលទាក់ទងទៅនឹងបញ្ហានានា ឬច្បាប់ផ្សេងៗ

ប្រសិនបើគ្មានគោលការណ៍ទាំងនេះទេ នោះការសម្រុះសម្រួលទំនាស់នឹងមិនទទួលជោគជ័យ មានភាពលម្អៀង និងមិនស៊ីសង្វាក់គ្នា ហើយជួនកាលអាចនឹងបង្កឱ្យមានទំនាស់កាន់តែធំឡើងៗទៀតផង។

### ខ). តួនាទីនៃគណៈកម្មាធិការដោះស្រាយទំនាស់

គណៈកម្មាធិការដោះស្រាយទំនាស់ មានតួនាទីសំខាន់ៗដូចខាងក្រោម :

- សម្រុះសម្រួលករណីទំនាស់រដ្ឋប្បវេណី ឬបទលហុដែលកើតមានក្នុងឃុំ សង្កាត់ តាមគោលការណ៍ស្ម័គ្រចិត្ត និងប្រកបដោយយុត្តិធម៌ មិនលម្អៀង
- ជួយទប់ស្កាត់ និងការពារនូវរាល់អំពើហិង្សា និងការរំលោភសិទ្ធិមនុស្សនានា
- កាត់បន្ថយនូវភាពតានតឹង និងទប់ស្កាត់នូវរាល់ភាពតានតឹង ឬទំនាស់ដែលអាចនឹងកើតមានឡើងម្តងទៀត
- រក្សាបាននូវទំនាក់ទំនងដ៏ចុះសម្រុងមួយដែលមានរយៈពេលយូរអង្វែងនៅក្នុងសហគមន៍
- ជួយសម្រាលកិច្ចការដល់មេឃុំ ចៅសង្កាត់
- ជួយជំរុញនូវល្បឿននៃដំណើរការសម្រុះសម្រួលទំនាស់នានានៅក្នុងឃុំ សង្កាត់

### គ). ចំណុចដែលគណៈកម្មាធិការដោះស្រាយទំនាស់មិនគួរធ្វើ

ក្នុងការសម្រុះសម្រួលករណីទំនាស់ គណៈកម្មាធិការដោះស្រាយទំនាស់ត្រូវពិចារណា និងជៀសវាងចំណុចមួយចំនួនដូចខាងក្រោម :

- មានភាពលម្អៀងដោយផ្អែកលើនិន្នាការនយោបាយ (គណបក្សនយោបាយ)
- មានតែមនុស្សម្នាក់ប៉ុណ្ណោះជាអ្នកធ្វើសេចក្ដីសម្រេចចិត្ត
- មានការរំពឹងទុកនូវប្រាក់កាស ឬសំណងសម្រាប់សកម្មភាពសម្រុះសម្រួល និងដោះស្រាយ
- មានភាពលម្អៀងទៅលើភាគីណាមួយក្នុងទំនាស់
- ទទួលឥទ្ធិពល ឬអន្តរាគមន៍ពីសំណាក់អ្នកណាម្នាក់

## ៤.២.៣. ការផ្សព្វផ្សាយ

ដើម្បីឱ្យប្រជាពលរដ្ឋដឹងអំពីវត្តមាននៃគណៈកម្មាធិការដោះស្រាយទំនាស់ក្នុងឃុំ សង្កាត់របស់ខ្លួន ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការដោះស្រាយទំនាស់ត្រូវធ្វើការផ្សព្វផ្សាយ។ មធ្យោបាយដែលឃុំ សង្កាត់អាចធ្វើការផ្សព្វផ្សាយបានអាចមានដូចជា :

- បិទផ្សាយលើក្ដារខៀនព័ត៌មាននៅសាលាឃុំ សង្កាត់ ឬទីកន្លែងសាធារណៈនៅក្នុងឃុំ សង្កាត់។
- ផ្សព្វផ្សាយដល់គ្រប់មេភូមិទាំងអស់នៅក្នុងឃុំ សង្កាត់ ដើម្បីផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ។
- តាមរយៈប្រព័ន្ធឧគ្ឃោសនសព្ទ ឬតាមមធ្យោបាយផ្សេងៗទៀត។

**ឧទាហរណ៍** : ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ក្នុងឃុំមួយនៃខេត្តកំពង់ធំ បាននិយាយថា បន្ទាប់ពីក្រុមប្រឹក្សាចេញសេចក្ដីសម្រេចបង្កើតគណៈកម្មាធិការដោះស្រាយទំនាស់មក យើងខ្ញុំបានធ្វើការផ្សព្វផ្សាយជាប្រចាំអំពីវត្តមាននៃគណៈកម្មាធិការដោះស្រាយទំនាស់នេះ។ មធ្យោបាយដែលអាចធ្វើការផ្សព្វផ្សាយបានរួមមាន ការប្រកាសតាមឧគ្ឃោសនសព្ទនៅពេលមានពិធីផ្សេងៗ ផ្សព្វផ្សាយតាមរយៈមេភូមិ អ្នកស្ម័គ្រចិត្តភូមិ។ ប្រសិនបើយើងធ្វើការសម្រុះសម្រួលទំនាស់បានជោគជ័យ និងប្រកបដោយភាពយុត្តិធម៌ មិនលម្អៀង នោះភាគីទំនាស់មានការពេញចិត្តនឹងលទ្ធផល ហើយពួកគេអាចជួយធ្វើការផ្សព្វផ្សាយបន្តបានយ៉ាងច្រើនផងដែរ។

## ៤.៣. ថ្នាក់ដឹកនាំភូមិ

ថ្នាក់ដឹកនាំភូមិរួមមាន មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ គឺជាយន្តការមួយក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់នៅថ្នាក់ភូមិ។ នៅក្នុងសហគមន៍ នៅពេលមានករណីទំនាស់កើតឡើង ភាគីទំនាស់មានទំនោរទៅរកការអន្តរាគមន៍ពីថ្នាក់ដឹកនាំភូមិ។ នៅពេលមានការស្នើសុំអន្តរាគមន៍ មេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិអាចធ្វើការសម្រុះសម្រួល និងដោះស្រាយករណីទំនាស់នោះ ដោយឈរលើមូលដ្ឋាននៃការព្រមព្រៀង និងស្ម័គ្រចិត្តពីគូភាគីទំនាស់។ ពេលខ្លះអ្នកដឹកនាំភូមិអាចធ្វើការសម្រុះសម្រួលទំនាស់ដោយធ្វើការសហការជាមួយអ្នកមានឥទ្ធិពល ឬអ្នកពាក់ព័ន្ធដទៃទៀតក្នុងភូមិ។

## ៤.៤. អ្នកមានឥទ្ធិពលក្នុងភូមិ

ក្រៅពីក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងអ្នកដឹកនាំភូមិដូចដែលបានបរិយាយខាងលើ ការសម្រុះសម្រួលទំនាស់នៅក្នុងសហគមន៍អាចធ្វើឡើងដោយបុគ្គល ឬអ្នកដែលមានឥទ្ធិពលផ្សេងទៀតនៅក្នុងភូមិដូចជា អ្នកស្ម័គ្រចិត្តភូមិ ចាស់ព្រឹទ្ធាចារ្យ ព្រះសង្ឃ អ្នកដឹកនាំសាសនា ឬគ្រូបង្រៀន ឬមន្ត្រីរាជការចូលនិវត្តន៍ជាដើម ។

ដូច្នេះនៅពេលមានករណីទំនាស់កើតឡើង ភាគីទំនាស់អាចមានជម្រើសជាច្រើនក្នុងការស្វែងរកអន្តរាគមន៍ ។ ភាគីទំនាស់អាចសុំការធ្វើអន្តរាគមន៍ដោះស្រាយពីអ្នកមានឥទ្ធិពលក្នុងភូមិ ឬអ្នកដឹកនាំភូមិ ឬគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ ឬឃុំ សង្កាត់ ។

**ឧទាហរណ៍ :** មេឃុំម្នាក់នៅក្នុងខេត្តកំពង់ធំបានបង្ហាញបទពិសោធន៍ថា លំដាប់លំដោយនៃការសម្រុះសម្រួលទំនាស់នៅក្នុងឃុំរបស់គាត់គឺ នៅពេលមានករណីទំនាស់កើតឡើង ភាគីទំនាស់ទៅសុំការធ្វើអន្តរាគមន៍ពីអ្នកស្ម័គ្រចិត្តភូមិ ។ ប្រសិនបើករណីទំនាស់នោះមិនអាចសម្រុះសម្រួលបាន អ្នកស្ម័គ្រចិត្តអាចជួយភាគីទំនាស់ទៅជួបមេភូមិដើម្បីសុំការសម្រុះសម្រួល ប៉ុន្តែប្រសិនបើការសម្រុះសម្រួលមិនទទួលបានជោគជ័យ អ្នកស្ម័គ្រចិត្តភូមិនឹងជួយបញ្ជូនករណីទំនាស់ទៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ ។ មានករណីទំនាស់ភាគច្រើនត្រូវបានសម្រុះសម្រួល និងបញ្ចប់ត្រឹមគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ ប៉ុន្តែក៏មានករណីមួយចំនួនដែលគណៈកម្មាធិការមិនអាចសម្រុះសម្រួលបាន ហើយត្រូវបញ្ជូនទៅមេឃុំ។ កន្លងមកមានពីរ-បីករណីដែលភាគីទំនាស់មិនអាចឈានដល់ការព្រមព្រៀងគ្នានៅថ្នាក់ឃុំ ហើយករណីទំនាស់នោះត្រូវបញ្ជូនទៅតុលាការ ។

## ៤.៥. ទំនាស់ដែលមិនអាចសម្រុះសម្រួល និងដោះស្រាយនៅថ្នាក់ឃុំ សង្កាត់បាន

មេឃុំ ចៅសង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ ថ្នាក់ដឹកនាំភូមិ និងអ្នកមានឥទ្ធិពលក្នុងភូមិ មិនមានសមត្ថកិច្ចក្នុងការ :

- សម្រេចឱ្យប្តី-ប្រពន្ធលែងលះគ្នា
- ដោះស្រាយអំពើហិង្សាក្នុងគ្រួសារដែលមានចរិកលក្ខណៈជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម
- ដោះស្រាយបទល្មើសដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ
- ដោះស្រាយទំនាស់ដែលកំពុងដោះស្រាយដោយតុលាការ ឬដែលមានសេចក្តីសម្រេចពីតុលាការ
- ដោះស្រាយទំនាស់ដែលច្បាប់ ឬដែលរដ្ឋាភិបាលបានកំណត់ឱ្យស្ថាប័ន ឬយន្តការជាក់លាក់ណាមួយសម្រុះសម្រួល ឬដោះស្រាយ ។
- កាត់សេចក្តី ឬវិនិច្ឆ័យភាគីទំនាស់
- ឃុំឃាំងភាគីទំនាស់ណាមួយ
- បង្ខំ ឬបង្គាប់ឱ្យភាគីណាមួយអនុវត្តល័ក្ខខ័ណ្ឌណាមួយ ឬទទួលយកការព្រមព្រៀងណាមួយ... ។ល ។

# ផ្នែកទី៥
# បទពិសោធន៍សម្រុះសម្រួល
# ទំនាស់នៅថ្នាក់ឃុំ សង្កាត់

# ផ្នែកទី៥
# បទពិសោធន៍នៃការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់

## ៥.១. ទំនាស់ដីធ្លី

### ៥.១.១. ទំនាស់ដីធ្លីទ្រង់ទ្រាយតូច



ទំនាស់ដីធ្លីទ្រង់ទ្រាយតូចជាទូទៅ គឺជាទំនាស់ដែលកើតមានទៅលើព្រំប្រទល់ដី ដូចជាការបង្អិតព្រំដីបន្តិចបន្តួច ឬការដណ្តើមភាពជាម្ចាស់កម្មសិទ្ធិដីធ្លី ឬការដាំដើមឈើធ្វើព្រំរបងជាដើម ហើយទំនាស់នេះភាគច្រើនកើតឡើងរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ក្នុងសហគមន៍ច្រើនជាងរវាងប្រជាពលរដ្ឋក្នុងសហគមន៍និងអ្នកមកពីខាងក្រៅ ឬជាមួយភាគីផ្សេងៗទៀត។

ទំនាស់ដីធ្លីទ្រង់ទ្រាយតូចភាគច្រើនកើតឡើងដោយសារមូលហេតុមួយចំនួនដូចខាងក្រោម :

- មិនមានប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី
- កង្វះខាតនូវចំណេះដឹងផ្នែកច្បាប់ភូមិបាល
- ភាពមិនប្រាកដប្រជាទៅលើភាពជាម្ចាស់កម្មសិទ្ធិ
- ភាពមិនប្រាកដប្រជាអំពីព្រំប្រទល់ដី
- ដំណោះស្រាយទំនាស់ពីពេលមុនមិនបានល្អ
- ការកាន់កាប់យកដីធ្លីដោយមិនស្របច្បាប់
- មិនមានការចុះកិច្ចព្រមព្រៀងនៅពេលមានទំនាស់ពីមុន
- ការដាំដើមឈើធ្វើព្រំរបង
- ...។ល។

ដំណើរការនៃការសម្រុះសម្រួល និងដោះស្រាយទំនាស់ដីធ្លីទ្រង់ទ្រាយតូច ត្រូវអនុវត្តតាមជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់ (**អនុវត្តតាមខ្លឹមសារ៣.៤.ជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់**) ដែលរួមមាន :

- ការទទួលពាក្យបណ្តឹង
- ការស៊ើបអង្កេត និងប្រមូលព័ត៌មាន
- ការសម្រុះសម្រួល និងការពិភាក្សា

- រៀបចំកិច្ចព្រមព្រៀង
- ការបញ្ជូនករណីទំនាស់ទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ (បើមិនអាចសម្រុះសម្រួលបាន)
- ការតាមដាន និងការផ្សះផ្សា

## ៥.១.២. ទំនាស់ដីធ្លីទ្រង់ទ្រាយធំ



ទំនាស់ដីធ្លីទ្រង់ទ្រាយធំភាគច្រើន គឺជាទំនាស់ដែលកើតឡើងរវាងក្រុមប្រជាពលរដ្ឋ ឬសហគមន៍ជាមួយនឹងភាគីណាមួយដែលទន្ទ្រានយកដីធ្លី ឬធនធានរួមរបស់ពួកគេក្នុងសហគមន៍ ដូចជា ដីព្រៃ វាលស្មៅ ឬបឹងធម្មជាតិ ដែលប្រជាពលរដ្ឋតែងតែពឹងផ្អែកលើធនធាន និងអនុផលនៃធនធានទាំងនេះដើម្បីចិញ្ចឹមជីវិត។ ជួនកាលទំនាស់អាចកើតឡើងដោយសារក្រុមប្រជាពលរដ្ឋ ឬសហគមន៍ទៅតាំងលំនៅដ្ឋាន ឬប្រកបរបរចិញ្ចឹមជីវិតលើដីធ្លីរបស់ភាគីណាមួយដោយគ្មានការអនុញ្ញាត។ ជាទូទៅទំនាស់ដីធ្លីទ្រង់ទ្រាយធំមានភាពស្មុគស្មាញ និងពិបាកដោះស្រាយជាងទំនាស់ដីធ្លីទ្រង់ទ្រាយតូច។

នៅក្នុងទំនាស់ដីធ្លីទ្រង់ទ្រាយធំ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ និងឃុំ សង្កាត់ជារឿយៗ ដើរតួជាអ្នកតំណាងឱ្យប្រជាពលរដ្ឋក្នុងការស្វែងរកស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយ។ លើសពីនេះទៀតឃុំ សង្កាត់អាចជួយផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធដល់អ្នកដោះស្រាយ សហការក្នុងការស៊ើបអង្កេត និងចូលរួមក្នុងដំណើរការដោះស្រាយផងដែរ។

## ៥.១.៣. បទពិសោធន៍នៃការសម្រុះសម្រួលទំនាស់ដីធ្លីទ្រង់ទ្រាយតូច

### ក). ករណីទំនាស់ទី១

មានក្រុមគ្រួសារពីររស់នៅក្នុងភូមិមួយជាមួយគ្នា។ គ្រួសារទាំងពីរនេះទទួលបានដីស្រែជាប់គ្នា និងមានទំហំ៥០ម៉ែត្រគុណនឹង១០០ម៉ែត្រដូចគ្នា(មិនបានវាស់ទេ ដោយកំណត់យកតាមភ្លឺស្រែដែលមានស្រាប់ធ្វើជាព្រំ)។ គ្រួសារទី១ដែលហៅថា ភាគី "ក" បានជួលដីស្រែនោះឱ្យទៅគ្រួសារមួយទៀតដែលហៅថា ភាគី "ខ" ដើម្បីធ្វើស្រែ។ បន្ទាប់ពីជួលបានមួយរយៈមកភាគី"ខ"បានបង្ខិតភ្លឺស្រែឱ្យចូលក្នុងដីភាគី"ក" ដោយវាស់យកដីចំណែករបស់ខ្លួនឱ្យគ្រប់៥០ម៉ែត្រក្បាល។ នៅពេលឃើញភាគី "ខ"បង្ខិតភ្លឺស្រែដូច្នេះ ភាគី "ក"បានសួរភាគី "ខ" ពីមូលហេតុដែលភាគី "ខ"បង្ខិតភ្លឺស្រែ ប៉ុន្តែភាគី"ខ"ឆ្លើយទៅភាគី"ក"វិញថា ដីរបស់ខ្ញុំចំនួន៥០ម៉ែត្រ ដូច្នេះខ្ញុំវាស់ត្រឹមតែ៥០ម៉ែត្រប៉ុណ្ណោះ។ ការប្រកែកគ្នារវាងភាគីទាំងពីរបានកើតមានឡើង។ បន្ទាប់មកដោយមិនអាចដោះស្រាយបាន ហើយឃើញដីស្រែរបស់ខ្លួននៅសល់តែមួយចំណែកតូច ភាគី"ក"បានមកជួបគណៈកម្មាធិការដោះស្រាយទំនាស់ឃុំដើម្បីដោះស្រាយ។

## ដំណើរការសម្រុះសម្រួល

- **ការទទួលពាក្យបណ្ដឹង** : នៅពេលភាគី"ក"មកជួបគណៈកម្មាធិការដោះស្រាយទំនាស់ដើម្បីសុំជួយធ្វើអន្តរាគមន៍ និងដោះស្រាយ គណៈកម្មាធិការបានតម្រូវឱ្យភាគី"ក"រៀបចំពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ។
- **ការប្រមូលព័ត៌មាន** : បន្ទាប់ពីបានទទួលពាក្យបណ្ដឹង គណៈកម្មាធិការបានសួរនាំអំពីករណីទំនាស់ពីភាគី"ក"។ ប្រធានគណៈកម្មាធិការបានទៅជួបភាគី"ខ" ជួបមេភូមិ និងប្រធានក្រុមដើម្បីប្រមូលព័ត៌មានអំពីទំហំដី និងប្រវត្តិនៃការបែងចែកដីឱ្យភាគីទាំងពីរ។
- **ការសម្រុះសម្រួលនៅថ្នាក់ឃុំ** : បន្ទាប់ពីបានប្រមូលព័ត៌មានចប់សព្វគ្រប់ គណៈកម្មាធិការដោះស្រាយទំនាស់បានកោះអញ្ជើញទាំងភាគី"ក" និងភាគី"ខ" មកជួបគ្នាដើម្បីដោះស្រាយនៅសាលាឃុំ។ គណៈកម្មាធិការបានបញ្ជាក់ទៅភាគីទំនាស់ថា ដីរបស់អ្នកទាំងពីរស្ថិតនៅក្នុងហិកតាតែមួយដែលគេរៀបចំតាំងពីសម័យប៉ុលពតម្ល៉េះ ហើយគ្មាននរណាផ្លាស់ប្ដូរឡើយ។ ទោះបីជាគណៈកម្មាធិការដោះស្រាយទំនាស់ធ្វើការសម្រុះសម្រួលយ៉ាងណាក៏ដោយ ក៏ភាគីទាំងពីរនៅតែអះអាងថា ដីរបស់ខ្លួនមានប្រវែង៥០ម៉ែត្រក្បាលដូចគ្នា។
- **ការចុះវាស់វែង និងសម្រុះសម្រួល** : ដោយមិនអាចធ្វើការសម្រុះសម្រួលបាន គណៈកម្មាធិការដោះស្រាយទំនាស់សម្រេចចុះទៅធ្វើការវាស់វែងនៅនឹងស្រែនោះដោយផ្ទាល់ ដោយមានការចូលរួមពីភាគីទាំងអស់ មេភូមិ និងអ្នកដទៃទៀត។ ផ្អែកលើលទ្ធផលនៃការវាស់វែងឃើញថា ក្បាលដីសរុបរបស់ភាគីទាំងពីរមានត្រឹមតែ៧០ម៉ែត្រប៉ុណ្ណោះ។ ឃើញដូច្នេះ ប្រធានគណៈកម្មាធិការបានធ្វើការសម្រុះសម្រួលជាមួយភាគី"ខ" ដោយនិយាយថា ឥឡូវដីសរុបមានត្រឹមតែ៧០ម៉ែត្រ ប្រសិនបើអ្នកដាច់ខាតយក៥០ម៉ែត្រម្នាក់ឯង តើវាយុត្តិធម៌សម្រាប់ភាគី"ក"ទេ? ហើយអ្នកត្រូវគិតមើលតើភ្លឺស្រែដែលទទួលបានពិតប្រាកដនៅត្រឹមណា? បន្ទាប់ពីពិចារណាមួយសន្ទុះ ភាគី"ខ" ហាក់ដូចជាបង្ហាញថាខ្លួនពិតជាបានបង្កិតភ្លឺស្រែចូលក្នុងដីស្រែភាគី"ក"មែន។ ជាមួយគ្នានោះដែរ ប្រធានគណៈកម្មាធិការបានទៅសម្រុះសម្រួលជាមួយភាគី"ក" ដោយនិយាយដូចគ្នាថា ឥឡូវដីសរុបមានត្រឹមតែ៧០ម៉ែត្រ ប្រសិនបើអ្នកដាច់ខាតយក៥០ម៉ែត្រម្នាក់ឯង តើវាយុត្តិធម៌សម្រាប់ភាគី"ខ"ទេ? បន្ទាប់មកគណៈកម្មាធិការសង្កេតឃើញថា ភាគីទាំងពីរហាក់ដូចជាមានទំនោរទៅរកការសម្រុះសម្រួល ទើបប្រធានគណៈកម្មាធិការលើកជាជម្រើសនៃដំណោះស្រាយថា ឥឡូវដីនេះមានត្រឹមតែ៧០ម៉ែត្រទេ ហើយកុំឱ្យវែងឆ្ងាយក្នុងការប្ដឹងផ្ដល់ទៅតុលាការដែលត្រូវចំណាយពេលវេលា និងសោហ៊ុយអស់ច្រើន ដូច្នេះប្រសិនបើយើងចែកជាពីរចំណែកស្មើគ្នា តើអ្នកទាំងពីរយល់យ៉ាងណាដែរ? ដោយយល់ឃើញថា ការសម្រុះសម្រួលនេះមានលក្ខណៈយុត្តិធម៌ និងអាចទទួលយកបាន ភាគីទាំងពីរព្រមទទួលការបែងចែកចំណែកស្មើគ្នា។ ដោយឃើញភាគីទាំងពីរស្រុះស្រួលគ្នា គណៈកម្មាធិការចាប់ផ្ដើមវាស់ដីស្រែជាពីរចំណែកស្មើគ្នា និងកំណត់បង្គោលព្រំយ៉ាងត្រឹមត្រូវ។

- **ការរៀបចំកិច្ចសន្យា :** បន្ទាប់មកគណៈកម្មាធិការរៀបចំកិច្ចសន្យា ដោយមានការផ្តិតស្នាមមេដៃរបស់ភាគីទាំងពីរទុកជាភស្តុតាង ។

## ១). ករណីទំនាស់ទី២

មានគ្រួសារពីររស់នៅជិតខាងនឹងគ្នា។ គ្រួសារមួយដែលហៅថាភាគី "ក" បានជួលជាងឱ្យទៅធ្វើរបងថ្មព័ទ្ធដីជាប់ជាមួយគ្រួសារមួយទៀតហៅថាភាគី"ខ" ។ នៅពេលកំពុងសាងសង់ ភាគី"ខ" គិតថារបងថ្មីនេះហាក់បីដូចជាខិតចូលក្នុងដីខ្លួន ហើយក៏និយាយ និងជេរដៀមដាមភាគី"ក" ។ ភាគី"ខ"និយាយ និងជេរដដែល១រហូតឮដល់ភាគី"ក" ដែលជាអ្នកសង់របងថ្ម។ ភាគី "ក" បានទៅប្តឹងទៅមេភូមិដើម្បីឱ្យជួយដោះស្រាយ ប៉ុន្តែដោយភាគីទាំងពីរសុទ្ធតែជាសាច់ញាតិរបស់មេភូមិ មេភូមិមិនអាចសម្រុះសម្រួលបាន ក៏បញ្ជូនករណីទំនាស់នេះទៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ ។

### ដំណើរការសម្រុះសម្រួល

- **ការទទួលពាក្យបណ្តឹង :** ភាគី"ក"បានសរសេរពាក្យបណ្តឹង ហើយមកជួបគណៈកម្មាធិការដោះស្រាយទំនាស់ឃុំដើម្បីដាក់ពាក្យបណ្តឹង ។
- **ការប្រមូលព័ត៌មាន :** បន្ទាប់ពីទទួលបានពាក្យបណ្តឹងពីភាគី "ក" គណៈកម្មាធិការដោះស្រាយទំនាស់បានសួរនាំអំពីបញ្ហាដែលកើតឡើង ។ បន្ទាប់មកទៀតបានចាត់ឱ្យសមាជិកគណៈកម្មាធិការម្នាក់ទៅស៊ើបអង្កេត និងប្រមូលព័ត៌មានពីអ្នកជិតខាង មេភូមិ កម្មករសង់របង។ តាមរយៈការប្រមូលព័ត៌មានឃើញថាភាគី"ក"មិនបានបង្ខិតព្រំដីចូលក្នុងដីរបស់ភាគី"ខ"ឡើយ ។ តាមពិតដីរបស់ភាគី"ខ"រួមតូចបន្តិចដោយសារកាលពីប៉ុន្មានឆ្នាំមុន គ្រួសារនៅតាមបណ្តោយផ្លូវខាងកើតផ្ទះភាគី"ខ"បានព្រមព្រៀងបង្ខិតដីរបស់ខ្លួនចំនួនកន្លះម៉ែត្រដើម្បីពង្រីកផ្លូវ ហើយកាលនោះ ភាគី"ខ"ក៏បានឯកភាពដែរ ។
- **ការកោះប្រជុំ :** បន្ទាប់ពីប្រមូលព័ត៌មានចប់សព្វគ្រប់ គណៈកម្មាធិការដោះស្រាយទំនាស់បានកោះអញ្ជើញភាគីទាំងពីរមកសាលាឃុំដើម្បីដោះស្រាយ ។
- **ការសម្រុះសម្រួលនៅសាលាឃុំ :** នៅពេលប្រជុំសម្រុះសម្រួលនៅសាលាឃុំ គណៈកម្មាធិការដោះស្រាយទំនាស់បានលើកឡើងថា ភាគី"ក"បានប្តឹងភាគី"ខ"អំពីបទជេរប្រមាថកេរ្តិ៍ថា ខ្លួន(ភាគី"ក") លួចបង្ខិតព្រំដី តើភាគី"ខ"បាត់ដីមែនទេ? ហើយបានជេរភាគី"ក"មែនទេ? ភាគី"ខ"ឆ្លើយថា បាត់មែនព្រោះក្បាលដីខ្ញុំមានប្រវែង១៦ម៉ែត្រ ឥឡូវបាត់អស់ប្រហែលកន្លះម៉ែត្រ អញ្ចឹងតើអ្នកណាយកក្រៅពីវា (ភាគី"ក") ។ ប្រធាន គណៈកម្មាធិការបានធ្វើការពន្យល់ថា តាមពិតភាគី"ក"មិនបានយកដីរបស់អ្នកទេព្រោះភាគី"ក"ធ្វើរបងនៅលើព្រំដីចាស់ដែលមានស្រាប់ ហើយដីរបស់អ្នកបាត់កន្លះម៉ែត្រនោះដោយសារកាលពីឆ្នាំកន្លងទៅ ឃុំបានពង្រីកផ្លូវជាប់ព្រំដីរបស់អ្នកម្ខាងទៀត ដែលចូលក្នុងដីអ្នកប្រហែលកន្លះម៉ែត្រក្រែងពេលនោះអ្នកបានព្រមព្រៀងដែរតើ!។ គណៈកម្មាធិការបានពន្យល់ទៀតថា នៅពេលអ្នកមិនពេញចិត្តនឹងអ្វីមួយ អ្នកមិនត្រូវជេរគេជេរឯងទេ ព្រោះវាជាបទប្រមាថកេរ្តិ៍ គេអាចប្តឹងឱ្យអ្នកសងជំងឺ

ចិត្តគេបាន។ គណៈកម្មាធិការបានសួរទៅភាគី"ក" តើអ្នកចង់បានអ្វី? ចង់បានជំងឺចិត្តប៉ុន្មាន? ភាគី"ក" ឆ្លើយថា "ចង់វាយវាឱ្យបែកមាត់"។ គ្រាន់តែភាគី"ក"និយាយដូច្នេះ ទំនាស់ពាក្យសម្ដីរវាងភាគីទាំងពីរកើតឡើងម្ដងទៀត ហើយស្ទើរតែឈានដល់ការវាយតប់គ្នាទៀតផង។ គណៈកម្មាធិការឃាត់ ហើយនិយាយថា អ្នកទាំងពីរមកទីនេះដើម្បីឱ្យគណៈកម្មាធិការជួយដោះស្រាយ ហើយប្រសិនបើអ្នកទាំងពីរនៅតែឈ្លោះគ្នាយ៉ាងដូច្នេះ តើគណៈកម្មាធិការអាចធ្វើការសម្រុះសម្រួលយ៉ាងដូចម្ដេច? គណៈកម្មាធិការបានពន្យល់ថា មនុស្សម្នាក់ៗមានសិទ្ធិ ដូច្នេះអ្នកមិនអាចជេរប្រមាថ ឬវាយដំលើអ្នកណាម្នាក់បានឡើយ។ ដោយមានការពន្យល់ និងបញ្ចុះបញ្ចូលរបស់គណៈកម្មាធិការ ភាគី"ខ" យល់ព្រមឈប់ជេរ ហើយភាគី"ក" ក៏មិនទាមទារសំណងជំងឺចិត្តអ្វីពីភាគី"ខ"ដែរ។

- **ការរៀបចំកិច្ចសន្យា :** បន្ទាប់ពីភាគីទាំងពីបានព្រមព្រៀងគ្នាហើយ គណៈកម្មាធិការតម្រូវឱ្យភាគីទាំងពីរធ្វើកិច្ចសន្យាដោយកំណត់ថា ប្រសិនបើភាគីណាមួយជេរបរិហាកេរ្តិ៍ភាគីម្ខាងទៀត នោះត្រូវពិន័យជាប្រាក់ចំនួន២០ម៉ឺនរៀល។

## ៥.២. ទំនាស់រវាងអ្នកជិតខាង

### ៥.២.១. និយមន័យ



ទំនាស់រវាងអ្នកជិតខាង គឺជាទំនាស់ដែលកើតឡើងរវាងអ្នកជិតខាងនឹងអ្នកជិតខាង ឬរវាងគ្រួសារនឹងគ្រួសារ ឬរវាងបុគ្គលនឹងបុគ្គល ដែលរស់នៅក្បែរគ្នា។ ទំនាស់រវាងអ្នកជិតខាងអាចនឹងមានទ្រង់ទ្រាយកាន់តែធំ ប្រសិនបើគូភាគីទាំងសងខាងធ្លាប់មានបញ្ហា ឬមានភាពតានតឹងរវាងគ្នាកន្លងមក។ ក្នុងដំណាក់កាលដំបូង ទំនាស់រវាងអ្នកជិតខាងខាងអាចបង្កឱ្យមានបទល្មើសព្រហ្មទណ្ឌតិចតួចណាស់ ព្រោះទំនាស់ភាគច្រើន គឺជាការមិនចុះសម្រុងគ្នា ដែលបញ្ហានេះគឺជាផ្នែកមួយនៃការរស់នៅក្នុងសហគមន៍។ ប៉ុន្តែនៅពេលមានការជេរប្រមាថកាន់តែកើនឡើង នោះវាអាចនឹងបង្កឱ្យស្ថានការណ៍នៃទំនាស់កាន់តែមានសភាពក្ដៅឡើងៗ ដែលអាចផ្ដល់លទ្ធផលជាហិង្សា ឬការបរិហាកេរ្តិ៍ធ្ងន់ធ្ងរ ហើយនឹងអាចឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផងដែរ។ ក្នុងករណីដែលមិនឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ឃុំ សង្កាត់ គណៈកម្មាធិការដោះស្រាយទំនាស់ មេភូមិ និងអ្នកដទៃទៀតអាចធ្វើការសម្រុះសម្រួលបាន។

### ៥.២.២. មូលហេតុដែលនាំឱ្យមានទំនាស់រវាងអ្នកជិតខាង

ទំនាស់រវាងអ្នកជិតខាងដែលតែងតែកើតមាននៅក្នុងសហគមន៍ អាចបង្កឡើងដោយមូលហេតុមួយចំនួនដូចខាងក្រោម :

- ការបង្ខិតព្រំរបង
- ការប្រើពាក្យសម្ដីមិនសមរម្យ
- ភាពច្រណែនឈ្នានីសគ្នា
- ការគុំគួនគ្នារវាងបុគ្គលនិងបុគ្គល គ្រួសារនិងគ្រួសារ ដែលមានរយៈពេលយូរមកហើយ
- លុយកាក់ និងធនធាន
- និយាយដើមគ្នា ឬពាក្យចចាមអារាម
- ប្រាប់ព័ត៌មានមិនពិត (ការភូតកុហក)
- ក្មេងៗវាយតប់គ្នា ដែលធ្វើឱ្យឪពុកម្ដាយយល់ច្រឡំនឹងគ្នា
- លួចទ្រព្យសម្បត្តិតូចតាច
- សត្វចិញ្ចឹមរបស់អ្នកដទៃមកស៊ីដំណាំ
- ការដាំដើមឈើជារបង ឬឈើហូបផ្លែនៅក្បែរបង
- ការរំខានផ្សេងៗដូចជា សម្លេង ក្លិន ការប្រើប្រាស់ផ្លូវសាធារណៈជាដើម
- ...។ល។

## ៥.២.៣. ការសម្រុះសម្រួល

ដំណើរការនៃការសម្រុះសម្រួល និងដោះស្រាយទំនាស់រវាងអ្នកជិតខាង ត្រូវអនុវត្តតាមជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់ (**អនុវត្តតាមខ្លឹមសារ ៣.៤.ជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់**)។

ក្នុងករណីទំនាស់ ភាគីទាំងពីរតែងតែចង់ឈ្នះរៀងៗខ្លួន ព្រោះពួកគេបានប្រកែកគ្នា និងបកអាក្រាតគ្នាទៅវិញទៅមកយ៉ាងខ្លាំង ហេតុដូច្នេះពួកគេមិនចង់ឱ្យមានការបាក់មុខមាត់ឡើយ។ ក្នុងការសម្រុះសម្រួលទំនាស់បែបនេះ ការបញ្ចុះបញ្ចូល និងការជួបពិភាក្សាផ្ដល់យោបល់នានាជាមួយពួកគេម្ដងហើយម្ដងទៀតរហូតដល់ភាពតានតឹងរវាងភាគីទាំងពីរមានការថយចុះ គឺជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាព។ លើសពីនេះទៀត ក្នុងអំឡុងពេលនៃការសម្រុះសម្រួល និងពិភាក្សា អ្នកសម្រុះសម្រួលអាចធ្វើការបញ្ជាក់បន្ថែមអំពីការចំណាយប្រាក់កាស ពេលវេលា និងអាចមានការប៉ះពាល់ដល់កិត្តិយស ប្រសិនបើករណីទំនាស់ត្រូវបញ្ជូនទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដូច្នេះជាការប្រសើរ ភាគីទាំងអស់នៃទំនាស់គប្បីអង្គុយជាមួយគ្នា ដើម្បីពិភាក្សា និងសម្រុះសម្រួលគ្នាបញ្ចប់ករណីទំនាស់។

## ៥.២.៤. បទពិសោធន៍នៃការសម្រុះសម្រួល

### ករណីទំនាស់

ករណីទំនាស់មួយកើតឡើងរវាងគ្រួសារពីរដែលរស់នៅជិតខាងនឹងគ្នា ដែលគ្រួសារមួយជាអ្នកដាំដើមឈើធ្វើជារបងហៅថា ភាគី"ក"។ ពីមួយឆ្នាំទៅមួយឆ្នាំ ដើមឈើចេះតែធំឡើងៗ ហើយបានខិតចូលក្នុងដីភាគីម្ខាងទៀត

ហៅថាភាគី"ខ"។ ភាគី"ខ"បានស្នើទៅភាគី"ក"ឱ្យកាប់ដើមឈើនោះចេញ ព្រោះវាខិតចូលដីរបស់គាត់ ហើយថែមទាំងមានម្លប់មិនអាចឱ្យគាត់ដាំបន្លែបាន លើសពីនេះទៀត ស្លឹកឈើនោះតែងតែធ្លាក់មកខាងគាត់ជាប្រចាំ។ ភាគី"ក" បានបដិសេធសំណើរបស់ភាគី "ខ" ហើយនិយាយថា ដើមឈើវាមិនចេះដើរទេ។ ការប្រកែកគ្នាបានកើតឡើងរវាងភាគីទាំងពីរ ដែលការប្រកែកគ្នាបន្តិចបន្តួចនេះបានក្លាយជាទំនាស់យ៉ាងខ្លាំងរវាងគ្រួសារទាំងពីរ។

## ដំណើរការសម្រុះសម្រួល

បន្ទាប់ពីមានទំនាស់កើតឡើងយ៉ាងខ្លាំង ភាគីទំនាស់បានទៅរកមេភូមិឱ្យជួយដោះស្រាយ។ មេភូមិបានស្នើឱ្យភាគីទាំងពីស្រុះស្រួលគ្នាវិញ ប៉ុន្តែភាគីទាំងពីរមិនព្រម មេភូមិក៏ស្នើឱ្យភាគីទំនាស់ប្តឹងទៅគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ។

- **ការទទួលពាក្យបណ្តឹង :** ភាគី"ខ"ដែលជាដើមបណ្តឹងបានទៅជួបមេឃុំ ប៉ុន្តែមេឃុំបានបញ្ជូនគាត់ទៅជួបប្រធានគណៈកម្មាធិការដោះស្រាយទំនាស់។ ភាគី"ខ"បានសរសេរពាក្យបណ្តឹងទៅប្រធានគណៈកម្មាធិការ។
- **ការប្រមូលព័ត៌មាន :** បន្ទាប់ពីទទួលបានពាក្យបណ្តឹង ប្រធាន និងសមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ឃុំបានចុះទៅប្រមូលព័ត៌មានអំពីប្រវត្តិដី និងករណីទំនាស់ពីអ្នកជិតខាង ឪពុកម្តាយភាគីទាំងសងខាង មេភូមិ ដើម្បីកំណត់ព្រំដីឱ្យបានច្បាស់ និងពិនិត្យលើដើមឈើដែលដាំធ្វើជារបងនោះ។ ជាលទ្ធផលឃើញថា ភាគី"ក"ពិតជាអ្នកដាំដើមឈើធ្វើរបង ហើយភាគី"ខ"ជាអ្នករងផលប៉ះពាល់ពីការដាំដើមឈើធ្វើរបងនោះពិតប្រាកដមែន។
- **ការសម្រុះសម្រួលនៅសាលាឃុំលើកទី១ :** បន្ទាប់ពីប្រមូលព័ត៌មានបានគ្រប់គ្រាន់ហើយ គណៈកម្មាធិការបានកោះអញ្ជើញភាគីទំនាស់មកសាលាឃុំដើម្បីធ្វើការសម្រុះសម្រួល។ ប្រធានគណៈកម្មាធិការបានពន្យល់ដោយយោងតាមមាត្រា១៥១នៃច្បាប់ភូមិបាលឆ្នាំ២០០១ថា "កម្មសិទ្ធិករមិនអាចដាំដើមឈើធំ តូច មានកម្ពស់លើសពី២(ពីរ)ម៉ែត្រនៅប្រប់ព្រំជាប់គ្នា ដែលមានចម្ងាយតិចជាងពីរម៉ែត្រពីព្រំដីបានទេ បើមិនដូច្នោះទេ នឹងត្រូវបង្ខំឱ្យយកចេញ កាលបើមានបណ្តឹងពីកម្មសិទ្ធិករដែលមានប្រយោជន៍ក្នុងរឿងនេះ"។ ប្រធានគណៈកម្មាធិការក៏បានពន្យល់អំពីផលវិបាកនៃការដាំដើមឈើធ្វើជាព្រំរបង ការលំបាកនានាដែលត្រូវធ្វើការកាត់សេចក្តីនៅតុលាការ សារៈសំខាន់នៃការរក្សាទំនាក់ទំនងល្អរវាងអ្នកជិតខាងដែលអាចជួយគ្នានៅពេលមានអាសន្នជាដើម។ ទោះបីជាគណៈកម្មាធិការធ្វើការពន្យល់យ៉ាងណាក៏ដោយក៏ភាគី"ក"នៅតែមិនព្រមកាប់ដើមឈើដែលខ្លួនដាំធ្វើរបងនោះចេញដែរ។
- **ការពន្យារពេល :** ដោយមិនអាចដោះស្រាយបាន គណៈកម្មាធិការបានស្នើឱ្យភាគីទំនាស់ទៅផ្ទះរៀងខ្លួនវិញ ហើយត្រូវត្រឡប់មកវិញម្តងទៀតនៅបីថ្ងៃក្រោយ។ ក្នុងអំឡុងពេលនៃការពន្យារពេលនេះសមាជិកគណៈកម្មាធិការ បានទៅជួបភាគី"ខ"ដើម្បីរកជម្រើសនៃដំណោះស្រាយ។ តាមរយៈការពិភាក្សាឃើញថា ភាគី"ខ"អាចមានលទ្ធភាពសង់របងថ្ម ប្រសិនបើភាគី"ក"កាប់ដើមឈើដែលបានដាំធ្វើជារបង

ទាំងអស់ចេញ។ សមាជិកគណៈកម្មាធិការក៏បានទៅជួបពិភាក្សាជាមួយភាគី"ក"អំពីជម្រើសនៃដំណោះស្រាយនេះ។ ដោយមានការពិចារណាលើច្បាប់ភូមិបាល និងខ្លឹមសារដែលគណៈកម្មាធិការបាននិយាយប្រាប់ ភាគី"ក" ហាក់បីដូចជាបន្ទន់តិរិយាបថរបស់ខ្លួន ហើយបានបង្ហាញនូវឆន្ទៈក្នុងការដោះស្រាយ។ ឃើញដូច្នេះ សមាជិកគណៈកម្មាធិការបានលើកឡើងថា ប្រសិនបើភាគី"ខ"មានធនធានគ្រប់គ្រាន់ក្នុងការសង់របងថ្មព័ទ្ធដី តើអ្នកអាចកាប់ដើមឈើរបងទាំងនោះចេញបានទេ? ពេលនោះភាគី"ខ"បានយល់ព្រមលើដំណោះស្រាយនេះផងដែរ។

- **ការសម្រុះសម្រួលនៅសាលាឃុំលើកទី២** : បីថ្ងៃក្រោយមក គណៈកម្មាធិការបានកោះអញ្ជើញភាគីទំនាស់មកជួបគ្នានៅសាលាឃុំម្តងទៀត។ ប្រធានគណៈកម្មាធិការបានស្វាគមន៍ចំពោះវត្តមានភាគីទំនាស់ ហើយលើកឡើងថា ខ្ញុំគិតថា អ្នកទាំងអស់គ្នាប្រាកដជាបានគិតនូវអ្វីដែលខ្ញុំបាននិយាយកាលពីប៉ុន្មានថ្ងៃមុន។ ហើយប្រធានគណៈកម្មាធិការបានលើកឡើងនូវជម្រើសដំណោះស្រាយមួយគឺ ស្នើឱ្យភាគី"ក"កាប់ដើមឈើចេញទាំងអស់ ហើយភាគី"ខ"ជាអ្នកសង់របងថ្មជំនួសរបងដើមឈើនេះវិញ។ ដោយគិតថា ការសម្រុះសម្រួលរបៀបនេះមានភាពយុត្តិធម៌ ភាគីទាំងពីរបានព្រមព្រៀងតាមការស្នើរបស់ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ។
- **ការរៀបចំកិច្ចសន្យា** : ដោយមានការព្រមព្រៀងពីភាគីទាំងពីរ គណៈកម្មាធិការបានរៀបចំកិច្ចសន្យាដែលមានការផ្តិតស្នាមមេដៃរបស់ភាគីទាំងពីរ។

## ៥.៣. ទំនាស់នៅក្នុងគ្រួសារ

### ៥.៣.១. និយមន័យ



ទំនាស់ក្នុងគ្រួសារ ឬអំពើហិង្សាក្នុងគ្រួសារសំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត (រួមមានការប្រមាថមាក់ងាយ ការគំរាមកំហែង និងការដាក់ឱ្យនៅឯកោម្នាក់ឯង) និងផ្នែកជីវភាពសេដ្ឋកិច្ច ដែលត្រូវបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ដើម្បីត្រួតត្រាលើមនុស្សផ្សេងទៀតដែលកំពុងរស់នៅក្នុងគ្រួសារនោះ។

### ៥.៣.២. ចំណាត់ការដំបូងរបស់ឃុំ សង្កាត់

នៅពេលមានករណីអំពើហិង្សាក្នុងគ្រួសារកើតឡើង ជាដំបូងឃុំ សង្កាត់ត្រូវពិចារណា និងចាត់វិធានការមួយចំនួនដូចខាងក្រោម :

- ចូលអន្តរាគមន៍ក្នុងកន្លែងកើតហេតុ បើមានសំណើសុំធ្វើអន្តរាគមន៍ និងមានបទល្មើសជាក់ស្តែងកើត

ឡើង ( ការចូលធ្វើអន្តរាគមន៍គួរមានអ្នកចូលរួមច្រើននាក់)

- ធានាសុវត្ថិភាពដល់ជនរងគ្រោះ ដោយបង្វែរយកជនមុខសញ្ញាចេញពីកន្លែងកើតហេតុ ឬបង្វែរជនរងគ្រោះ បើមានការស្នើសុំពីជនរងគ្រោះ
- ក្នុងអំឡុងពេលធ្វើអន្តរាគមន៍ ត្រូវធ្វើកំណត់ហេតុឱ្យបានជាក់លាក់អំពីហេតុការណ៍ រួចរាយការណ៍ទៅស្ថាប័នពាក់ព័ន្ធ
- ផ្តល់ឱ្យជនរងគ្រោះនូវជំនួយសមស្របតាមកាលៈទេសៈ ជាពិសេសផ្តល់កន្លែងជម្រកបណ្តោះអាសន្នដែលអាចធានាសុវត្ថិភាព និងនាំទៅទទួលសេវាសុខាភិបាលជាបន្ទាន់
- ចេញសេចក្តីសម្រេចរដ្ឋបាលដើម្បីការពារសន្តិសុខជនរងគ្រោះ
- ប្រសិនបើមានរបួសស្នាមលើរាងកាយ ត្រូវតែផ្តល់ព័ត៌មានទៅកាន់នគរបាលប៉ុស្តិ៍ ឬភ្នាក់ងារមានសមត្ថកិច្ចដទៃទៀតដែលនៅជិតបំផុត
- ប្រសិនបើអំពើហិង្សាក្នុងគ្រួសារនោះឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នោះមិនត្រូវមានការផ្សះផ្សា ឬសម្រុះសម្រួលណាមួយកើតឡើងឡើយរវាងជនរងគ្រោះ និងអ្នកប្រព្រឹត្តបទល្មើស ។
- ត្រូវធ្វើការតាមដានទៅលើទង្វើរបស់គូភាគីនៃទំនាស់ ពិសេសទង្វើរបស់ជនមុខសញ្ញា
- ...។ល។



ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងទំនាស់គ្រួសារដែលមានអំពើហិង្សាកើតឡើង ភាគីរងគ្រោះភាគច្រើន ពិសេសស្ត្រីតែងតែមិនចង់ប្តឹង ឬធ្វើការលែងលះនោះទេ។ អ្វីដែលពួកគេចង់បាន គឺត្រឹមតែផ្តល់ព័ត៌មានទៅអាជ្ញាធរ និងស្វែងរកជំនួយដើម្បីចាត់វិធានការបញ្ឈប់អំពើហិង្សាក្នុងគ្រួសាររបស់គេតែប៉ុណ្ណោះ ។

## ៥.៣.៣. ការសម្រុះសម្រួលទំនាស់ក្នុងគ្រួសារ

ឃុំ សង្កាត់អាចធ្វើការសម្រុះសម្រួលរាល់ទំនាស់ក្នុងគ្រួសារប្រជាពលរដ្ឋក្នុងដែនដីឃុំ សង្កាត់របស់ខ្លួន លើកលែងតែករណីទំនាស់នោះឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ដំណើរការនៃការសម្រុះសម្រួលទំនាស់ក្នុងគ្រួសារអនុវត្តតាមជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់ (**អនុវត្តតាមខ្លឹមសារ៣.៤.ជំហានជាមូលដ្ឋាននៃការសម្រុះសម្រួលទំនាស់**) ដែលមានដូចខាងក្រោម :

- **ការស៊ើបអង្កេត និងប្រមូលព័ត៌មាន :** ការស៊ើបអង្កេតគួរអនុវត្តបន្ទាប់ពីបានដឹងអំពីបញ្ហា ហើយជនរងគ្រោះបានរួចពីអំពើហិង្សា។ ទោះបីជាយ៉ាងណាក៏ដោយ សូមកុំព្យាយាមធ្វើការស៊ើបអង្កេតជាមួយជនល្មើសភ្លាមៗ។ ការសួរនាំនានាជាមួយជនរងគ្រោះ ឬជាមួយជនមុខសញ្ញាត្រូវធ្វើឡើងដោយឡែកៗពីគ្នា។ លើសពីនេះទៀត ការសម្ភាសន៍ជាមួយសាក្សី និងការប្រមូលព័ត៌មានដទៃទៀតគួរធ្វើនៅថ្ងៃបន្ទាប់

ដើម្បីធានាសុវត្ថិភាពដល់ជនរងគ្រោះ ។

- **ការសម្រុះសម្រួល និងការពិភាក្សា :** ខាងក្រោមនេះគឺជាចំណុចមួយចំនួន ដែលអ្នកសម្រុះសម្រួលអាចពិចារណា និងពន្យល់ដល់ភាគីនៃទំនាស់ ។ ចំណុចទាំងនោះមានដូចជា :
  - ការលើកទឹកចិត្តជនមុខសញ្ញាឱ្យអនុវត្តនូវឥរិយាបថអហិង្សា មួយចំនួនដូចជា មិនប្រើអាកប្បកិរិយាគំរាមកំហែង មានការគោរពគ្នាទៅវិញទៅមក មានការជឿទុកចិត្តនិងគាំទ្រគ្នា មានចិត្តស្មោះត្រង់ ធ្វើជាឪពុកម្តាយដែលមានការទទួលខុសត្រូវ ភាពជាដៃគូក្នុងជីវភាពសេដ្ឋកិច្ច មានការចែករំលែកនិងទទួលខុសត្រូវ និងមានការចរចាប្រកបដោយយុត្តិធម៌ជាដើម ។



  - ការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ គឺជាសកម្មភាពដែលផ្ទុយនឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ហើយប្រសិនបើឈានដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះនឹងត្រូវផ្តន្ទាទោសដោយតុលាការ ។
  - តម្លៃនៃសាសនាដែលអប់រំមនុស្សអំពីភាពអហិង្សា ឬការលុបបំបាត់អំពើហិង្សា និងការគំរាមកំហែង
  - ការប៉ះពាល់ដល់កិត្តិយសគ្រួសារ
  - ការគំរាមកំហែង និងការវាយតប់ក្នុងគ្រួសារមិនមែនជាប្រពៃណី ទំនៀមទម្លាប់របស់សង្គមខ្មែរទេ
  - ការវាយដំមិនមែនជាវិធីដោះស្រាយបញ្ហាឡើយ ។
- **រៀបចំកិច្ចព្រមព្រៀង :** ប្រសិនបើមានការព្រមព្រៀងគ្នា អ្នកសម្រុះសម្រួលត្រូវរៀបចំកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរឱ្យស្របតាមទម្រង់ច្បាប់ ។
- **ការបញ្ជូនករណីទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃ :** ប្រសិនបើមិនមានការព្រមព្រៀងគ្នាទេ ករណីទំនាស់នៅក្នុងគ្រួសារនោះត្រូវបញ្ជូនទៅកាន់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ។
- **ការតាមដាន និងការផ្សះផ្សា :** ការបន្តចុះទៅសួរសុខទុក្ខដល់ភាគីទំនាស់ទាំងអស់ ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ និងបញ្ហាទំនាស់ក្នុងគ្រួសារដទៃទៀត មានសារៈសំខាន់ណាស់ដើម្បីពិនិត្យលើទំនាក់ទំនង និងភាពតានតឹង ដែលអាចនឹងរីករាលដាល ឬបង្កឱ្យមានហិង្សាឡើងវិញរវាងពួកគេ ។

## ៥.៣.៤. បទពិសោធន៍នៃការសម្រុះសម្រួល

### ក). ករណីទំនាស់ទី១

មានទំនាស់ប្តីប្រពន្ធមួយកើតឡើង ដោយភាគីប្តីតែងតែផឹកស្រាជាប្រចាំ ហើយពេលត្រឡប់មកផ្ទះវិញក្នុងស្ថានភាពស្រវឹងខ្លាំង ។ ដោយសារភាពស្រវឹងជោគជាំខ្លាំងពេក ធ្វើឱ្យបុរសជាប្តីនោះក្អួតបង្កឱ្យប្រឡាក់ពេញផ្ទះ ព្រមទាំង

ជេរប្រមាថអ្នករស់នៅក្នុងផ្ទះទៀតផង ។ ឃើញដូច្នោះ ម្ដាយក្មេកបានជេរស្ដី និងបណ្ដេញបុរសនោះចេញពីផ្ទះ ។ បុរសជាប្ដីបានចាកចេញពីផ្ទះអស់រយៈពេលប្រមាណមួយឆ្នាំ ទើបប្រពន្ធសម្រេចចិត្តមកជួបគណៈកម្មាធិការដោះស្រាយទំនាស់ដើម្បីស្នើសុំឱ្យជួយធ្វើការសម្រុះសម្រួល ។

**ដំណើរការសម្រុះសម្រួល**

- **ការទទួលពាក្យបណ្ដឹង** : ភាគីប្រពន្ធបានមកជួបគណៈកម្មាធិការដោះស្រាយទំនាស់ដើម្បីសុំឱ្យជួយដោះស្រាយ ។ គណៈកម្មាធិការដោះស្រាយទំនាស់បានជួយភាគីប្រពន្ធក្នុងការរៀបចំពាក្យបណ្ដឹង ។
- **ចុះស៊ើបអង្កេត** : បន្ទាប់ពីទទួលបានពាក្យបណ្ដឹង គណៈកម្មាធិការដោះស្រាយទំនាស់បានសួរនាំអំពីបញ្ហា ឬរឿងរ៉ាវដែលនាំឱ្យមានទំនាស់ ។ គណៈកម្មាធិការបានចាត់សមាជិកដែលមានអាសយដ្ឋាននៅជិតភាគីទំនាស់ឱ្យធ្វើការស៊ើបអង្កេតអំពីករណីទំនាស់ ។ សមាជិកគណៈកម្មាធិការបានជួបជាមួយប្រធានភូមិ និងអ្នកជិតខាងដើម្បីប្រមូលព័ត៌មាន ។ ការចុះស៊ើបអង្កេតបានធ្វើឡើងទាំងភាគីប្រពន្ធ និងទាំងភាគីប្ដី ។ ជាលទ្ធផល ភាគីប្រពន្ធមានឆន្ទៈចង់ដោះស្រាយបញ្ចប់ទំនាស់ ប៉ុន្តែភាគីប្ដីហាក់មិនទាន់មានជំហរច្បាស់លាស់នៅឡើយ ។ ជាការពិត បុរសជាប្ដីបានចាកចេញពីផ្ទះអស់រយៈពេលប្រមាណមួយឆ្នាំហើយ ដោយសារតែខ្លួនគេខឹងនឹងម្ដាយក្មេកដែលបានជេរ និងបណ្ដេញគេចេញពីផ្ទះ ។
- **កោះប្រជុំនៅសាលាឃុំលើកទី១** : បន្ទាប់ពីចុះស៊ើបអង្កេត និងប្រមូលព័ត៌មាន គណៈកម្មាធិការបានកោះអញ្ជើញភាគីទាំងពីរមកជួបជុំនៅសាលាឃុំ ។ នៅពេលភាគីទាំងពីរបានមកដល់សាលាឃុំ ប្រធានគណៈកម្មាធិការបានអញ្ជើញភាគីម្ដងមួយៗដើម្បីជួបនិយាយនៅក្នុងបន្ទប់ ។ ប្រធានគណៈកម្មាធិការព្យាយាមសួរភាគីប្ដី ប៉ុន្តែគេមិនឆ្លើយអ្វីទាំងអស់ ។ ទោះបីភាគីប្ដីមិននិយាយអ្វីក៏ដោយ ក៏ភាគីប្រពន្ធនៅតែព្យាយាមដោះស្រាយដោយបញ្ជាក់ថា បើលែងលះគ្នាត្រូវលែងឱ្យដាច់ ប៉ុន្តែបើមិនលែងទេត្រូវមកផ្ទះវិញ ។
- **ការពន្យារពេល** : ដោយភាគីប្ដីមិននិយាយ គណៈកម្មាធិការបានស្នើឱ្យភាគីទំនាស់ទៅផ្ទះវិញ ហើយចាំបីថ្ងៃក្រោយទើបមកសាលាឃុំម្ដងទៀត ។
- **ការប្រជុំនៅសាលាឃុំលើកទី២** : បន្ទាប់ពីទុករយៈពេលបីថ្ងៃឱ្យភាគីប្ដីគិត គណៈកម្មាធិការដោះស្រាយទំនាស់ បានកោះអញ្ជើញភាគីទាំងអស់មកសាលាឃុំម្ដងទៀតដើម្បីធ្វើការសម្រុះសម្រួល ។ ការប្រជុំដោះស្រាយលើកទីពីរនេះនៅតែមិនអាចដោះស្រាយបានទៀត ព្រោះភាគីប្ដីគ្រាន់តែនិយាយថា ចាំគិតមើលសិន ។ ខណៈនោះគណៈកម្មាធិការដោះស្រាយទំនាស់បានអញ្ជើញមេឃុំឱ្យចូលរួម ។ មេឃុំបានធ្វើការពន្យល់ និងលើកហេតុផលមួយចំនួន ដូចជា ការលែងលះគ្នាមិនចំណេញ ខាតបង់ប្រាក់កាស ខូចអនាគតកូន គ្មាននរណាធ្វើស្រែចម្ការជាដើម ។ បន្ទាប់ពីពន្យល់ណែនាំរួច មេឃុំប្រាប់ឱ្យភាគីប្ដីគិតមើលឱ្យច្បាស់ ។
- **ការពន្យារពេល** : ដោយនៅតែមិនអាចដោះស្រាយបាន គណៈកម្មាធិការស្នើឱ្យពន្យារពេលពីរថ្ងៃទៀតដើម្បីឱ្យភាគីប្ដីគិត ។ ក្នុងអំឡុងពេលពន្យារពេលនេះ សមាជិកគណៈកម្មាធិការម្នាក់ទៅជួបពិភាក្សា

ជាមួយភាគីប្តីម្តងទៀត ដើម្បីធ្វើការបញ្ចុះបញ្ចូល។ តាមពិតភាគីប្តីមានបំណងចង់មករួមរស់ជាមួយប្រពន្ធ ប៉ុន្តែមិនហ៊ាននិយាយ។ ភាគីប្តីបានប្រាប់សមាជិកគណៈកម្មាធិការដែលមកជួបថា គេអាចទៅរស់នៅជាមួយក្រុមគ្រួសារបាន ប៉ុន្តែភាគីប្រពន្ធត្រូវមកហៅគេដោយផ្ទាល់។ ជាមួយគ្នានោះដែរ សមាជិកគណៈកម្មាធិការក៏បាននាំយកការស្នើសុំរបស់ប្តីទៅពិគ្រោះយោបល់ជាមួយភាគីប្រពន្ធ។ ដោយឃើញល័ក្ខខ័ណ្ឌមិនធ្ងន់ធ្ងរ ភាគីប្រពន្ធយល់ព្រមតាមការស្នើសុំរបស់ប្តី។

- **ការប្រជុំនៅសាលាឃុំលើកទី៣ ៖** បន្ទាប់ពីបានទទួលនូវជម្រើសឯកភាពគ្នាហើយ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ បានកោះអញ្ជើញភាគីទាំងអស់មកដោះស្រាយបញ្ចប់។ ក្នុងអំឡុងពេលនៃការសម្រុះសម្រួលនេះ ប្រធានគណៈកម្មាធិការសួរទៅភាគីប្រពន្ធថា តើអ្នកចង់ឱ្យប្តីទៅរួមរស់ក្នុងក្រុមគ្រួសារវិញទេ? ភាគីប្រពន្ធឆ្លើយថា ចង់! ព្រោះដល់រដូវធ្វើស្រែហើយ។ បន្ទាប់មកប្រធានគណៈកម្មាធិការបន្ថែមថា អើ! ប្រសិនបើចង់ឱ្យវាទៅផ្ទះវិញ ម្តេចមិនហៅវាត្រង់ៗទៅ។ ភាគីប្រពន្ធបានហៅប្តីឱ្យមកផ្ទះវិញ ពេលនោះភាគីប្តីបង្ហាញនូវការយល់ព្រមតាមការហៅរបស់ប្រពន្ធ។
- **ការរៀបចំកិច្ចសន្យា ៖** បន្ទាប់ពីភាគីទាំងពីរបានព្រមព្រៀងគ្នាហើយ គណៈកម្មាធិការតម្រូវឱ្យភាគីទំនាស់ធ្វើកិច្ចសន្យាដោយផ្តិតស្នាមមេដៃជាភស្តុតាង។

## ខ). ករណីទំនាស់ទី២

មានគ្រួសារមួយ នៅពេលប្រពន្ធមិននៅផ្ទះ ប្តីបានលក់ស្រូវ ហើយយកលុយទៅចាយ និងផឹកស្រា។ នៅពេលកូនឈឺ ប្រពន្ធបានសុំលុយពីប្តីដែលបានលក់ស្រូវដើម្បីយកទៅទិញថ្នាំឱ្យកូនលេប ផ្ទុយទៅវិញប្តីបែរជាវាយដំ និងជេរប្រមាថប្រពន្ធទៀតផង។ ការវាយដំ និងជេរប្រមាថប្រពន្ធតែងតែកើតមានជាញឹកញាប់។ ដោយរងការវាយដំ និងជេរប្រមាថច្រើនពេក ទោះបីជាមិនទាន់ដល់រងរបួសស្នាមធ្ងន់ធ្ងរក៏ដោយ ក៏ប្រពន្ធមិនអាចទ្រាំទ្រនឹងទង្វើបែបនេះទៀតបាន ក៏បានទៅប្តឹងគណៈកម្មាធិការដោះស្រាយទំនាស់ឃុំដើម្បីឱ្យជួយដោះស្រាយ។

### ដំណើរការសម្រុះសម្រួល

- **ការទទួលពាក្យបណ្តឹង ៖** នៅពេលជនរងគ្រោះមកជួបគណៈកម្មាធិការដោះស្រាយទំនាស់ ប្រធានគណៈកម្មាធិការបានស្នើឱ្យជនរងគ្រោះរៀបចំពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ។ ក្នុងពេលនោះ លេខាធិការនៃគណៈកម្មាធិការជាអ្នកជួយក្នុងការរៀបចំពាក្យបណ្តឹង។
- **ការសាកសួរប្រមូលព័ត៌មាន ៖** បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីជនរងគ្រោះ ប្រធានគណៈកម្មាធិការបានសាកសួរដំណើររឿង និងប្រមូលព័ត៌មានបានមួយចំនួនពីជនរងគ្រោះ។ គណៈកម្មាធិការបានសាកសួរព័ត៌មានពីមេភូមិនៃភូមិកើតហេតុ និងអ្នកជិតខាងដើម្បីប្រមូលព័ត៌មានបន្ថែម។
- **ការសម្រុះសម្រួលនៅសាលាឃុំលើកទី១ ៖** មួយថ្ងៃក្រោយពីទទួលបានពាក្យបណ្តឹង គណៈកម្មាធិការបានកោះអញ្ជើញជនរងគ្រោះ និងជនមុខសញ្ញាមកសាលាឃុំដើម្បីធ្វើការសម្រុះសម្រួល និងណែនាំ។ នៅពេលភាគីទាំងពីរមកដល់សាលាឃុំ គណៈកម្មាធិការដោះស្រាយទំនាស់បានអញ្ជើញភាគីទំនាស់ម្តង

មួយៗចូលក្នុងបន្ទប់ដើម្បីធ្វើសាកសួរ និងបញ្ចុះបញ្ចូល។ ក្នុងអំឡុងពេលនៃការសាកសួរ ប្រធានគណៈកម្មាធិការបានពន្យល់ដល់ភាគីនីមួយៗអំពី គោលបំណងដែលកោះអញ្ជើញមកសាលាឃុំនេះ គឺដើម្បីសម្រុះសម្រួលបញ្ចប់អំពើហិង្សាក្នុងគ្រួសារ ជួយឱ្យគ្រួសារមានសុភមង្គល និងសាកសួរអំពីបំណងរបស់ភាគីនីមួយៗ ថាតើភាគីនីមួយៗចង់សម្រុះសម្រួល ឬយ៉ាងណា។ ភាគីជនរងគ្រោះបានទាមទារសុំលែងលះគ្នា ព្រោះនាងអះអាងថា ខ្លួននាងមិនអាចស៊ូទ្រាំនឹងអំពើហិង្សាទាំងនេះបានទេ។ ដោយឡែកភាគីជនមុខសញ្ញាមិនមានបំណងលែងលះឡើយ។ បន្ទាប់ពីសាកសួរភាគីទំនាស់ម្នាក់ម្តងៗ គណៈកម្មាធិការដោះស្រាយទំនាស់ជួបប្រជុំជាមួយភាគីទំនាស់ទាំងអស់ ហើយធ្វើការណែនាំអំពីផលវិបាកនៃការលែងលះគ្នា ភាពគ្រោះថ្នាក់ដែលកើតឡើងដោយការប្រើអំពើហិង្សាក្នុងគ្រួសារ ភាពរងគ្រោះរបស់កូន ការខូចខាតទ្រព្យសម្បត្តិ ការអាប់ឱនកិត្តិយសគ្រួសារជាដើម។ ប្រធានគណៈកម្មាធិការក៏បានពន្យល់អំពីច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ហើយបញ្ជាក់បន្ថែមថា ប្រសិនបើជនមុខសញ្ញាធ្វើការវាយដំលើជនរងគ្រោះឱ្យមានរបួស ស្នាមធ្ងន់ធ្ងរនោះនឹងត្រូវជាប់ចោទពីបទប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

- **ការពន្យារពេល** : ដោយសារភាគីប្រពន្ធនៅតែប្រកាន់ជំហរលែងលះគ្នា គណៈកម្មាធិការបានស្នើឱ្យភាគីទាំងពីរទៅផ្ទះសិន ដោយពន្យារពេលមួយថ្ងៃ។ នៅក្នុងអំឡុងពន្យារពេលនេះ សមាជិកគណៈកម្មាធិការដោះស្រាយទំនាស់ម្នាក់បានចុះទៅជួបភាគីប្រពន្ធដែលជាជនរងគ្រោះ ដោយពន្យល់អំពីផលវិបាកនៃការប្តឹងទៅតុលាការ ព្រោះបើនាងសម្រេចចិត្តលែងលះ នោះចាំបាច់ត្រូវប្តឹងសុំការលែងលះនៅតុលាការ ដែលត្រូវចំណាយធនធាន និងពេលវេលាច្រើន និងផលវិបាកនានាបន្ទាប់ពីធ្វើការលែងលះ។ តាមរយៈការពិគ្រោះយោបល់ និងបញ្ចុះបញ្ចូល ភាគីប្រពន្ធយល់ព្រមរស់នៅជាមួយស្វាមីបន្តទៀត ប៉ុន្តែស្នើឱ្យភាគីប្តីបំពេញល័ក្ខខ័ណ្ឌមួយចំនួន ដូចជា បន្ថយការផឹកស្រា ឈប់វាយប្រពន្ធកូន ឈប់ជេរម្តាយក្មេក ឈប់រអ៊ូរទាំជាដើម។ ជាមួយគ្នានោះសមាជិកគណៈកម្មាធិការម្នាក់ទៀតបានទៅ ជួបភាគីខាងប្តីដែលជារួមភាគីប្តីមិនមានបំណងលែងលះទេ ហើយយល់ព្រមឈប់ប្រព្រឹត្តអំពើហិង្សានានាក្នុងគ្រួសារ។
- **ការសម្រុះសម្រួលនៅសាលាឃុំលើកទី២** : បន្ទាប់ពីពន្យារពេលមួយថ្ងៃមក ភាគីជនមុខសញ្ញា និងជនរងគ្រោះបានមកសាលាឃុំម្តងទៀត។ ដោយមានការជួបពិគ្រោះយោបល់រួចហើយ គណៈកម្មការបានលើកឡើងអំពីសំណើរបស់ប្រពន្ធដែលតម្រូវឱ្យភាគីប្តីបំពេញ ដូចជា បន្ថយការផឹកស្រា ឈប់វាយដំលើប្រពន្ធកូន ឈប់ជេរម្តាយក្មេក ឈប់រអ៊ូរទាំជាដើម ជាមួយគ្នានោះភាគីប្តីបានឯកភាពតាមការស្នើសុំរបស់ប្រពន្ធ។
- **ការរៀបចំកិច្ចសន្យា** : បន្ទាប់ពីភាគីទាំងពីរព្រមព្រៀងគ្នាហើយ ប្រធានគណៈកម្មាធិការដោះស្រាយទំនាស់បានរៀបចំកិច្ចសន្យា ហើយតម្រូវឱ្យភាគីទំនាស់ទាំងអស់ផ្តិតមេដៃ។